# របាយការណ៍សង្ខេបសរុបរបស់
# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ
# ឆ្នាំ២០១១

## ក/របាយការណ៍សង្ខេបសរុបរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រឆ្នាំ២០១១

### ១.ជំងឺគ្រុនចាញ់

ឆ្នាំ២០១១ជាឆ្នាំគោលដែលកម្មវិធីជាតិប្រយុទ្ធជំងឺគ្រុនចាញ់បានសម្រេចសូចនាករស្នូលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ទាក់ទងនឹងការកាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ ដោយសារអត្រាស្លាប់ បណ្តាលមកពីជំងឺគ្រុនចាញ់បានធ្លាក់ចុះពី ៦,២៩ លើប្រជាជន ១០០.០០០ នាក់ នៅឆ្នាំ ១៩៩៨ មក ០,៦៧ នៅឆ្នាំ ២០១១ នៅខណៈពេលដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាឆ្នាំ២០១៥កំណត់ត្រឹម០,៧៨ លើប្រជាជន ១០០.០០០នាក់។

- ករណីស្លាប់ និងករណីឈឺដោយជំងឺគ្រុនចាញ់ករណីស្លាប់ដោយគ្រុនចាញ់នៅឆ្នាំ ២០១១បានថយចុះ ៣៨% គឺពី ១៥១ ករណី នៅឆ្នាំ២០១០ មកនៅ ៩៤ ករណី នៅឆ្នាំ២០១១ នេះ។ មូលហេតុជាគន្លឹះ ៣ ដែលនាំឱ្យអត្រាស្លាប់ថយចុះគឺ:
  - ប្រជាជនកាន់តែមានការយល់ដឹងច្រើនអំពីជំងឺគ្រុនចាញ់ ដោយឱកាសទទួលព័ត៌មាន មានកាន់តែច្រើនតាមរយៈវិទ្យុ-ទូរទស្សន៍ តាមផ្ទាំងគំនូរផ្សព្វផ្សាយនៅទីសាធារណៈ និងតាមមធ្យោបាយឃោសនាទល់មុខគ្នានៅតាមសហគមន៍។ នៅឆ្នាំ ២០១១ថវិកាចំណាយលើការឃោសនាតាមរយៈវិទ្យុ-ទូរទស្សន៍ បានកើនឡើងទ្វេដង។
  - ភូមិដែលប្រឈមការចម្លងគ្រុនចាញ់ មានភ្នាក់ងារសុខភាពស្ម័គ្រចិត្តការពារ និងព្យាបាលជំងឺគ្រុនចាញ់។ភ្នាក់ងារទាំងនេះ ត្រូវបានទទួលការបណ្តុះបណ្តាលអំពីវិធីការពារព្យាបាលជំងឺគ្រុនចាញ់និងត្រូវបានផ្តល់ឱ្យនូវសម្ភារៈដោះឈាមមើលមេរោគគ្រុនចាញ់ដឹងលទ្ធផលភ្លាមៗព្រមទាំងមានឱសថព្យាបាលក្នុងដៃជាប្រចាំ។ ភ្នាក់ងារទាំងនេះ តែងជួយបញ្ជូនករណីធ្ងន់ធ្ងរ ឬកុមារអាយុក្រោម៥ឆ្នាំ ឬស្ត្រីមានផ្ទៃពោះ ដែលមានមេរោគគ្រុនចាញ់មកមន្ទីរពេទ្យបង្អែកទទួលការព្យាបាល ទាន់ពេល។ ដោយសារការបញ្ជូននេះ ទើបចំនួនករណីឈឺកើនឡើងបន្តិចបន្តួច (៧%) គឺពី ៥៨.៦២១ នាក់ នៅឆ្នាំ២០១០ មក ៦២.៧៧០ នាក់ នៅឆ្នាំ២០១១។
  - ប្រជាជនចំណាកស្រុកទៅធ្វើការនៅតំបន់គ្រុនចាញ់ ហើយខ្វះការប្រុងប្រយ័ត្នការពារជំងឺគ្រុនចាញ់ ដូចជា ទៅធ្វើការនៅការដ្ឋានកសិកម្មចំការកៅស៊ូ ដាំដំឡូង ការដ្ឋានថាមពលអគ្គិសនី រ៉ែ និងគមនាគមន៍។ល។ ប្រការនេះធ្វើឱ្យករណីឈឺដោយជំងឺគ្រុនចាញ់មានការប្រែប្រួលនៅខេត្ត ដែលមិនមែនជាតំបន់គ្រុនចាញ់ដោយសារជនចំណាកស្រុកដែលឆ្លងជំងឺគ្រុនចាញ់បានត្រឡប់មក ពីតំបន់គ្រុនចាញ់វិញ ដូចជា ករណីនៅខេត្តកណ្តាលកើន ៦២% ខេត្តស្វាយរៀងកើន ៣៨% មន្ទីរពេទ្យជាតិ និងរាជធានីភ្នំពេញ កើន ១៥%។ ដោយឡែក ករណីស្លាប់នៅខេត្តស្វាយរៀង បានកើនទ្វេដងគឺពី២នាក់ក្នុងឆ្នាំ២០១០ មក ៤ នាក់ ក្នុងឆ្នាំ ២០១១ ខណៈដែលករណីស្លាប់ ទូទាំងប្រទេសចុះដល់ទៅ ៣៨%។ ផ្ទុយទៅវិញ ករណីគ្រុនចាញ់នៅខេត្តមួយចំនួន ដែលធ្លាប់តែប្រឈមជំងឺគ្រុនចាញ់ បែរជាថយចុះ ដូចជា ខេត្តមណ្ឌលគិរីថយចុះ ២៩% ក្រចេះចុះ ១៧% បន្ទាយមានជ័យ ចុះ ១៧% ឧត្តរមានជ័យចុះ ១៧% កំពង់ធំចុះ ៦% សៀមរាបចុះ ៥% រតនគិរីចុះ ១៤% ប៉ៃលិន ចុះ ៤% ប៉ុន្តែខេត្តកំពតថយចុះ ១%។ ចំនួនស្លាប់នៅខេត្តរតនគិរី បានថយចុះពី ៧១% (៣៨នាក់នៅឆ្នាំ២០១០ មកនៅ១១នាក់នៅឆ្នាំ ២០១១)ឯកំពង់ចាមថយចុះ ៧៧%(២២នាក់នៅឆ្នាំ២០១០ មកនៅ ៥ នាក់នៅឆ្នាំ ២០១១)ព្រះសីហនុ ថយ៨០%ពី៥នាក់ថយ ៨០%(ពី៥នាក់នៅឆ្នាំ២០១០មក០១នាក់នៅឆ្នាំ២០១១ )។

បច្ចុប្បន្នមានភ្នាក់ងារសុខភាពស្ម័គ្រតាមភូមិ៨.១០៤ នាក់ ក្នុង ៤.០៥៧ភូមិដែលប្រឈមនឹងជំងឺគ្រុនចាញ់ ក្នុងនោះមាន ២.៨៩០ នាក់ ជាភ្នាក់ងារសុខភាពស្ម័គ្រចិត្តការពារ-ព្យាបាលជំងឺគ្រុនចាញ់សម្រាប់ ១.៤៤៥ ភូមិដែលប្រឈមធ្ងន់ធ្ងរ នឹងការចម្លងជំងឺគ្រុនចាញ់។ ចំណែកភូមិ ២.៦១២ ទៀត ដែលប្រឈមនឹងគ្រុនចាញ់ដែរ ប៉ុន្តែមិនសូវធ្ងន់ធ្ងរនោះ សកម្មភាពតាមភូមិត្រូវបានអនុវត្តដោយភ្នាក់ងារសុខភាពស្ម័គ្រចិត្ត ដែលទទួលបន្ទុកការងារសុខភាពជាទូទៅ ដោយមិនសំដៅតែលើជំងឺគ្រុនចាញ់មួយមុខប៉ុណ្ណោះទេ។

- ការគ្របដណ្តប់នៃសេវាបង្ការគួរកត់សម្គាល់ថា រវាងឆ្នាំ ២០០៦-២០១០ មុងជ្រលក់ថ្នាំប្រសិទ្ធភាព ៣ ឆ្នាំ ចំនួន ២.៣០០.០០០ មុង ត្រូវបានចែកជូនប្រជាជនដោយឥតគិតថ្លៃ នៅតាមបណ្តាខេត្ត។ ក្នុងឆ្នាំ២០១១ ប្រទេសកម្ពុជាបាននឹងកំពុងធ្វើយុទ្ធនាការចែកមុងក្នុងទ្រង់ទ្រាយដ៏ធំមួយ ដែលមិនធ្លាប់មាននៅក្នុងតំបន់អាស៊ីរយៈពេលបួនខែ (ខែវិច្ឆិកា ២០១១-កុម្ភៈ ២០១២) ដោយបានប្រគល់មុងជ្រលក់ថ្នាំប្រសិទ្ធភាព ៣ ឆ្នាំ ដោយឥតគិតថ្លៃ ២.៧០០.០០០ មុង ត្រូវដល់ប្រជាជនរស់នៅក្នុងតំបន់ដែលមានហានិភ័យគ្រុនចាញ់ខ្ពស់ សរុបចំនួន ៣.០៤០.០០០នាក់ ក្នុង ៨១២.០០០គ្រួសារ ក្នុង ៤.០៥៧ ភូមិ នៅក្នុងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាព ៣១២ កន្លែង ក្នុង៤៥ ស្រុកប្រតិបត្តិនៃខេត្ត ២០ តាមគោលការណ៍ប្រជាជនម្នាក់ទទួលមុង ១ (លើកលែងអ្នកដែលធ្លាប់ទទួលមុងក្នុងរយៈពេល ២-៣កន្លងមក) ។
  ក្នុងកិច្ចសហការជាមួយ វិស័យឯកជននៅឆ្នាំ ២០១១ ថ្នាំជ្រលក់មុងចំនួន ៧០០.០០០ កញ្ចប់ សម្រាប់ជ្រលក់មុង ៧០០.០០០ មុង ត្រូវបានចែកជូនដោយឥតគិតថ្លៃដល់អ្នកលក់មុង ៥.៥០០ កន្លែង ក្នុងនោះមានអ្នកលក់ដុំ ៥០ កន្លែង។

## ២.ជំងឺគ្រុនឈាម

- កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម បានចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចសូចនាករស្នូល ដែលពាក់ព័ន្ធនឹងការកាត់បន្ថយករណីឈឺ និង អត្រាស្លាប់ជាទូទៅរបស់កុមារដោយជំងឺគ្រុនឈាម។ អន្តរាគមន៍របស់កម្មវិធីបានផ្តោតជាចម្បងលើការធ្វើរោគវិនិច្ឆ័យនិងព្យាបាលទាន់ពេល ការដាក់ថ្នាំអាបែត តាមផ្ទះ និងការអប់រំមាតាបិតា ឬអាណាព្យាបាល របស់កុមារឱ្យទទួលខុសត្រូវចូលរួមបំបាត់ជម្រកមូសខ្លា ខាំកូន និងនាំកូនទៅពេទ្យទាន់ពេលវេលានៅពេលក្តៅខ្លួន។
  ក្នុងឆ្នាំ ២០១១ ចំនួនករណីឈឺដែលបានមកទទួលការព្យាបាលនៅមូលដ្ឋាន សុខាភិបាលសាធារណៈ មានចំនួន ១៥.៩៨០ ករណី ក្នុងនោះស្លាប់ ៧៣ នាក់។ ចំនួនករណីឈឺនៅឆ្នាំ ២០១១ កើនឡើង ២៨% បើប្រៀបធៀបនឹងឆ្នាំ ២០១០ (១២.៥០០ នាក់ និងស្លាប់ ៣៨ នាក់) ប៉ុន្តែមិនអាចចាត់ទុកថាការផ្ទុះការរាតត្បាតទេ ដោយសារចំនួនករណីឈឺនៅឆ្នាំ ២០១១ មានតែ ១ ភាគបួន នៃចំនួនករណីឈឺនៅឆ្នាំ ២០០៧ ដែលជាឆ្នាំមានការផ្ទុះការរាតត្បាតជំងឺគ្រុនឈាម។ អត្រាស្លាប់ដោយជំងឺគ្រុនឈាមទូទាំងប្រទេសបានថយចុះពី ២,៩២% នាឆ្នាំ ១៩៩៨ មកនៅ ០,៤៦% នាឆ្នាំ២០១១។ គួរកត់សម្គាល់ថា ខេត្តដែលមានអត្រាឈឺខ្ពស់ជាងគេ គឺខេត្តកំពង់ធំ,សៀមរាប, ភ្នំពេញ និងខេត្តកណ្តាល។
- ការឆ្លើយតបនឹងជំងឺគ្រុនឈាម
  សកម្មភាពក្នុងដំណាក់កាលត្រៀម - ពីខែមីនា ដល់ខែមិថុនា និងពីខែសីហា ដល់ខែតុលា ថ្នាំបាណកយាដអាបេត ១៥៩,៥ តោន ថ្នាំBti៥,៦តោន ត្រូវបានដាក់ក្នុងពាង/អាង ចំនួន ៥.១៤៥.២៩៨ នៅតាមផ្ទះប្រជាជន ១.២៣៤.៥៨៤ ខ្នង (ប្រមាណ ៩៦,១៤% នៃចំនួនផ្ទះសរុប) ស្ថិតនៅតាម ភូមិ-ឃុំ ក្នុង ១៧៣ ស្រុក និង ៧៦៦ ឃុំ នៃខេត្តដែលជាតំបន់ប្រឈមខ្ពស់នឹងជំងឺគ្រុនឈាម។ ការគ្របដណ្តប់នៃការដាក់ថ្នាំបាណកយាដនេះ អាចការពារប្រជាជនប្រមាណ ២.៧៥៩.១៤៨ នាក់។ ក្នុងដំណាក់កាលនេះ ការងារអប់រំសុខភាព និងការផ្សព្វផ្សាយ - ចែកចាយសម្ភារៈអប់រំសុខភាពមានសារៈសំខាន់ណាស់ ដោយមានអ្នកស្ម័គ្រចិត្តតាមភូមិបានចូលរួមយ៉ាងសកម្មក្នុងការងារឃោសនាអប់រំជាមួយនឹងបុគ្គលិកមណ្ឌលសុខភាព ដើម្បី

ចលនាប្រជាជន ឱ្យអនុវត្តវិធានការបង្ការ ដូចជាលុបបំបាត់ជម្រកមូស អនាម័យភូមិដ្ឋាន-ផ្ទះសម្បែង និងទីសាធារណៈនានា និងយល់ដឹងពីរោគសញ្ញាបឋមសំខាន់ៗនៃ ជំងឺគ្រុនឈាម ដែលត្រូវស្វែងរកសេវាព្យាបាលទាន់ពេលវេលា និងចេះថែទាំអ្នកជំងឺគ្រុនឈាម។ល។

- សកម្មភាពក្នុងដំណាក់កាលរាតត្បាតៈ សកម្មភាពឆ្លើយតបជាបន្ទាន់ ដែលត្រូវមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដោយរាប់បញ្ចូលទាំងប្រជាពលរដ្ឋ ក្នុងសហគមន៍ ពិសេសការធ្វើអនាម័យសំអាតទីកន្លែងបំផ្លាញជម្រកមូស បង្កើនការងារឃោសនាអប់រំចល័តតាមភូមិ-ឃុំ សហគមន៍ សាលារៀន ទន្ទឹមគ្នានឹងការដាក់ថ្នាំបាណកយាជនៅតាមតំបន់ចំណុចដែលមានការរាតត្បាត។

## ៣.ជំងឺស៊ីស្តូ និងជង្គូវព្រូន

ជំងឺស៊ីស្តូនៅជាបញ្ហាសុខភាពសំខាន់មួយរបស់ប្រជាជនរស់នៅតាមដងទន្លេមេគង្គនិងដៃទន្លេនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ ឯជង្គូវពោះវៀន ក៏ធ្វើឱ្យប៉ះពាល់សុខភាពដល់ប្រជាជនដែលរស់នៅតាមជនបទ និងតំបន់ជាយក្រុងផងដែរ ពិសេស គឺកុមារក្នុងវ័យសិក្សា និងនារីស្ថិតក្នុងវ័យបន្តពូជ។ ចំណែកជំងឺព្រូនអំបោះចាំបាច់ត្រូវផ្តល់ថ្នាំព្យាបាល ពិសេសដល់ប្រជាជនដែលរស់នៅក្នុងតំបន់អត្រា ចម្លងខ្ពស់ ដើម្បីកាត់ផ្តាច់ការចម្លង។

ប្រជាជនរស់នៅតំបន់ចម្លងខ្ពស់នៃជំងឺស៊ីស្តូ បានទទួលថ្នាំព្យាបាលជាសមូហភាពចំនួន ៧៣.៤៤០ នាក់។ យុទ្ធនាការចែកថ្នាំព្យាបាលដល់ប្រជាជនក្នុងសហគមន៍ជុំទី ៥ រស់នៅក្នុងតំបន់ចម្លងខ្ពស់នៃជំងឺព្រូនអំបោះ បានត្រូវបញ្ចប់កាលពីឆ្នាំ ២០០៩ និងក្នុងឆ្នាំ ២០១០។ ការសិក្សាស្រាវជ្រាវមើលអត្រាប្រេវ៉ាឡង់នៃជំងឺព្រូនអំបោះ ដោយប្រើឱបស្ទីក តេស្ត និងថ្នាំឌីអ៊ីស៊ីកាបាម៉ាស៊ីនស៊ីត្រាត ១០០ មីលីក្រាម និងអាល់បង់ដាស្សូល ក្រោយរយៈពេល ៥ឆ្នាំ នៃការបញ្ចប់យុទ្ធនាការចែកថ្នាំព្យាបាលបានរកឃើញថា អត្រាប្រេវ៉ាឡង់នៃជំងឺព្រូនអំបោះ គឺ ០,៦%។

អត្រាគ្របដណ្តប់នៃការផ្តល់ថ្នាំទម្លាក់ព្រូនលើកុមារអាយុពី ១២-៥៩ ខែ បានកើនឡើងពី ៦៥% នៅឆ្នាំ ២០១០ ទៅ៨៥% នៅឆ្នាំ២០១១។ រីឯអត្រាគ្របដណ្តប់ការផ្តល់ថ្នាំទម្លាក់ព្រូនលើកុមារក្នុងវ័យសិក្សាទូទាំង ២៤ រាជធានី- ខេត្ត សម្រេចបាន៩៥%។ ការចែកថ្នាំមេបង់ដាស្សូលដល់ក្មេងអាយុពី ៦-១៤ឆ្នាំ តាមសាលាបឋមសិក្សាបានធ្វើឡើង ២ ដងក្នុងមួយឆ្នាំ ដោយកុមារចំនួន ២.៣១១.២៣៣ នាក់ ទូទាំង ២៤ រាជធានី-ខេត្ត បានទទួលថ្នាំ។ ចាប់តាំងពីឆ្នាំ ២០០៥ មកអត្រាគ្របដណ្តប់ការផ្តល់ឱសថទម្លាក់ព្រូន ២ដង ក្នុង១ឆ្នាំ ដល់សិស្សសាលាបឋមសិក្សា សម្រេចបានលើសពី ៩៥%។ ស្ត្រីមានគភ៌ចាប់ពីត្រីមាសទី ២ និងស្ត្រីក្រោយសម្រាល បានទទួលថ្នាំព្រូនមានចំនួន៣៨០.០០០នាក់។

# កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់

# ខ/របាយការណ៍សមិទ្ធិផលរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ឆ្នាំ២០១១

## I. សេចក្តីផ្តើម

ជំងឺគ្រុនចាញ់នៅតែជាបញ្ហាសុខភាពសាធារណៈនិងជាបន្ទុកសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយសារតែអត្រាឈឺនៃជំងឺគ្រុនចាញ់ក្នុងចំណោមប្រជាជន ១០០០នាក់ មានចំនួន ៤,០៧នាក់ ហើយករណីស្លាប់ដោយជំងឺគ្រុនចាញ់មានចំនួន ១៣៥នាក់ ក្នុងឆ្នាំ២០១០ ។

ទោះបីជាមានការថយចុះករណីគ្រុនចាញ់ដែលបានធ្វើរោគវិនិច្ឆ័យគ្លីនិក និងព្យាបាល រួមទាំងអត្រាស្លាប់ ក្នុងចំណោមអ្នកជំងឺធ្ងន់ធ្ងរ ក្នុងរយៈពេល១១ឆ្នាំចុងក្រោយនេះក៏ដោយ (របាយការណ៍គ្រុនចាញ់ឆ្នាំ២០០០-២០១០) ក៏ការឈឺ និងការស្លាប់ដោយសារជំងឺគ្រុនចាញ់នៅកម្ពុជានៅតែមានកម្រិតខ្ពស់បើប្រៀបធៀបនឹងបណ្តាប្រទេសផ្សេងៗក្នុងតំបន់។

បញ្ហាជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជាជាកត្តាដ៏សំខាន់មួយដែលរួមចំណែកធ្វើឲ្យមានបញ្ហាភាពស្លេកស្លាំង ផលលំ បាកពេលមានផ្ទៃពោះ ទារកមិនគ្រប់ទំងន់ និងការលូតលាស់ខ្សោយសម្រាប់កុមារ។ ជំងឺគ្រុនចាញ់នៅកម្ពុជាធ្វើឲ្យប៉ះពាល់ដល់ការចំណាយសេដ្ឋកិច្ច រួមបញ្ចូលទាំងចំណាយផ្ទាល់លើការព្យាបាលជំងឺ ពិសេសចំពោះជនក្រីក្រ និងជនដែលងាយរងគ្រោះ ព្រមទាំងការចំណាយសង្គមផ្សេងៗទៀត ដូចជា ការបាត់បង់ពេលវេលាសិក្សារបស់កុមារ និងយុវវ័យ ពេលវេលាប្រកបមុខរបរ ការធ្វើដំណើរនិងបំលាស់ទី និងការសន្សំប្រាក់កាសទុកជាដើម។ ផលប៉ះពាល់នៃបញ្ហាជំងឺគ្រុនចាញ់ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច រាប់បញ្ចូលទាំងការងារពាណិជ្ជកម្ម ទេសចរណ៍ និងការងារវិនិយោគផ្ទាល់ពីបរទេស និងក្នុងស្រុក។

ការធ្លាក់ចុះនៃករណីជំងឺគ្រុនចាញ់ (ប្រហែល ៩.៧ភាគរយក្នុង១ឆ្នាំ) និងករណីស្លាប់ (ប្រហែល ៨.៤ ភាគរយក្នុង១ឆ្នាំ) គឺបានមកដោយសារកត្តាជាច្រើន រួមមានកត្តាសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងការរីកចំរើនខាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងព័ត៌មាន ការផ្លាស់ប្តូរមុខរបរ ការកែលំអបរិស្ថាន ឥរិយាបថរស់នៅ និងសំខាន់គឺភាពប្រសើរឡើងនៃការទទួលយកបាននូវអន្តរាគមន៍នៃការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់តាមរយៈការកែលំអនូវសេវាពិនិត្យព្យាបាល និងការបង្ការការចម្លងដោយមានការត្រួតពិនិត្យ និងតាមដានរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៃក្រសួងសុខាភិបាល និងអង្គភាពក្រោមឱវាទរបស់ក្រសួងសុខាភិបាល និងដៃគូទាំងឡាយ ដែលរួមមាន នាយកដ្ឋានសុខាភិបាល និងនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងកិច្ចការនារី អាជ្ញាធរមូលដ្ឋាន និងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ រួមជាមួយនិងការធ្វើវិមជ្ឈការ និងការពង្រីកនូវសកម្មភាពជាគន្លឹះនៃកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់រហូតដល់តំបន់ជនបទដាច់ស្រយ៉ាលដែលជាកន្លែងពិបាកស្វែងរកសេវាសុខភាព តាមរយៈគំនិតផ្តួចផ្តើមឲ្យមានអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ ការផ្លាស់ប្តូរឥរិយាបថ និងការប្រាស្រ័យទាក់ទង ការបង្កើននូវអត្រាគ្របដណ្តប់ការចែកចាយមុងដល់ប្រជាជនប្រឈមនឹងការចម្លង និងការកែលំអសេវាធ្វើរោគវិនិច្ឆ័យ និងព្យាបាលគ្រុនចាញ់នៅតាមសេវាសុខាភិបាលសាធារណៈ។ល។

## II. ទិសដៅសកម្មភាពការងារកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់២០១១

១. ការគ្រប់ដណ្តប់បានទាំងស្រុង (១០០ភាគរយ)រោគវិនិច្ឆ័យជំងឺគ្រុនចាញ់ឲ្យបានឆាប់រហ័ស និងការ ព្យាបាលទាន់ពេលវេលា និងមាន ប្រសិទ្ធភាពនូវគ្រប់ករណីជំងឺគ្រុនចាញ់ និងការសម្លាប់ហ្កាម៉ែត នៃមេរោគហ្វាល់ស៊ីប៉ារ៉ូម (គោលដៅលើប្រជាជនចំណុចរួមទាំងប្រជាជនចល័ត និង ជនចំណាកស្រុក)។

២. បញ្ឈប់នូវការប្រើប្រាស់ឱសថដែលនាំឲ្យមានភាពស៊ាំរបស់មេរោគគ្រុនចាញ់ជាមួយថ្នាំអាតេមីស៊ីនីនតាមរយៈការធ្វើឲ្យប្រសើរឡើងនូវការទទួលយកសេវាព្យាបាលជំងឺបានត្រឹមត្រូវ និងបង្ការការប្រើប្រាស់ថ្នាំគ្រុនចាញ់តែមួយមុខ និងថ្នាំខុសច្បាប់ឬក្លែងក្លាយនៅតាមសេវាសុខភាពសាធារណៈ និងឯកជន។

៣. ធានាបាននូវការទទួលយកសេវាបង្ការជាពិសេសការបង្ការការចម្លងមេរោគគ្រុនចាញ់ដែលមានភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន ក្នុងចំណោមប្រជាជនគោលដៅ តាមរយៈការត្រួតពិនិត្យសត្វមូស ដែលជាភ្នាក់ងារចម្លងជំងឺ និងមធ្យោបាយការពារដោយខ្លួនឯងផ្ទាល់ និងការកែលំអបរិស្ថាន។

៤. ធានាថាសហគមន៍បានទទួលការយល់ដឹងទូលំទូលាយអំពីជំងឺគ្រុនចាញ់ និង ការប្រកាន់យកឥរិយាបថត្រឹមត្រូវក្នុងការបង្ការការចម្លងជំងឺគ្រុនចាញ់ ចលនាសហគមន៍ និងការគាំទ្រកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់។

៥. គ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាពរួមបញ្ចូលទាំងប្រពន្ធ័ព័ត៌មានសុខាភិបាលនិងការតាមដានព្រមទាំងការសម្របសម្រួលនានាដែលនឹងនាំឲ្យការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់ មានគុណភាពខ្ពស់ និងទទួលបានជោគជ័យ។

## III. សមិទ្ធិផលការងារកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់ឆ្នាំ២០១១

### ១.សកម្មភាពសំខាន់ៗគាំទ្រដល់ការគ្រប់ដណ្តប់បានទាំងស្រុង១០០ភាគរយ)រោគវិនិច្ឆ័យជំងឺគ្រុនចាញ់ឲ្យបានឆាប់រហ័សនិងការព្យាបាលទាន់ពេលវេលានិងមានប្រសិទ្ធភាពនូវគ្រប់ករណីជំងឺគ្រុនចាញ់រួមទាំងប្រជាជនចល័ត និង ជន ចំណាកស្រុក។

១.១. **សេវាសុខភាពសាធារណៈ**

១.១.១.**វគ្គបណ្តុះបណ្តាលលើការព្យាបាលនិងធ្វើរោគវិនិច្ឆ័យ៖**ការបណ្តុះបណ្តាលមន្ត្រីសុខាភិបាលលើការព្យាបាល (training malaria clinical management) ក្នុងឆ្នាំ២០១១ កន្លងមកនេះ កម្មវិធីគ្រុនចាញ់ខេត្តបានបើកវគ្គបណ្តុះបណ្តាលគ្លីនិកជំងឺគ្រុនចាញ់ជូនដល់មន្ត្រីសុខាភិបាលតាមខេត្តរៀងៗខ្លួនដូចជា ខេត្តកំពតមានសិក្ខាកាមចូលរួម៣៣នាក់,ព្រះវិហារ២៧នាក់,រតនៈគិរី៤៨នាក់,ស្ទឹងត្រែង១០នាក់។

### ១.១.២ វគ្គបណ្តុះបណ្តាលមីក្រូទស្សន៍និងតេស្តរហ័ស៖

ទន្ទឹមនឹងមានបើកវគ្គបណ្តុះបណ្តាលវគ្គគ្លីនិកជំងឺគ្រុនចាញ់ កម្មវិធីគ្រុនចាញ់ខេត្តក៏មានបើកវគ្គបណ្តុះបណ្តាលផ្នែកមីក្រូទស្សន៍ជំងឺគ្រុនចាញ់ជូនដល់មន្ត្រីបំរើការងារខាងមីក្រូទស្សន៍នៅតាម មណ្ឌលសុខភាពនិងស្រុកប្រតិបត្តិចំនួន២៤ខេត្តក្រុងដែលមានសិក្ខាកាមដែលចូលរួមដូចមានរាយ តួលេខក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត | ចំនួនសិក្ខាកាម | ល.រ | ឈ្មោះខេត្ត | ចំនួនសិក្ខាកាម |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ២៥ | ១៣ | ព្រះវិហារ | ២៧ |
| ២ | បាត់ដំបង | ១៧ | ១៤ | ព្រៃវែង | ១៦ |
| ៣ | កំពង់ចាម | ២១ | ១៥ | ពោធិ៍សាត់ | ១៦ |
| ៤ | កំពង់ឆ្នាំង | ៩ | ១៦ | រតនៈគីរី | ៤៦ |
| ៥ | កំពង់ស្ពឺ | ២១ | ១៧ | សៀមរាប | ១៥ |
| ៦ | កំពង់ធំ | ១៤ | ១៨ | សីហនុ | ១២ |
| ៧ | កំពត | ១៤ | ១៩ | ស្ទឹងត្រែង | ១១ |
| ៨ | កណ្តាល | ១៦ | ២០ | ស្វាយរៀង | ១៣ |
| ៩ | កោះកុង | ១៣ | ២១ | តាកែវ | ១៥ |
| ១០ | ក្រចេះ | ៩ | ២២ | ឧត្តរមានជ័យ | ១៩ |
| ១១ | មណ្ឌលគិរី | ២៣ | ២៣ | កែប | ១៥ |
| ១២ | ភ្នំពេញ | ៣៩ | ២៤ | ប៉ៃលិន | ១៤ |
| | | **២២១** | | | **២១៩** |

### ១.១.៤. ការគាំទ្រអភិបាលកិច្ច

មន្ត្រីតាមដាន និងវាយតំលៃ និងក្រុមអភិបាលកិច្ចមកពីមជ្ឈមណ្ឌលជាតិ បានធ្វើការ តាមដាន និងធ្វើការងារអភិបាលកិច្ចទៅកាន់ខេត្តនានាមួយចំនួន។ គោលបំណងគឺដើម្បី ផ្តល់នូវការគាំទ្រឱ្យបានទៀងទាត់ទៅដល់មន្ត្រីគ្រុនចាញ់ខេត្ត ដើម្បីធានាថាកិច្ចអនុវត្តន៍ ការងារគ្រុនចាញ់ដំណើរការសមស្រប ទៅតាមកិច្ចដំណើរការជាគន្លឹះនៅថ្នាក់ខេត្ត និងកំរិតប្រតិបត្តិ ហើយការងារទាំងអស់ត្រូវបានអនុវត្តតាមផែនការ ដែលបានកំណត់។

សកម្មភាពការងារគន្លឹះខាងក្រោម ត្រូវបានអនុវត្តកំឡុងពេលចុះទស្សនៈកិច្ច ៖

- ការជួបជាមួយនាយកមន្ទីរសុខាភិបាលខេត្តនិងមន្ត្រីគ្រុនចាញ់ខេត្តនិងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលពាក់ព័ន្ធ។
- អភិបាល និងតាមដានកិច្ចដំណើរការកម្មវិធីគ្រុនចាញ់ និងសកម្មភាពផ្សេងៗនៅមណ្ឌលសុខភាពណា ដែល នៅក្នុងតំបន់ប្រឈមមុខនឹងជំងឺគ្រុនចាញ់ខ្ពស់ និងមធ្យម។
- ជួយសំរួល និងផ្តល់ប្រឹក្សាដល់មន្ត្រីគ្រុនចាញ់ខេត្ត និងគនេយ្យករ ក្នុងការអនុវត្តកម្មវិធីគ្រុនចាញ់ ដែលបានគ្រោងទុក និងធានាថា ការចាត់ចែងថវិកាសំរាប់ការ អនុវត្តសកម្មភាពនេះ គឺសមស្របទៅតាមទិសដៅ។
- សំរួលដល់មន្ត្រីគ្រុនចាញ់ខេត្ត និងគនេយ្យករ ក្នុងការរៀបចំផែនការតាមដាន និងវាយតំលៃប្រចាំត្រីមាស, ផែនការហិរញ្ញវត្ថុប្រចាំត្រីមាស និងរបាយការណ៍សកម្មភាពប្រចាំខែ។

- ផ្តល់ប្រឹក្សា និងអំណាច ដល់មន្រ្តីគ្រុនចាញ់ ក្នុងការរៀបចំរបាយការណ៍ និងផែនការ ការងារ និងសំណើរ ប្រាក់ចំណាយថវិកាប្រចាំត្រីមាស។
- បង្កើនកិច្ចទំនាក់ទំនងរវាងមជ្ឈមណ្ឌលគ្រុនចាញ់ និងមន្ទីរសុខាភិបាលខេត្ត និង អង្គការនានា ដែលកំពុង អនុវត្តសកម្មភាពលុបបំបាត់ជំងឺគ្រុនចាញ់ និងខេត្តនានា។

បានចុះទៅធ្វើការតាមដាននិងវាយតម្លៃនៅទូទាំង២០ខេត្តនិងស្រុកប្រតិបត្តិចំនួន៣១ ដែលមានជម្ងឺគ្រុនចាញ់រាតត្បាត និងចុះទៅផ្ទាល់ដល់មណ្ឌលសុខភាព ដែលមានអត្រាជម្ងឺ គ្រុនចាញ់ខ្ពស់ចំនួន៨០ដើម្បីធ្វើការតាមដាននិងវាយតម្លៃនិងផ្តល់ការណែនាំក្នុងការអនុវត្ត កម្មវិធីគ្រុនចាញ់។

### ១.៤.៥.ការពិនិត្យគុណភាពកញ្ចក់ឈាមជំងឺគ្រុនចាញ់ (Cross-Checking)

| ល.រ | ខេត្ត | Total Slides # | Sensitivity % | Specificity % | Accuracy % | PPV % | NPV % | False Positive % | False Negative % | False Species% |
|---|---|---|---|---|---|---|---|---|---|---|
| ១ | បាត់ដំបង | 679 | 100 | 100 | 100 | 100 | 100 | 0 | 0 | 0.29 |
| ២ | បន្ទាយមានជ័យ | 40 | 100 | 100 | 100 | 100 | 100 | 0 | 0 | 0 |
| ៣ | ឧត្តរមានជ័យ | 159 | 100 | 100 | 100 | 100 | 100 | 0 | 0 | 0.62 |
| ៤ | ប៉ៃលិន | 325 | 95.08 | 98.52 | 97.23 | 97.47 | 97.08 | 0.92 | 1.84 | 3.38 |
| ៥ | រតនៈគិរី | 425 | 96.18 | 96.25 | 96.23 | 91.97 | 98.26 | 2.58 | 1.17 | 0.94 |
| ៦ | កំពត | 41 | 97.43 | 100 | 97.56 | 100 | 66.66 | 0 | 2.43 | 2.43 |
| ៧ | កំពង់ឆ្នាំង | 71 | 100 | 95 | 98.59 | 98.07 | 100 | 1.40 | 0 | 5.63 |
| មធ្យមភាគ | | 1740 | 98.38 | 98.54 | 98.52 | 98.22 | 94.57 | 0.7 | 0.78 | 1.90 |

### ១.២. សេវាសហគមន៍(VMW):

ការបង្កើតអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ គឺជាវិធីសាស្រ្តមួយដ៏មានប្រសិទ្ធិភាពសម្រាប់ព្យាបាលជម្ងឺគ្រុនចាញ់នៅតាមសហគមន៍ដោយផ្អែកលើការប្រើតេស្តរហ័សនិងព្យាបាលនៅនឹងកន្លែងតាមភូមិដែលមានការចម្លងជម្ងឺគ្រុនចាញ់និងជាផ្នែកមួយក្នុងការចូលរួមចំណែកក្នុងយុទ្ធសាស្រ្តលុបបំបាត់ជម្ងឺគ្រុនចាញ់រយៈពេលយូររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់នៅកម្ពុជា។ប្រទេសកម្ពុជាមាប្រជាជនប្រមាណ១៤,៨៣១,៧៧៧( ការប៉ាន់ស្មានឆ្នាំ២០១១ )ដែលមានប្រជាជនប្រឈមមុខនឹងជំងឺគ្រុចាញ់ ៣.០៤០.០០លាននាក់ក្នុង២០ខេត្តក្នុងចំណោម២៤ខេត្តក្រុងដែលស្ថិតក្នុង៤៥ស្រុកប្រតិបត្តិក្នុចំណោម ៧៧ស្រុកប្រតិបត្តិទូទាំងប្រទេសនិងមណ្ឌលសុខភាព៣១២នៃ៩១៤មណ្ឌលសុខភាពទាំងអស់។

ហូតមកដល់បច្ចុប្បន្ននេះ អ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់សរុបមានចំនួន១៥២៨ភូមិក្នុងប្រទេសកម្ពុជាដែលគ្របដណ្តប់ប្រជាជនងាយរងគ្រោះដោយសារជំងឺគ្រុនចាញ់ច្រើនជាង១លាននាក់ក្នុងខេត្តចំនួន១៧នឹងស្រុកប្រតិបត្តិចំនួន៣៤ មណ្ឌលសុខភាពចំនួន១៥៩។

ក្នុងឆ្នាំ២០១១នេះការផ្តល់សេវាព្យាបាលជំងឺគ្រុនចាញ់ក្នុងសហគមន៍តាមរយៈអ្នកស្ម័គ្រចិត្ត មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានរួមសហការជាមួយដៃគូរ និងមន្ទីរសុខាភិបាល ខេត្ត ស្រុក មណ្ឌលសុខភាពបានអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោមៈ

**ក. ជ្រើសរើសអ្នកស្ម័គ្រចិត្តភូមិថ្មីបន្ថែម**

នាឆ្នាំ២០១១គំពោងអ្នកស្ម័គ្រចិត្តភូមិបានជ្រើសរើសភូមិថ្មីបន្ថែមដែលលក្ខខ័ណ្ឌនៃការជ្រើសរើសភូមិអ្នកស្ម័គ្រចិត្តព្យាបាលគ្រុនចាញ់គឺ ៖

- ភូមិដែលនៅឆ្ងាយជាង៥គីឡូម៉ែត្រឬធ្វើដំណើរលើសពី១ម៉ោងពីមណ្ឌលសុខភាព បុស្តិសុខភាព
- ភូមិដែលទើបបង្កើតថ្មីដែលព័ទ្ធជុំវិញដោយព្រៃ(ភូមិគោលដៅនៃការគ្របដណ្តប់មុង)។
- ភូមិដែលមានករណីជម្ងឺគ្រុនចាញ់កើតឡើងរាយការណ៍ដោយសេវាសាធារណៈភូមិដែលគ្មានអ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិទាក់ទងនឹងជម្ងឺគ្រុនចាញ់។

ក.១.លទ្ធផលនៃការចុះអង្កេតបានចុះពិនិត្យមានចំនួន០៥ខេត្ត ,ចំនួន០៦ ស្រុកប្រតិបត្តិ, មណ្ឌលសុខភាពចំនួន២១និង២៧៦ភូមិ។
ខ.២.លទ្ធផលនៃការជ្រើសរើសភូមិបន្ថែមថ្មីបានចំនួន១២៩ភូមិដែលមាននៅខេត្តចំនួន០៥ (ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ ខេត្តមណ្ឌលគីរី) ស្រុកប្រតិបត្តិចំនួន០៦ និងមណ្ឌល សុខភាពចំនួន១៥។

**ខ.ការបណ្តុះបណ្តាល**

### ខ.១.វគ្គបណ្តុះបណ្តាលអ្នកស្ម្រ័គចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ជ្រើសរើសថ្មីនឹង វគ្គបណ្តុះបណ្តាលវិក្រិត្យការៈ

➢ គោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលអ្នកស្ម្រ័គចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់គឺផ្តោតទៅលើការអនុវត្តផ្ទាល់និងសង្កត់ធ្ងន់លើ៖

- តួនាទីនិងការទទួលខុសត្រូវនៃអ្នកស្ម្រ័គចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់
- ណែនាំអោយស្គាល់រោគសញ្ញាគ្រុនចាញ់ស្រាលនិងគ្រុនចាញ់ធ្ងន់ធ្ងរ
- ការធ្វើរោគវិនិច្ឆ័យដោយប្រើប្រាស់តេស្តរហ័ស
- ការព្យាបាលដោយប្រើថ្នាំកញ្ចប់ACTs
- ការបញ្ជូនករណីជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរនិងផលវិបាក
- ការកត់ត្រានិងធ្វើរបាយការណ៍ជម្ងឺគ្រុនចាញ់ករណីស្លាប់ចំនួនតេស្តនិងថ្នាំបានប្រើ។
- អប់រំសុខភាពស្តីពីការការពារជម្ងឺគ្រុនចាញ់។

➢ លទ្ធផលនៃវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ សរុបចំនួន២៥៨ នាក់ក្នុង១២៩ភូមិ(មានប្រុស០១នាក់និងស្រី១នាក់ក្នុង០១ភូមិ)មកពី១៥មណ្ឌលសុខ

ភាពស្រុកប្រតិបត្តិចំនួន០៦ ខេត្តចំនួ០៥រួមមានខេត្តព្រះវិហារ,បន្ទាយមានជ័យ,កំពង់ស្ពឺ,ឧត្តរមានជ័យ និងមណ្ឌលគិរី។ វគ្គបណ្តុះ បណ្តាលនេះបានត្រួតពិនិត្យនិងតាមដានផ្ទាល់ពីក្រុមការងារផ្នែកអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់ថ្នាក់ជាតិក្នុងពេលរៀបចំការបណ្តុះបណ្តាល។

- កំឡុងពេលនៃការបណ្តុះបណ្តាលចាប់ផ្តើមពីខែឧសភាដល់ខែកក្កដាឆ្នាំ២០១១។
- ទីកន្លែងនៃវគ្គបណ្តុះបណ្តាលគឺខេត្តព្រះវិហារ,បន្ទាយមានជ័យ,ឧត្តរមានជ័យ,កំពង់ស្ពឺ និងមណ្ឌលគិរី។
- រយៈពេលបណ្តុះបណ្តាល៤ថ្ងៃសម្រាប់វគ្គនីមួយៗ។

ទោះបីជា មានវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ នាពេលជ្រើសរើសតំបូង និងមានការណែនាំតាមរយៈការប្រជុំប្រចាំខែក៏ដោយ កម្មវិធីក៏មានផែនការសំរាប់បើកវគ្គបណ្តុះបណ្តាល វិក្រិត្យការអ្នកស្ម័គ្រចិត្តភូមិនិងអ្នកស្ម័គ្រចិត្តចល័តព្យាបាលជម្ងឺគ្រុនចាញ់ជារៀងរាល់២ឆ្នាំម្តងផងដែរ។

- គោលបំណងនៃវគ្គបណ្តុះបណ្តាលគឺផ្តល់និងបង្កើនសមត្ថភាពយល់ដឹងដល់អ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់ដែលបានជ្រើសរើសកន្លងមកស្ថិតក្នុងតំបន់មានភាពស៊ាំទៅនឹងថ្នាំអាតេមីសេនីន។
- កំឡុងពេលនៃវគ្គបណ្តុះបណ្តាលរំលឹកពីខែមេសាដល់ខែមិថុនាឆ្នាំ២០១១សម្រាប់ខេត្តដែលឧត្ថម្ភដោយមូលនិធិសកលជុំទី៦និងពីខែកក្កដាដល់ខែកញ្ញាឆ្នាំ២០១១សម្រាប់ខេត្តដែលឧបត្ថម្ភដោយមូលនិធិសកលជុំទី៩។
- ទីកន្លែងនៃវគ្គបណ្តុះបណ្តាលៈខេត្តគោលដៅនៃគម្រោងអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់។
- រយៈពេលនៃវគ្គបណ្តុះបណ្តាលវិក្រិត្យការមានរយៈពេល២ថ្ងៃ

*ខ.១.១*-ការបណ្តុះបណ្តាលរំលឹកអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់និងអ្នកចល័តសម្រាប់ជុំទី៩ បានចំនួន០៩ខេត្ត(ខេត្តបន្ទាយមានជ័យ,កោះកុង,កំពត,បាត់ដំបង,ពោធិ៍សាត់,ព្រះវិហារ,សៀមរាប,ឧត្តរមានជ័យ,កំពង់ស្ពឺ)ចំនួន៤៣២ភូមិដែលមានសិក្ខាកាមជាអ្នកស្ម័គ្រភូមិព្យាបាលជំងឺគ្រុនចាញ់ចូលរួមរៀនចំនួន៨៦៣នាក់និងអ្នកស្ម័គ្រភូមិព្យាបាលជំងឺគ្រុនចាញ់ចល័តចំនួន១០៨នាក់។

**ខ.១.២** ការបណ្តុះបណ្តាលរំលឹកអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់សម្រាប់ជុំទី៦បានចំនួន១០ខេត្ត (ខេត្ត ព្រះវិហារ,កំពង់ធំ,សៀបរាប,កំពត,កំពង់ស្ពឺ,ព្រះសីហនុ,មណ្ឌលគិរី,ក្រចេះ,ស្ទឹងត្រែង,រតនៈគិរី)ចំនួន៣៨២ភូមិដែល មានសិក្ខាកាមជាអ្នកស្ម័គ្រភូមិព្យាបាលជំងឺគ្រុនចាញ់ចូលរួមរៀនចំនួន៧៦៣នាក់។

**ខ.១.៣** សរុបការបណ្តុះបណ្តាលវិក្រិត្យការទាំងពីរលើកមានចំនួន១៦ខេត្ត ,ក្នុងស្រុកប្រតិបត្តិចំនួន៣៤ សិក្ខាកាមចំនួន១៦២៦ នាក់។

### ខ.២.វគ្គបណ្តុះបណ្តាលផ្ញើសារ( SMS )ដល់អ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ះ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រដោយមានការជួយឧបត្ថម្ភពីក្រុមហ៊ុនទូរស័ព្ទMobitel,InSTEED, MalariaConsortium និងថវិកាឧបត្ថម្ភដោយWHOកម្ពុជា, យើងបានបង្កើត កម្មវិធីសាកល្បងនេះដោយបានចាប់ផ្តើមបើវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ក្នុងខេត្តកំពត,សៀមរាប,កំពង់ចាម(ស្រុកប្រតិបត្តិមេមត់)អំពីរបៀបផ្ញើសារតាម ទូរសព្ទ័ដៃនូវរបាយការណ៍ភ្លាមៗទាន់ពេលលើករណីគ្រុនចាញ់វិជ្ជមាននៅតាមសហគមន៍ពួកគេ។ប្រព័ន្ធព័ត៌មាននេះសម្រាប់អ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់និងបុគ្គលិកមណ្ឌលសុខភាពផ្តល់ជាព័ត៌មានទៅស្រុក,ខេត្តនិងថ្នាក់ជាតិនូវករណីគ្រុនចាញ់ដែលបានធ្វើរោគវិនិច្ឆ័យឃើញវិជ្ជមាន។

ជាលទ្ធផលដែលយើងបានបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តចំនួន១៦៩នាក់និងអ្នកស្ម័គ្រចិត្តចល័តចំនួន១៤នាក់ស្ថិតនៅក្នុងខេត្តចំនួន០៣(ខេត្តកំពត,សៀមរាប,កំពង់ចាម)ស្រុកប្រតិបត្តិចំនួន០៤(មេមត់,អង្គរជុំ,ឈូក,កំពត)មណ្ឌលសុខភាពចំនួន១៥និងភូមិ១៦៩។

ការបណ្តុះបណ្តាលបានប្រព្រឹត្តិនៅខែសីហាដែលរយះពេលនៃការបណ្តុះបណ្តាលមួយវគ្គគឺមានរយះពេល១ថ្ងៃដោយបង្រៀនទាំងទ្រឹស្តីនិងការអនុវត្តន៍ជាក់ស្តែង។

## គ.ការប្រជុំរបស់តំណាងអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់

### គ.១.ការប្រជុំប្រចាំខែ

បុគ្គលិកមណ្ឌលសុខភាពបានកំណត់កាលបរិច្ឆេទប្រជុំប្រចាំខែសម្រាប់អ្នកស្ម័គ្រចិត្តនិងអ្នកចល័តម្តងក្នុង១ខែម្តង។កំឡុងពេលប្រជុំបានត្រួតពិនិត្យមើលៈ

- លទ្ធផលតេស្តដែលបានធ្វើ
- ថ្នាំដែលបានផ្តល់ឱ្យអ្នកជម្ងឺ
- ចំនួនអ្នកជម្ងឺដែលបានកត់ត្រា
- ចំនួនសរុបនៃតេស្តរហ័សនិងថ្នាំដែលបានប្រើប្រាស់
- ពិនិត្យថ្ងៃខែឆ្នាំកំណត់ឱ្យប្រើប្រាស់នៅលើប្រអប់ថ្នាំនិងតេស្តនិងផ្តល់ថ្នាំឬតេស្តឱ្យតាមជាក់ស្តែង។

ទិន្នន័យទទួលបានត្រូវបានបញ្ចូលតាមប្រព័ន្ធព័ត៌មានគ្រុនចាញ់ដោយបុគ្គលិកស្រុកប្រតិបត្តិ ដែលបានបណ្តុះបណ្តាលកន្លងមកនិងផ្ញើរទិន្នន័យទៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់នៅពេលបញ្ចូលចប់តាម ប្រព័ន្ធអ៊ីម៉ែល។

ក្រៅពីជម្ងឺគ្រុនចាញ់ដែលបានព្យាបាលអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់ក៏បានព្យាបាលជម្ងឺរលាកសួត,រាគ,គ្រុនក្តៅសម្រាប់កុមារអាយុក្រោម៥ឆ្នាំនៅភូមិចំនួន៤០០ភូមិក្នុងខេត្តចំនួន៧។

ទិន្នន័យ ទាំងអស់នេះត្រូវបានប្រមូលយ៉ាងទៀងទាត់នៅពេលប្រជុំប្រចាំខែ។

➢ តារាង១ការធ្វើតេស្តរកមេរោគគ្រុនចាញ់និងព្យាបាលដោយ VMW២០១១ឆ្នាំ,

| ចំនួនភូមិ | ប្រជាជនសរុប | សរុបតេស្តបានប្រើ | ករណីវិជ្ជមានសរុប | ករណីគ្រុនចាញ់ស្លាប់ | អត្រាអាំងស៊ីដង់ (១,០០០) | អត្រាស្លាប់ (១០,០០០) |
|---|---|---|---|---|---|---|
| ១៥២៨ | ១០៨២៩៧១ | ១៣៨០៧០ | ៤៨៧៥០ | ២ | ៤៥,០១ | ០.០២ |

➢ តារាង២,ជម្ងឺរលាកសួត,រាគ,គ្រុនក្តៅមិនមែនគ្រុនចាញ់លើកុមារអាយុក្រោម៥ឆ្នាំក្នុង៤០០ភូមិ២០១១ឆ្នាំ,

| ខេត្តចំនួន១០ | សង្ស័យរលាកផ្លូវដង្ហើម | ជម្ងឺរាគ | គ្រុនក្តៅ(មិនមែនគ្រុនចាញ់) |
|---|---|---|---|
| ៤០០ភូមិ | ៤,២៣៣ ករណី | ៤,៤៥២ ករណី | ៧,០២៣ ករណី |

➢ ក្រាភិចបង្ហាញពីអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ក្នុងចំណោមភូមិគ្របដណ្តប់ដោយ VMW២០១១ឆ្នាំ,




➢ **ការសង្ខេបលទ្ធផលទិន្នន័យរបស់ VMWឆ្នាំ២០១១៖**

- ក្នុងកំឡុងពេលខែមករាដល់ខែធ្នូឆ្នាំ២០១១អ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់បានពិនិត្យ ជម្ងឺគ្រុនចាញ់បាន១៣៨,០៧០នាក់,វិជ្ជមានគ្រុនចាញ់៤៨,៧៥០នាក់,ស្លាប់ដោយសារគ្រុនចាញ់ចំនួន២នាក់។នៅពេលធ្វើការប្រៀបធៀបទៅនឹងឆ្នាំ២០១០ឃើញថាមានការពិនិត្យអ្នកជំងឺដោយតេស្តរហ័សនឹងកណីតេស្តវិជ្ជមានមានការកើនឡើងបន្តិចដែលឆ្នាំ២០១០ការពិនិត្យជម្ងឺបាន១៣២,៩១០នាក់,វិជ្ជមាន៤៧,២២២នាក់,និងស្លាប់៣នាក់។
- ជាមធ្យមក្នុងមួយខែអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់តាមភូមិនីមួយៗបានពិនិត្យជម្ងឺបាន៣១នាក់ក្នុងឆ្នាំ២០១១និង៣៤នាក់ក្នុងឆ្នាំ២០១០។
- ចំនួនតេស្តដែលបានធ្វើរោគវិនិច្ឆ័យនិងតេស្តវិជ្ជមានក្នុងឆ្នាំ២០១១មានការកើនឡើងបើប្រៀបធៀបទៅនឹងឆ្នាំ២០១០

- ទោះបីជាយ៉ាងណាក៏ដោយអ្នកស្លាប់ដោយសារជម្ងឺគ្រុនចាញ់មានការធ្លាក់ចុះពី៣ករណីនៅឆ្នាំ២០១០មកត្រឹម២ករណីក្នុងឆ្នាំ២០១១។
- អត្រាជម្ងឺកើតថ្មីដែលប្រមូលបានពីអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់(១៥២០ភូមិ)មានការថយចុះបន្តិចបន្តួច គឺ៤៥,២៧ក្នុង១០០០នាក់នៅឆ្នាំ២០១០នឹង៤៥,០១ក្នុង១០០០នាក់នៅឆ្នាំ២០១១។ក៏ប៉ុន្តែបើយើងប្រៀបធៀបអត្រាឈឺប្រមូលបានដោយអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់ក្នុងឆ្នាំ២០០៤គឺមាន១៧០ក្នុង១០០០នាក់និងក្នុងឆ្នាំ២០០៦គឺ៣៤៨ក្នុង១០០០នាក់ក្នុងចំណោម៣០០ភូមិនៃអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់។
- ក្នុងឆ្នាំ២០១១,អ្នកវិជ្ជមានមេរោគគ្រុនចាញ់បែងចែកទៅតាមក្រុមអាយុ,ក្រុមបុរសពេញវ័យ១៥ ដល់ ៤៩ឆ្នាំ មាន៥០%និងក្រុមអាយុកុមារពី៥ដល់១៤ឆ្នាំគេសង្កេតឃើញមាន២២%និង១៦%ជាក្រុមស្ត្រីអាយុ ពី១៥ដល់៤៩ឆ្នាំ,បន្ទាប់មកឃើញមាន៧%កើតលើក្រុមកុមារអាយុចន្លោះ០ដល់៤ឆ្នាំនិង៣%កើតលើក្រុមអាយុលើសពី៤៩ឆ្នាំជាបុរសនិង២%ក្រុមអាយុលើសពី៤៩ឆ្នាំជាស្ត្រី។
- ក្នុងឆ្នាំ២០១១,គេសង្កេតឃើញថាអត្រាមេរោគហ្វាល់ស៊ីប៉ារ៉ូមនិងវីវ៉ាក់ក្នុងចំណោមតេស្តវិជ្ជមានទាំងអស់១៤%ហ្វាល់ស៊ីប៉ារ៉ូម,៤៤%វីវ៉ាក់និង៤២%ចំរុះ។ចំណែកឯឆ្នាំ២០១០វិញគេសង្កេតឃើញតេស្តវិជ្ជមាន១៧%ហ្វាល់ស៊ីប៉ារ៉ូម,៤០%វីវ៉ាក់និង៤៣%ចំរុះ។
- អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់នៅភូមិអ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់គឺ០.០២ក្នុង១០០០០នាក់នៅឆ្នាំ២០១១និង០.០៣ក្នុង១០០០០នាក់នៅឆ្នាំ២០១០ ខណៈពេលដែលអត្រាឆ្លងថ្មីមានការថយចុះពី៤៥.២៥មក៤៥.០១ក្នុង១០០០នាក់នៅឆ្នាំ២០១១និង២០១០។

### ឃ/ការប្រជុំប្រចាំឆ្នាំនៃគម្រោងអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់៖

- ថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០១១ គម្រោងអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់បានរៀបចំការប្រជុំប្រចាំឆ្នាំដែលមានការចូលរួមពីមន្ត្រីថ្នាក់ខេត្ត,ស្រុកប្រតិបត្តិនិងមណ្ឌលសុខភាពដែលធ្វើការជាមួយកម្មវិធីអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់។
- ការប្រជុំនេះក្នុងគោលបំណងចែករំលែកនូវបទពិសោធន៍និងលើកឡើងបញ្ហាដែលកើតមានឡើងនៅតាមសហគមន៍និងដើម្បីយកមកដោះស្រាយទាំងអស់គ្នាស្វែងរកភាពរីកចំរើននាឆ្នាំខាងមុខ។
- មានអ្នកចូលរួមចំនួន១២៥នាក់(រួមបញ្ចូលទាំងមន្ត្រីកម្មវិធីគ្រុនចាញ់ខេត្តនិងមន្ត្រីទទួលបន្ទុកសម្របសម្រួលក្នុងនោះ (មន្ត្រីមកពីមជ្ឈមណ្ឌលជាតិចំនួន៩នាក់,ប្រធានកម្មវិធីគ្រុនចាញ់ខេត្តនិងមន្ត្រីគ្រុនចាញ់ចំនួន៣៤នាក់,មន្ត្រីស្រុកប្រតិបត្តិ ចំនួន៥២នាក់និងមណ្ឌលសុខភាពចំនួន៣០នាក់។

### ង/.**ការអភិបាល**

ការចុះអភិបាលការងារប្រព្រឹត្តិទៅដោយមានបុគ្គលិកចូលរួមគ្រប់កំរិតពីថ្នាក់ជាតិ ដល់មណ្ឌលសុខភាពគឺជម្រុញការអនុវត្តផ្ទាល់ឱ្យមានប្រសិទ្ធភាព,កត់សម្គាល់នូវបញ្ហានិងជួយដោះស្រាយបញ្ហាចំពោះមុខផ្សេងៗដែលកើតមានឡើង។លទ្ធផលនៃការចុះអភិបាលៈ

- ការចុះអភិបាលប្រព្រឹត្តទៅ២ដងក្នុងមួយឆ្នាំ,មានចំនួន០៨ខេត្តដែលមានរាយនាមដូចជា៖ ខេត្តរតនៈគិរី,មណ្ឌលគិរី,ស្ទឹងត្រែង,ក្រចេះ,ព្រះសីហនុកំពង់ធំ,,កំពង់ស្ពឺ,សៀមរាបដែលឧបត្ថម្ភដោយគម្រោងមូលនិធិសកលជុំទី៦។

➢ គម្រោងដែលឧបត្ថម្ភដោយមូលនិធិសកលជុំទី៩ការចុះអភិបាលរៀងរាល់៣ខែម្តងនៅចំនួន១១ខេត្តៈមានខេត្តបាត់ដំបង,បន្ទាយមានជ័យ,ឧត្តរមានជ័យ,ព្រះវិហារ,សៀមរាប,កំពត,កោះកុង,ពោធិ៍សាត់,កំពង់ធំ,កំពង់ចាម និង ខេត្តកំពង់ស្ពឺ។

## ១.៣. សេវាឯកជនៈ

ការផ្តល់សេវាធ្វើរោគវិនិច្ឆ័យនិងព្យាបាលនៅសេវាឯកជនជាយុទ្ធសាស្ត្រនេះមួយ ដែលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានផ្តោតការយកចិត្តទុកដាក់សហការជាមួយអ្នកផ្តល់សេវានៅផ្នែកឯកជនដែលក្នុងនោះមានអង្គការជាដៃគូរ(PSI),មន្ទីរសុខាភិបាលខេត្ត,ស្រុក មណ្ឌលសុខភាពបានអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

### ១.៣.១.ភាពជាដៃគូរវាងអ្នកផ្តល់សេវាសាធារណៈ និងឯកជន (Public-Private Mix Approach)

➢ <u>សារបាននិងការពង្រឹងរចនាសម្ព័ន្ធ</u>

តាមរបាយការណ៏អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥និង២០១០អ្នកជំងឺដែលទៅរកសេវាជាជំរើសដំបូងដោយទៅទិញថ្នាំតាមតូប/ផ្ទះឬរកសេវាដែលគ្មានវិជ្ជាជីវៈបានថយចុះពី២១,៦%នាឆ្នាំ២០០៥មកនៅត្រឹម៥,៩%នាឆ្នាំ២០១០។ក៏ប៉ុន្តែអ្នកជំងឺនៅជនបទជំរើសដំបូងដោយទៅរកសេវាឯកជនដែលមានវិជ្ជាជីវៈបានកើនពី៤៦,៧%នាឆ្នាំ ២០០៥ទៅដល់៥៥,៥%នាឆ្នាំ២០១០ ហេតុនេះហើយបានជាភាពជាដៃគូរសេវាសាធារណៈនិងឯកជនរួមគ្នាប្រយុទ្ធនឹងជំងឺគ្រុនចាញ់មានចែងច្រើនគួរសមនៅក្នុងផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០១១-២០២៥របស់រាជរដ្ឋាភិបាល។តាមសំណើរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្របាណកសាស្ត្រក្រសួងសុខាភិបាលបានកែសំរួលជាថ្មី (ថ្ងៃទី៦ខែកក្កដាឆ្នាំ២០១១)នូវសមាសភាពអនុគណៈកម្មការបច្ចេកទេសភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (Sub-Technical Working Group on Public Private Partnership: Sub-TWG PPP) អោយមានអនុរដ្ឋលេខាធិការមួយរូបជាប្រធាននិងបានបន្ថែម អនុប្រធាន១រូបរបស់ CNM ជាសមាជិក។លក្ខណ៏យោង (TOR) របស់អនុគណៈកម្មការនេះបានបញ្ជាក់ថាវិស័យឯកជនរួមមានទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ហើយសមាសភាពថ្មីនេះបានកោះប្រជុំលើកទី១ដែលផ្តោតតែលើភាពជាដៃគូរសេវាសាធារណៈនិងឯកជនរួមគ្នាប្រយុទ្ធនឹងជំងឺគ្រុនចាញ់។ នៅចុងឆ្នាំ២០១១ CNM បានពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងអង្គភាពដោយបង្កើតឱ្យមានផ្នែកដៃគូរសេវាសាធារណៈនិងឯកជនរួមគ្នាប្រយុទ្ធនឹងជំងឺគ្រុនចាញ់ (PPM Unit) ដោយចាត់តាំងមន្ត្រី១រូបទទួលខុសត្រូវដឹកនាំផ្ទាល់និងស្ថិតនៅក្រោមឱវាទការិយាល័យបច្ចេកទេស។

➢ <u>ទិសដៅនៃយុទ្ធសាស្ត្រ</u>

ភាពជាដៃគូរវាងសេវាសាធារណៈនិងសេវាឯកជនគឺគាំទ្រដល់សកម្មភាពទប់ស្កាត់ការរីករាលដាលនូវភាពសាំនៃមេរោគគ្រុនចាញ់ទៅនឹងឱសថអាតេមីស៊ីនីនតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការធ្វើរោគវិនិច្ឆ័យការបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យការផ្លាស់ប្តូរឥរិយាបទនៃការចេញវេជ្ជបញ្ជាព្រមទាំងបង្កើនការតាមដាននិងគ្រប់គ្រងទិន្នន័យនៃអ្នកជំងឺគ្រុនចាញ់ដែលទៅរកសេវាឯកជនក្នុងគោលបំណងៈ

- ធានាថាមុងដែលបានផ្សព្វផ្សាយលក់និងមុងអង្រឹងត្រូវបានជ្រលក់ថ្នាំនិងសហការជានិយោជកដើម្បីធានាបង្កើនអត្រាប្រើប្រាស់មុង។
- បង្កើនការផ្លាះប្តូរឥរិយាបថក្នុងកាកោរពារនិងព្យាបាលជម្ងឺគ្រុនចាញ់។

- មិនមានវត្តមានឱសថក្លែងក្លាយនិងឱសថម៉ូណូតេរ៉ាពីនៅលើទីផ្សារឯកជន។
- អ្នកជំងឺគ្រប់រូបនឹងទទួលបានការធ្វើរោគវិនិច្ឆ័យដ៏ត្រឹមត្រូវ។
- អ្នកជំងឺគ្រប់រូបនឹងទទួលបានឱសថដ៏ត្រឹមត្រូវនិងគ្រប់គ្រាន់។
- អ្នកជំងឺនឹងត្រូវបានបញ្ជូនដោយផ្អែកតាមគោលនយោបាយជាតិ (អ្នកជំងឺដែលមានស្ថានភាពធ្ងន់ អ្នកជំងឺដែលលាប់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៥ឆ្នាំ)។
- តាមដាននិងប្រមូលឱ្យបានទៀងទាត់នូវទិន្នន័យនៃអ្នកជំងឺគ្រុនចាញ់ដែលទៅរកសេវាឯកជន។

## ➢ <u>សមិទ្ធិផលការងារកន្លងមកៈ</u>

**ក**-ដោយលក្ខណ៍យោង (TOR) របស់អនុគណៈកម្មការបច្ចេកទេសភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជនបានបញ្ជាក់ថាវិស័យឯកជនរួមមានទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរនោះ ការ អនុវត្តន៍អនុសរណៈយោគយល់គ្នារវាងCNMនិងអង្គការមិនមែនរដ្ឋាភិបាលចំនួន៤ ដើម្បីប្រើប្រាស់ថវិកាមូលនិធិសកលជុំទី៩ជំហានទី១សរុប១៧លានសែនដុល្លារត្រូវបានរំលេចក្នុងរបាយការណ៍នេះថាជាផ្នែកមួយនៃភាពជោគជ័យរវាងវិស័យសាធារណះនិងឯកជនដែរ។អង្គការមិនមែនរដ្ឋាភិបាចំនួន៤នោះមានគឺPSI(8.2 million $); MC(4.0 million$); PFD (2.3 million $); and HU/PHA(1.3 million $)។ ដោយអង្គការMCបានចុះកិច្ចសន្យាបន្តឱយអង្គការចំនួន៥ទៀតគឺFHI; BBC; IPC; WMC; and AMDAHLចំនួនអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមអនុវត្តPPMមាន៩អង្គការ។

**ខ**-តាមរយៈអនុសរណៈយោគយល់គ្នាខាងលើ PSI ធ្វើការចែកចាយឱសថនិងប្រតិករគ្រុនចាញ់និងថ្នាំជ្រលក់មុងនៅវិស័យឯកជន។ថវិកាចែកចាយផ្សព្វផ្សាយនិងទិញថ្នាំជ្រលក់មុងឱសថព្យាលនិងសំភារៈ/ប្រតិករធ្វើរោគវិនិច្ឆ័យនិងព្យាបាលគ្រុនចាញ់ជាថវិកាក្នុងកិច្ចសន្យាដូចបានជំរាបខាងលើសរុប៨.២លានសំរាប់រយៈពេល៣៦ ខែចាប់ ពី ខែកក្កដាឆ្នាំ២០១០ទៅក៏ប៉ុន្តែថវិកាអនុវត្តន៍មកដល់ចុងឆ្នាំ២០១១នេះបានតែ២លាន២សែនប៉ុណ្ណោះ។

**គ**-តាមរយៈអនុសរណៈយោគយល់គ្នាខាងលើអង្គការ MC/FHI to improve communication and collaborationwith private farm/mine owner and dwellers to fight against malaria in Pailin

**ឃ** -ដោយមានជំនួយបច្ចេកទេសពីអង្គការ CHAI (Clinton Health Access Initiative) មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្របាណកសាស្ត្របានសហការជាមួយអង្គការ PATH ការសាកល្បងកិច្ចសន្យារវាងវិស័យសារជារណៈនិងឯកជន (វេជ្ជសាស្ត្រនិងឱសថសាស្ត្រ)នៅស្រុកប្រតិបត្តិចំនួន៦គឺ *ឈូក,បានលុង,បាត់ដំបង,សំពៅលូន,អូរជ្រៅ,និងសូត្រនិគម*មានតំណាងផ្នែកឯកជនសរុបចំនួន៤១០កន្លែងបានចុះកិច្ចសន្យាជួលរួមសហការក្នុងនោះមានឱសថស្ថាន៦៩កន្លែងឱសថស្ថានរង៦២កន្លែងគ្លីនីក៦៤កន្លែងនិងបន្ទប់ពិគ្រោះព្យាបាល២៣៥កន្លែង។ CNM កំពុងរៀបចំធ្វើកិច្ចសន្យាបន្ថែម៤ស្រុកប្រតិបត្តិទៀតគឺធ្លូងស្ទឹងសែនត្បែងមានជ័យចំការលើ។

ក្រោយពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងCNMជាមួយការិយាល័យ ស្រុកប្រតិបត្តិនីមួយៗ ដោយមានតំណាងអាជ្ញាធរខេត្តនិងមន្ទីរសុខាភិបាលខេត្តចុះហត្ថលេខាជាសាក្សីនោះតំណាងអ្នកគ្រប់គ្រងសេវាសុខាភិបាលឯកជនស្របច្បាប់និមួយៗ ។ សេវាវេជ្ជសាស្ត្រឬឱសថសាស្ត្រឬមន្ទីរពិសោធន៏ក្នុងស្រុកប្រតិបត្តិទាំងនោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយលោកប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជាបន្តបន្ទាប់ដែលក្នុងកិច្ចសន្យានេះទាមទារអ្នកគ្រប់គ្រងសេវាសុខាភិបាលឯកជនគោរពនិងអនុវត្តឱ្យបានទៅតាមគោលបំណងរបស់កម្មវិធីដូចខាងក្រោមៈ

1. ទប់ស្កាត់មិនមានវត្តមានឱសថក្លែងក្លាយនិងឱសថម៉ូណូតេរ៉ាពីនៅលើទីផ្សារឯកជន
2. ផ្តល់ដល់អ្នកជំងឺគ្រប់រូបឱ្យទទួលបានការធ្វើរោគវិនិច្ឆ័យដ៏ត្រឹមត្រូវ
3. ផ្តល់ដល់អ្នកជំងឺគ្រប់រូបឱ្យទទួលបាននូវឱសថដ៏ត្រឹមត្រូវនិងគ្រប់គ្រាន់ក្នុងតំលៃថោក
4. អ្នកជំងឺដែលមានសភាពធ្ងន់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៥ឆ្នាំនឹងត្រូវបានបញ្ជូនទៅកាន់សេវាសាធារណៈតាមគោលនយោបាយជាតិ ប្រមូលឱ្យបានទៀងទាត់នូវទិន្នន័យនៃអ្នកជំងឺ គ្រុនចាញ់ដែលទៅរកសេវាឯកជន។

ចំណែកការិយាល័យសុខាភិបាលស្រុកត្រូវត្រូវសហការជាមួយវិស័យពាក់ព័ន្ធដើម្បីផ្តល់ការបណ្តុះបណ្តាលស្តីពីតួនាទីរបស់វិស័យឯកជននៅក្នុងការធ្វើរោគវិនិច្ឆ័យការព្យាបាល និងការបញ្ជូនជំងឺគ្រុនចាញ់ហើយត្រូវដឹកនាំធ្វើទស្សនៈកិច្ចត្រួតពិនិត្យតាមដាននិងគាំទ្រជាទៀងទាត់ដើម្បីអប់រំជូនដំណឹងនិងលើកទឹកចិត្តចំពោះអ្នកផ្តល់សេវា ឯកជនទាំងនោះ។

**១.៣.២.ទីផ្សារសង្គមលើឱសថគ្រុនចាញ់ និងការធ្វើរោគវិនិច្ឆ័យ ( Social Marketing on Malaria Case Management )៖**

កម្មវិធីគ្រុនចាញ់របស់អង្គការ ភី អេស អាយ កម្ពុជាប្រតិបត្តិការនៅទូទាំងប្រទេស រួមមានៈ

1. **កម្មវិធីបង្ការៈ** ដើម្បីជានាអោយក្រុមគ្រួសារអោចជ្រលក់មុងរបស់ពួកគេ។ កម្មវិធីបានប្រែក្លាយមុងធម្មតាជិត១លានមុង ឲ្យទៅជាមុងជ្រលក់ថ្នាំមានប្រសិទ្ធភាពជារៀងរាល់ឆ្នាំ។
2. **រោគវិនិច្ឆ័យៈ** រួមមានការបណ្តុះបណ្តាល ចែកចាយសំភារៈតេស្តឈាម និងធានាឲ្យមានការធ្វើតេស្តឈាមមុនការព្យាបាល។
3. **ការព្យាបាលៈ** រួមមានការបណ្តុះបណ្តាល ការចែកចាយឱសថដែលមានគុណភាព និងការផ្សព្វផ្សាយដើម្បីជំរុញឲ្យមានការផ្តល់ឱសថព្យាបាលត្រឹមត្រូវ តាមក្រុមអាយុអ្នកជំងឺដែលបានកំណត់។

កម្មវិធីគ្រុនចាញ់របស់អង្គការ ភី អេស អាយ ទទួលបានការគាំទ្រពីមូលនិធិសកល។ ការសិក្សាស្រាវជ្រាវ ACTwatch ទទួលបានមូលនិធិពី The Bill and Melinda Gates Foundation ។

## ១.តើអ្វីជា ទីផ្សារសង្គម?

ទីផ្សារសង្គម គឺជាកញ្ចប់នៃសកម្មភាពដែលគិតគូរបានគ្រប់ជ្រុងជ្រោយ ដូចជា ១. គុណភាពខ្ពស់នៃផលិតផល ផលិតផលដែលចែកចាយដោយវិស័យឯកជនមានតំលៃសមរម្យនិងទទួលស្គាល់ដោយក្រសួងសុខាភិបាល ២. ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវាកម្មតាមរយៈវគ្គបណ្តុះបណ្តាល និងសំភារៈគាំទ្រ ៣. ការទំនាក់ទំនងជាមួយអតិថិជនតាមរយៈការងារនៅកំរិតសហគមន៍ ឧទាហរណ៍ ការបញ្ចាំងវីដេអូចល័ត យុទ្ធនាការផ្សព្វផ្សាយសាធារណៈដូចជា ទូរទស្សន៍ វិទ្យុ ផ្ទាំងប៉ាណូ ៤. ការធ្វើការស្រាវជ្រាវដើម្បីឲ្យប្រាកដថាយើងធ្វើផ្លាស់ប្តូរឥរិយាបថបានត្រឹមត្រូវ និងដោះស្រាយគ្រប់ឧបសគ្គបានត្រឹមត្រូវ ដើម្បីធ្វើអោយប្រជាពលរដ្ឋប្រកាន់ឥរិយាបថប្រកបដោយសុខុមាលភាព។

## ២.ACT និង RDTs - ប្រើប្រាស់យុទ្ធសាស្រ្តទីផ្សារសង្គម

ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជា មានសារៈសំខាន់បំផុត មិនមែនសំរាប់តែសុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែសំរាប់ការទប់ស្កាត់ភាពរីកសាយនៃភាពស៊ាំនៃថ្នាំអាតេមីស៊ីនីន។

ភី អេស អាយ ជាអង្គការតែមួយគត់ដែលអនុវត្តកម្មវិធីនូវទូទាំងប្រទេសគាំទ្រមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដើម្បីឲ្យប្រាកដថាអ្នកផ្តល់សេវាឯកជនទាំងអស់ ស្តុកឱសថនិងសំភារៈតេស្តឈាមរកមេរោគគ្រុនចាញ់មានគុណភាពខ្ពស់ ហើយទទួលស្គាល់ដោយក្រសួងសុខាភិបាល។ ខាងក្រោមនេះ គឺជាតួលេខនៃឱសថនិងសំភារៈតេស្តឈាមរកមេរោគគ្រុនចាញ់ដែលចែកចាយ ដោយអង្គការ ភី អេស អាយ កន្លងមក។

## តារាង១៖ ការចែកចាយ ACT (ម៉ាឡារីន)

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិការ | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2003 | - | 2,031 | 4,015 | 2 | 7,075 | 3 | 1,030 | 3,547 | 2,040 | 2,749 | 2,015 | 5,735 | 30,242 |
| 2004 | 20 | 75 | 53 | 48 | - | - | - | 12 | 38,196 | 27,756 | 20,868 | 2,712 | 89,740 |
| 2005 | 3,180 | 2,232 | 2,796 | 1,248 | 1,476 | 25,104 | 25,920 | 20,928 | 21,948 | 12,672 | 32,904 | 44,808 | 195,216 |
| 2006 | 16,416 | 12,000 | 8,604 | 3,996 | 18,192 | 18,924 | 35,272 | 39,293 | 8,664 | 7,860 | 33,648 | 39,067 | 241,936 |
| 2007 | 31,584 | 17,987 | 14,160 | 10,175 | 8,448 | 13,596 | 17,328 | 14,974 | 18,060 | 9,720 | 5,676 | 656 | 162,364 |
| 2008 | 660 | 816 | 3,938 | 29,138 | 25,829 | 26,448 | 13,296 | 9,612 | 2,748 | 19,020 | 31,427 | 19,401 | 182,333 |
| 2009 | 38,892 | 24,396 | 7,788 | 10,832 | 1,308 | 47,364 | 26,040 | 25,524 | 23,844 | 30,336 | 26,456 | 18,336 | 281,116 |
| 2010 | 2,148 | 10,968 | 11,640 | 15,840 | 3,396 | 6,564 | 5,892 | 14,928 | 14,556 | 11,338 | 17,832 | 25,140 | 140,292 |
| 2011 | 16,476 | 16,392 | 12,936 | 8,364 | 5,652 | 3,240 | 600 | 384 | 216 | - | - | - | 64,260 |
| | | | | | | | | | | | | សរុប | 1,387,499 |

## តារាង2៖ ការចែកចាយ RDT (ម៉ាឡាឆែក)

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិការ | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2003 | - | 20,020 | 1,040 | 20 | 50,060 | 10 | 10,020 | 10,020 | - | 56,002 | 12 | 25 | 147,229 |
| 2004 | 20 | 6,080 | 20 | 50 | 100 | 50 | 1,200 | 32,480 | 3,790 | 22,220 | 20,980 | 13,540 | 100,530 |
| 2005 | 17,080 | 16,170 | 11,500 | 30,450 | 32,150 | 35,040 | 33,980 | 24,410 | 12,860 | 24,510 | 26,090 | 21,380 | 285,620 |
| 2006 | 12,220 | 6,500 | 7,220 | 5,130 | 18,110 | 16,460 | 27,000 | 37,600 | 13,540 | 19,560 | 39,240 | 32,650 | 235,230 |
| 2007 | 21,980 | 13,290 | 20,500 | 4,310 | 11,460 | 19,310 | 39,270 | 31,750 | 67,730 | 48,090 | 25,280 | 19,200 | 322,170 |
| 2008 | 7,460 | 2,000 | 370 | - | - | - | - | - | - | - | - | 119,580 | 129,410 |
| 2009 | 40,070 | 34,270 | 28,460 | 18,000 | 27,000 | 67,750 | 41,900 | 38,450 | 48,770 | 23,470 | 2,280 | - | 370,420 |
| 2010 | | | 31,000 | 54,100 | 39,990 | 43,940 | 35,240 | 48,550 | 54,420 | 44,100 | 81,110 | 88,010 | 520,460 |
| 2011 | 51,680 | 15,850 | 16,310 | 4,260 | 2,080 | - | - | - | - | - | - | - | 92,560 |
| | | | | | | | | | | | | សរុប | 2,203,629 |

សំរាប់ឆ្នាំ២០១១ តួលេខបង្ហាញថា ឱសថ ACT និង RDT មានការខ្វះខាតស្តុកយ៉ាងធ្ងន់ធ្ងរ ចាប់តាំងពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ (CNM) ផ្ទេរកម្មវិធីទីផ្សារសង្គមផ្នែកជំងឺគ្រុនចាញ់មកអោយអង្គការ ភី អេស អាយ គ្រប់គ្រងនៅឆ្នាំ ២០០២។ ចាប់ពីខែមេសា រហូតដល់ខែធ្នូ ឆ្នាំ២០១១ (១០ខែ) អង្គការ ភី អេស អាយ ដាច់ស្តុកនៃផលិតផលទាំងពីរប្រភេទ ហេតុដូច្នេះហើយបានជា អង្គការ ភី អេស អាយ ចែកចាយឱសថ ACTs បានត្រឹមតែ 64,260 និង សំភារៈតេស្តឈាម RDTs បានត្រឹមតែ 92,560 ក្នុងឆ្នាំ២០១១។

## ៣. វគ្គបណ្តុះបណ្តាលពីការធ្វើរោគវិនិច្ឆ័យរហ័ស និងព្យាបាលជំងឺគ្រុនចាញ់ស្រាល

វគ្គបណ្តុះបណ្តាលអំពី ការធ្វើរោគវិនិច្ឆ័យរហ័ស និង ព្យាបាលជំងឺគ្រុនចាញ់ស្រាលរបស់ អង្គការ ភី អេស អាយ គឺជាការបណ្តុះបណ្តាលបន្ថែមចំណេះដឹង ដែលមានរយៈពេលមួយថ្ងៃ សំរាប់អ្នកផ្តល់សេវាសុខភាពឯកជន។ វគ្គបណ្តុះបណ្តាលនេះ បានចាប់ផ្តើមនៅឆ្នាំ២០០៤ មានគោលបំណងផ្លាស់ប្តូរឥរិយាបថ អ្នកផ្តល់សេវាឯកជន និងបង្កើនចំណេះដឹងទាក់ទងនឹងការព្យាបាលជំងឺគ្រុនចាញ់។

នៅក្នុងឆ្នាំ២០១១នេះ អង្គការ ភី អេស អាយ បានបណ្តុះបណ្តាលអ្នកផ្តល់សេវាឯកជន ចំនួន ២.២២៨នាក់ ក្នុងខេត្តចំនួន១៦ ដែលជាតំបន់គ្រុនចាញ់ និង និស្សិតគិលានុប្បដ្ឋាក-ឆ្មប នៃសាលាសុខាភិបាលភូមិភាគទាំង៥ ចំនួន ៩២៣នាក់អង្គការ ភី អេស អាយ តែងធ្វើការសហការយ៉ាងជិតស្និតជាមួយមន្ទីរសុខាភិបាលខេត្ត ជាពិសេស ជាមួយបុគ្គលិកកម្មវិធីគ្រុនចាញ់ខេត្ត ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនេះ ដូចជា ការចុះជ្រើសរើសនិងអញ្ជើញអ្នកចូលរួម ក្នុងអំឡុងពេល ១សប្តាហ៍មុនពេលបើកវគ្គ និងជួយសម្របសម្រួលក្នុងការបណ្តុះបណ្តាល។

## ៤. កម្មវិធីអប់រំវេជ្ជសាស្ត្រ

អង្គការ ភី អេស អាយ បានបញ្ចូលជំងឺគ្រុនចាញ់ក្នុងកម្មវិធីអប់រំវេជ្ជសាស្ត្រនៅឆ្នាំ២០០៦ ដែលកម្មវិធីនេះបញ្ជាក់ថាជាគំរូដ៏មានប្រសិទ្ធភាពខ្ពស់ សំរាប់អ្នកផ្តល់សេវាសុខភាពឯកជន នៅទូទាំងប្រទេស។

ក្រុមការងារអប់រំវេជ្ជសាស្ត្រ ទាំងអស់សុទ្ធតែបានទទួលការបណ្តុះបណ្តាលជំនាញផ្នែកឱសថសាស្ត្រ និង វេជ្ជសាស្ត្រ (ជាឱសថការី វេជ្ជបណ្ឌិត គ្រូពេទ្យ) ហើយក្រុមការងារនេះធ្វើដំណើរទៅជួប អ្នកផ្តល់សេវាដោយផ្ទាល់និងជាអចិន្ត្រៃយ៍។ ក្រុមការងារចុះជួបក្រុមគោលដៅដោយផ្ទាល់ ម្នាក់-ទល់-ម្នាក់ តាមទីតាំងផ្ទាល់ (បញ្ចរ/តូប) ដើម្បីធានាថា អ្នកផ្តល់សេវាទាំងអស់ មានការជឿជាក់ក្នុងការប្រើប្រាស់ផលិតផល ដោយត្រឹមត្រូវតាមទីផ្សាររបស់អង្គការ ភី អេស អាយ (បច្ចុប្បន្ន អង្គការ ភី អេស អាយ មានផលិតផល ចំនួន១៤ ប្រភេទខុសៗគ្នា )។ ហើយគោលដៅចុងក្រោយរបស់កម្មវិធីនេះ គឺផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវា។សំរាប់គ្រុនចាញ់ ក្រុមការងារបានយកចិត្តទុកដាក់ទៅលើសារសុខភាពជាគន្លឹះមួយចំនួន ដូចជា ជានិច្ចជាកាលត្រូវធ្វើតេស្តឈាមរកមេរោគគ្រុនចាញ់មុននឹងព្យាបាល ផ្តល់ឱសថដែលមានគុណភាព តាមការណែនាំរបស់ក្រសួងសុខាភិបាល មិនផ្តល់ថ្នាំផ្សំឬថ្នាំឈុត ផ្តល់ការណែនាំអោយអ្នកជំងឺលេបថ្នាំគ្រប់ចំនួនរយៈពេល៣ថ្ងៃជាប់ៗគ្នា និងបញ្ជូនទៅសេវាសាធារណៈតាមការចាំបាច់។

ក្រុមការងារអប់រំវេជ្ជសាស្ត្ររបស់អង្គការ ភី អេស អាយ បានចុះជួបអ្នកផ្តល់សេវាតាមទីតាំងផ្ទាល់ សរុបចំនួន ១.១៧៦កន្លែង ស្មើនឹង ៤.៥៨៨លើក ក្នុងឆ្នាំ២០១១។

**ផលប្រយោជន៍នៃការអប់រំវេជ្ជសាស្ត្រគឺ**

- បង្កើនការជួបប្រាស្រ័យទាក់ទងជាមួយអ្នកផ្តល់សេវានៅជនបទ ដែលជាអ្នកផ្តល់សេវាសុខភាពសំខាន់ៗដោយផ្ទាល់ដល់ប្រជាជនក្រីក្រ។
- បង្កើនចំណេះដឹងនិងជំនាញរបស់ផ្តល់សេវានិងតាមដានត្រួតពិនិត្យមើល ការរីកចំរើននៃការផ្តល់សេវាសុខភាព។
- ផ្តល់ឱកាសសំរាប់ប្រមូលព័ត៌មានដោយផ្ទាល់ពីអ្នកផ្តល់សេវា អំពីក្តីព្រួយបារម្ភនិងបញ្ហានានាទាក់ទងនឹងការប្រើប្រាស់ផលិតផល ជាពិសេស សុវត្ថិភាព និង ដំណោះស្រាយភ្លាមៗជូនដល់អ្នកផ្តល់សេវា។

## ៥. ការបញ្ចាំងវីដេអូចល័ត( MVU) អំពីជំងឺគ្រុនចាញ់

ក្រុមការងារបញ្ចាំងវីដេអូចល័តរបស់អង្គការ ភី អេស អាយ តែងតែរៀបចំការបញ្ចាំងវីដេអូនៅតាមតំបន់ដែលប្រឈមនឹងជំងឺគ្រុនចាញ់ខ្ពស់និងពិបាកក្នុងការទទួលបានព័ត៌មាន អំពីជំងឺគ្រុនចាញ់ពីបណ្តាញផ្សព្វ-ផ្សាយ ដូចជាៈ ទូរទស្សន៍និងវិទ្យុ។ ក្រុមបញ្ចាំងវីដេអូចល័ត រួមមាន រថយន្តមួយគ្រឿង ប្រដាប់ដោយឧបករណ៍សំរាប់ចាក់ផ្សាយនិងម៉ាស៊ីនភ្លើង ដែលធ្វើអោយមានភាពងាយស្រួលក្នុងការរៀបចំផ្សព្វផ្សាយនៅតាមតំបន់ដាច់ស្រយាល ។

សំរាប់ការបញ្ចាំងមួយលើកៗ ក្រុមការងារបានរៀបចំយ៉ាងយកចិត្តទុកដាក់ ដើម្បីមានភាពងាយស្រួល ក្នុងការផ្សព្វផ្សាយដល់អ្នកចូលរួមទស្សនា តាមរយៈឈុតឆាកឬវគ្គផ្សេងៗរបស់វីដេអូ និងសកម្មភាពរបស់ពិធីករ ដូចជា វគ្គសំនួរ-ចំលើយ, វគ្គល្បែងកំសាន្តខ្លីៗ ទាក់ទងទៅនឹងប្រធានបទ ឬសារស្តីពីជំងឺគ្រុនចាញ់ ។

សំរាប់ឆ្នាំ២០១១ ក្រុមការងារបញ្ចាំងវីដេអូចល័តរបស់អង្គការ ភី អេស អាយ បានរៀបចំបញ្ចាំងវីដេអូអប់រំស្តីពីជំងឺគ្រុនចាញ់ចំនួន ៥០៨ដង ដែលមានអ្នកចូលរួមទស្សនាប្រហែល ២០៦.៧៦៩ នាក់ ក្នុងសហគមន៍ដែលប្រឈមនឹងជំងឺគ្រុនចាញ់ខ្ពស់ នៃខេត្តដែលប្រឈមនឹងជំងឺគ្រុនចាញ់ទាំង **២០**។

## ៦. យុទ្ធសាស្ត្រភ្ជាប់ទឹកថ្នាំជាមួយមុងធម្មតានៅក្នុងប្រទេសកម្ពុជា- ជាប្រភេទយុទ្ធសាស្ត្រថ្មីតែមួយគត់នៅលើពិភពលោក

តាមការណែនាំរបស់អង្គការសុខភាពពិភពលោក (WHO) អង្គការ ភី អេស អាយ បានផ្លាស់ប្តូរកម្មវិធីបង្ការជំងឺគ្រុនចាញ់របស់ខ្លួននៅឆ្នាំ២០០៨ ជំនួសអោយការនាំចូលមុងជ្រលក់ថ្នាំនិងទឹកថ្នាំសំរាប់ជ្រលក់មុងមានប្រសិទ្ធិភាពរយៈពេលខ្លី អង្គការ ភី អេស អាយ ចាប់ផ្តើមសហការដោយផ្ទាល់ជាមួយវិស័យឯកជន ដើម្បីបង្កើនប្រសិទ្ធិភាពនៃមុងធម្មតា ដែលបាននាំចូលរួចហើយមកក្នុងប្រទេសកម្ពុជា។ នេះគឺជាយុទ្ធសាស្ត្រដ៏ពិតប្រាកដមួយ ក្នុងការសហការរវាងវិស័យសាធារណៈនិងឯកជនដើម្បីប្រែក្លាយមុងធម្មតាដែលបាននាំចូលរាប់លានមុងក្នុងមួយឆ្នាំៗ ឲ្យក្លាយជាមុងជ្រលក់ថ្នាំ ហើយមានប្រសិទ្ធិភាពខ្ពស់ក្នុងការការពារមូសខាំ និងជំងឺគ្រុញចាញ់ ។

យុទ្ធសាស្ត្រនេះគឺសាមញ្ញបំផុត។ តាមការប៉ាន់ប្រមាណ គឺមានមុងធម្មតាប្រហែល ១លានមុងត្រូវបាននាំចូលប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ។ អង្គការ ភី អេស អាយ នាំចូលទឹកថ្នាំជ្រលក់មុងដែលមានប្រសិទ្ធិភាពយូរ អ្នកនាំមុងចូលភ្ជាប់ទឹកថ្នាំជ្រលក់មុងមួយកញ្ចប់ជាមួយមុងធម្មតាដែលគាត់នាំចូលទាំងអស់មុនពេលចែកចាយវាទៅតាមផ្សារនៅតាមខេត្តនានា។ អង្គការ ភី អេស អាយ ចំណាយថវិកាតែទៅលើទឹកថ្នាំជ្រលក់មុង ការផ្សព្វផ្សាយ ដើម្បីលើកកំពស់តំរូវការមុងភ្ជាប់ជាមួយទឹកថ្នាំ និងក្រុមការងារច្រកទឹកថ្នាំជាមួយមុងធម្មតារយៈពេល បួនខែដំបូង ដើម្បីច្រកទឹកថ្នាំ ជាមួយនឹងមុងធម្មតាទាំងអស់ដែលមាននៅតាមតូបលក់មុងក្នុងផ្សារនៃខេត្តគ្រុនចាញ់ទាំង ២០។

ក្នុងអំឡុងខែធ្នូ ឆ្នាំ២០០៩ ទឹកថ្នាំជ្រលក់មុងនាំចូលដោយអង្គការ ភី អេស អាយដំបូង បានមកដល់ប្រទេសកម្ពុជា ហើយយុទ្ធសាស្ត្រភ្ជាប់ទឹកថ្នាំជ្រលក់មុងជាមួយមុងធម្មតា ក៏ចាប់ផ្តើមសម្ពោធក្នុងពេលដំណាលគ្នានោះដែរ។ អង្គការ ភី អេស អាយ បានចុះកិច្ចព្រមព្រៀងជាមួយអាជីករនាំមុងចូលនិងអ្នកលក់ដុំធំៗចំនួន ៥០នាក់ ដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដូចជាបាត់ដំបងនិងបន្ទាយមានជ័យ។ រយៈពេលតែ ៧ខែប៉ុណ្ណោះបន្ទាប់ពីកម្មវិធីសម្ពោធ អង្គការ ភី អេស អាយ បានចែកចាយអស់ចំនួនទឹកថ្នាំដែលបាននាំចូលទាំងនោះ។ ហើយតាមរយៈការស្រាវជ្រាវរបស់អង្គការ ភី អេស អាយ បង្ហាញថា ៧០%នៃតូបលក់មុងនៅទូទាំងប្រទេសមានដាក់លក់មុងមានភ្ជាប់ទឹកថ្នាំ ។

សំរាប់ឆ្នាំ២០១១កន្លងមកនេះ អង្គការ ភី អេស អាយ បានចែកនូវទឹកថ្នាំជ្រលក់មុងដោយឥតគិតថ្លៃចំនួន ៧០០,០១៥កញ្ចប់ ទៅកាន់អាជីវករលក់មុង ដើម្បីភ្ជាប់ជាមួយមុងធម្មតាដែលគាត់នាំចូល។ ការស្រាវជ្រាវ

លើកទី២ ដើម្បីវាស់វែងពីវិសាលភាពនៃការគ្រប់ដណ្តប់នៃមុងភ្នាប់ទឹកថ្នាំ បាននឹងកំពុងតែធ្វើការវិភាគ ហើយទិន្នន័យនឹងទទួលបានក្នុងពេលឆាប់ៗនេះ។

ក្នុងឆ្នាំ២០១១នេះដែរ ស្ពតវិទ្យុនិងទូរទស្សន៍ (អរគុណម៉ែ!) ដើម្បីជួយជំរុញគាំទ្រការនៃមុងភ្ជាប់ទឹកថ្នាំត្រូវបានចាក់ផ្សាយឡើងវិញតាមរយៈស្ថានីយ៍ទូរទស្សន៍ថ្នាក់ជាតិចំនួន៤ និង ស្ថានីយ៍វិទ្យុថ្នាក់ជាតិចំនួន៤ ហើយនឹងស្ថានីយ៍វិទ្យុតាមខេត្តចំនួន១៣។ យុទ្ធនាការតាមរយៈវិទ្យុនិងទូរទស្សន៍នេះ គឺដើម្បីជំរាបអតិថិជនអោយទិញមុងដែលមានភ្ជាប់ទឹកថ្នាំ ហើយជ្រលក់មុងភ្លាមៗបន្ទាប់ពីទិញរួច។ ទឹកថ្នាំជ្រលក់មុងមានសុវត្ថិភាព ងាយស្រួលប្រើ ហើយអាចជួយអោយមុងធម្មតារបស់គាត់ក្លាយជាមុងមានប្រសិទ្ធិភាពខ្ពស់ ក្នុងការការពារមូស និងជំងឺគ្រុនចាញ់រហូតដល់រយៈពេល ៣ឆ្នាំ ។

## ២.អន្តរាគមន៍បញ្ឈប់នូវការប្រើប្រាស់ឱសថដែលនាំឲ្យមានភាពស៊ាំរបស់មេរោគគ្រុនចាញ់ជា មួយថ្នាំអាតេមីស៊ីនីន:

របកគំហើញថ្មីៗពីគម្រោងដែលគាំទ្រដោយមូលនិធិប៊ីលហ្គេត និងការសិក្សាជាច្រើនបានបង្ហាញឲ្យឃើញថាមេរោគគ្រុនចាញ់ដែលធន់នឹងឱសថប្រឆាំងជំងឺគ្រុនចាញ់ផ្សំ ដោយសារជាតុអាតេមីស៊ីនីនកំពុងមានវត្តមាននៅតាមបណ្តោយព្រំដែនកម្ពុជាថៃ អាចនឹងវិវត្តទៅជាមេរោគដែលស៊ាំជាមួយថ្នាំអាតេមីស៊ីនីនជាប្រភេទថ្នាំដែលត្រូវបានណែនាំថាមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងការព្យាបាលជំងឺគ្រុនចាញ់ប្រភេទហ្វាល់ស៊ីប៉ារ៉ូម។

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងបញ្ហាដ៏ស្រួចស្រាវនេះតាមរយៈការធ្វើឲ្យប្រសើរឡើងនូវការទទួលយកសេវាព្យាបាលជំងឺបានត្រឹមត្រូវ និងបង្ការការប្រើប្រាស់ថ្នាំគ្រុនចាញ់តែមួយមុខ និងថ្នាំខុសច្បាប់ឬក្លែងក្លាយនៅតាមសេវាសុខភាពសាធារណៈ និងឯកជនៈ

- បន្តផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលហាមការផលិតនិងលក់ឱសថគ្រុនចាញ់ដែលមានជាតិផ្សំតែមួយមុខ
- ចុះត្រួតពិនិត្យលើការអនុវត្តន៍សេចក្តីណែនាំរបស់ក្រសួងសុខាភិបាលនៅតាមសេវាឯកជនទាំងឱសថស្ថានឱសថស្ថានរងនិងតូបលក់ឱសថដើម្បីទប់ស្កាត់ការលក់ឱសថArtemisinine Monotherapy នឹងពង្រឹងនៅសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល។
- ផ្នែកឱសថនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺគ្រុនចាញ់បានរួមសហការណ៏ ជាមួយមន្ត្រីប៉ូលីសយុត្តិធម៌និងមន្ត្រីការិយាល័យឱសថនៃមន្ទីរសុខាភិបាលខេត្តនៅតាមខេត្តចំនួន១០ដែលនៅតំបន់១និងតំបន់២ដែលឧបត្ថម្ភថវិកាដោយcontaintment project ក្នុងគោលបំណងដើម្បីជួយទប់ស្កាត់ភាពស៊ាំរបស់មេរោគជាមួយឱសថគ្រុនចាញ់។
- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានសហការណ៏ជាមួយនាយកដ្ឋានប៉ូលីសប្រឆាំងបទល្មើសសេដ្ឋកិច្ច ដោយបានបណ្តុះបណ្តាលមន្ត្រីប៉ូលីសប្រឆាំងបទល្មើសសេដ្ឋកិច្ចអោយបានយល់ដឹងពីការត្រួតពិនិត្យលក្ខណៈគុណភាពឱសថ ដើម្បីធ្វើការសហការជាមួយមន្ត្រីប៉ូលីសយុត្តិធម៌នៅតាមខេត្តនីមួយៗក្នុងការត្រួតពិនិត្យនិងតាមដានលើគុណភាពឱសថជាប្រចាំដែលបានប្រើប្រាស់នៅតាមសេវាឯកជន។ ជាលទ្ធផលបានត្រួតពិនិត្យចំនួន៨ដងនៅខេត្ត ពោធិសាត់ បាត់ដំបង ឧត្តរមានជ័យ កំពត កោះកុង បន្ទាយមានជ័យ កំពង់ស្ពឺ និង ខេត្តព្រះវិហារ។

បច្ចុប្បន្ន ផ្នែកឱសថនៃមជ្ឈមណ្ឌលជាតិគឺមានទំនាក់ទំនងជាមួយឃ្លាំងឱសថកណ្តាលCMSជាប្រចាំរាល់ការចែកចាយ/ផ្គត់ផ្គង់ឃ្លាំងឱសថកណ្តាលCMS ជាអ្នកអនុវត្តដោយផ្អែកលើគំរោងផែនការរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ CNM លើកលែងតែករណីឱសថរឺបរិក្ខារពេទ្យមួយចំនួនដែលឃ្លាំងឱសថកណ្តាល CMS

អាចធ្វើការចែកចាយ/ផ្គត់ផ្គង់ទៅតាមវគ្គចែកចាយរបស់ខ្លួនក្នុងនោះផ្នែកឱសថនៃមជ្ឈមណ្ឌលជាតិក៏អាចតាមដាន នូវស្ថានភាពស្តុកដោយប្រើតាមប្រព័ន្ធ NatDID តាមរយៈអ៊ិនធើណិត Internet ផងដែរ។

## ៣.ធានាបាននូវការទទួលយកសេវាបង្ការជាពិសេសការបង្ការការចម្លងមេរោគគ្រុនចាញ់ដែលមានភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន ក្នុងចំណោមប្រជាជនគោលដៅ តាមរយៈការត្រួតពិនិត្យសត្វមូស ដែលជាភ្នាក់ងារចម្លងជំងឺ និងមធ្យោបាយការពារដោយខ្លួនឯងផ្ទាល់ និងការកែលំអបរិស្ថាន។

ដើម្បីធានាអោយបាននូវការពារពិសេសបង្ការភាពចំលងនៃមេរោគគ្រុនចាញ់ពីមូសក្នុងចំណោម ប្រជាជនគោលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុចាញ់សហការជាមួយ ដៃគូរអភិវឌ្ឍន៏បានអនុវត្តផែនការ សកម្មភាពយុទ្ធសាស្ត្រដូចខាងក្រោមនេះ

1. ធ្វើយុទ្ធនាការបែងចែកមុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ និងអង្រឹងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ ចំពោះ ប្រជាជនគោលដៅ ចំពោះប្រជាជនចំណាកស្រុក និង ប្រជាជនដែលទៅធ្វើការ និង សំរាកក្នុងព្រៃ ទាំង ២០ខេត្ត។
2. ធ្វើការបាញ់ថ្នាំតំបន់ដែលមានអ្នកជំងឺគ្រុនចាញ់នៅមានវត្តមានប៉ារ៉ាស៊ីតក្នុងឈាម ក្រោយការ ព្យាបាល៣ថ្ងៃ ។
3. ធ្វើការតាមដានប្រសិទ្ធិភាពមុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរដែលបានប្រើប្រាស់ក្នុងមូលដ្ឋាន ទៅនឹង ភ្នាក់ងារចំលងជំងឺគ្រុនចាញ់ ។
4. ធ្វើការតាមដានប្រសិទ្ធិភាពថ្នាំបាញ់ជញ្ជាំងទៅនឹងភ្នាក់ងារចំលងជំងឺគ្រុនចាញ់ ។
5. អភិបាលកិច្ចការងារបែងចែកមុង គ្រប់គ្រងមុង និងការជ្រលក់មុងដល់មូលដ្ឋាន ។
6. រៀបចំកំណត់ទីតាំង ផែនទី ភូមិដែលប្រឈមនឹងជំងឺគ្រុនចាញ់ ។

**សមិទ្ធិផលដែលសំរេចបានផ្នែកគ្រប់គ្រងបាណកសាស្ត្រ**(Vector Control Unit) **ក្នុងឆ្នាំ២០១១ ៖**

1. **ធ្វើយុទ្ធនាការបែងចែកមុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរនិងអង្រឹងជ្រលក់ថ្នាំប្រសិទ្ធភាពយូរចំពោះប្រជាជន គោលដៅ ចំពោះប្រជាជនចំណាកស្រុកនិងប្រជាជនដែលទៅធ្វើការនិងសំរាកក្នុងព្រៃទាំង២០ខេត្ត៖**

1. នៅក្នុងឆ្នាំ ២០១១នេះ គំរោងមូលនិធិសកល ជុំទី ៦ និង SSF grant បានទិញមុង ជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ និងអង្រឹងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរចំនួន ២.៧ លានមុង។ ដោយសារ ចំនួនមុង មានចំនួនច្រើន មុងទាំងអស់នេះបានដឹកមកជាពីរលើក លើកទី១ ចំនួន ៧៨៥.៥០០ មុងជ្រលក់ ថ្នាំប្រសិទ្ធិភាពយូរ និង លើកទី២ ចំនួន ១.៦៣៥.៥០០ មុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ និង ២៧៥.០០០ មុងអង្រឹងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ។ដើម្បីឲ្យយុទ្ធនាការដែលមិនធ្លាប់មាននេះ ប្រព្រឹត្តទៅបានល្អប្រសើរ មជ្ឈមណ្ឌលជាតិ បានបើកសិក្ខាសាលាណែនាំស្តីពីយុទ្ធានាការបែងចែក មុងនេះចំនួន៣ ដែលមានសិក្ខា កាមមកពីថ្នាក់ កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក និង មណ្ឌលសុខ ភាព (មើលតារាងទី១) ។គោលបំណងសិក្ខាសាលា នេះគឺផ្តោតលើៈ (១) វឌ្ឍនភាពការងារ លើ សេចក្តីណែនាំស្តីពីការបែងចែកមុងរបស់៖ **ឯកឧត្តមម៉មប៊ុនហេង**រដ្ឋមន្ត្រីក្រសួងសុខាភិបាល, (២) គោលនយោបាយនៃការចាត់ចែង និងទុកដាក់ មុង, (៣) ការកំណត់គោលដៅសំរាប់ការបែងចែក មុង, (៤) ការធ្វើជំរឿនប្រជាជនមុងចែក មុងដោយប្រើ សៀវភៅតាមដានការចែកមុង

(៥) ការធ្វើជំរឿនប្រជាជនចល័តសំរាប់ការបែងចែកមុង, (៦)ធ្វើការប្រជុំក្រុមការងារលុបបំបាត់ជំងឺគ្រុនចាញ់ពិសេសថ្នាក់ខេត្តមុនការចែកមុង, (៧) គោលការ ណែនាំលំអិតពីយុទ្ធនាការចែកមុង, (៨) ការធ្វើអង្កេតរហ័សលើការតាមដានការចែកមុង។ យុទ្ធនាការ បែងចែកមុងនេះចាប់ផ្តើមពីខែ វិច្ឆិកា ២០១១ និង បញ្ចប់ក្នុងខែ កុម្ភៈ ២០១២ ។

តារាងទី១. ចំនួនអ្នកចូលរួមសិក្ខាសាលាស្តីពីយុទ្ធនាការបែងចែកមុង

| ល.រ | សិក្ខាកាមមកពី | ចំនួនអង្គភាព | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | មជ្ឈមណ្ឌលជាតិគ្រុនចាញ់ | ១ | ២០ |
| ២ | មន្ទីរសុខាភិបាលខេត្ត | ២០ | ៦០ |
| ៣ | ស្រុកប្រតិបត្តិ | ៤៥ | ១៨០ |
| ៤ | មណ្ឌលសុខភាព | ៣១៤ | ៣១៤ |

មកទល់នឹងបច្ចុប្បន្ននេះ យើងបានគ្របដណ្តប់មុងជ្រលក់ថ្នាំបានចំនួន ៨០% ចំពោះប្រជាជនដែលប្រឈមនឹងជំងឺគ្រុនចាញ់ទាំងអស់ (៣.២០៥.៩៦១) បើគិតជាភូមិបានចំនួន ៧២%នៃភូមិ គោលដៅទាំងអស់(៤.១៣០) ។ ក្នុងនេះ ១.១២៤.៤៣៥ នាក់បានគ្របដណ្តប់ក្នុងរយៈកាល ២ឆ្នាំ កន្លងនេះ និង ១.៥២១.១៥៩នាក់ ក្នុងឆ្នាំនេះ (ដែលឆ្នាំនេះរួមមាន ៧៦៨.៣៩០ មុងជ្រលក់ថ្នាំ មានប្រសិទ្ធិភាពយូរ, ៤២៣.៤៤២ មុងអង្រឹងជ្រលក់ថ្នាំមានប្រសិទ្ធិភាពយូរ, ៩.៨៤៣ មុងជ្រលក់ថ្នាំ ធម្មតា និង ៣១៩.៨៨៤ មុងជ្រលក់ថ្នាំឡើងវិញ) (មើលតារាងទី២)។

ចំពោះប្រជាជនចំណាកស្រុក យើងបានប្រើយុទ្ធសាស្ត្រពីរសំរាប់ធ្វើការគ្របដណ្តប់ ដោយយោងទៅនឹងរយៈពេលស្នាក់នៅរបស់គាត់ ។ (១) ប្រជាជនចំណាកស្រុកដែលមកបោះទីតាំងថ្មី ដោយខ្លួនឯងនឹងធ្វើការស្នាក់នៅលើសពី ១ឆ្នាំ, (២) ប្រជាជនចំណាកស្រុកដែលមកធ្វើការឲ្យក្រុមហ៊ុន ម្ចាស់កសិដ្ឋាន ចំការ ជាដើម ការគ្របដណ្តប់មុងរបស់គាត់នឹងធ្វើតាមរយៈម្ចាស់ ក្រុមហ៊ុន ម្ចាស់កសិដ្ឋាន ចំការ ដោយប្រើយុទ្ធសាស្ត្រឲ្យខ្ចី ។ ជាក់ស្តែង ៣.០៩៤ម្ចាស់កសិដ្ឋាន ដែលមានអ្នក ចំណាកស្រុកចំនួន ៧១.១៩៨ បានទទួលមុងខ្ចីចំនួន ៤៦.៨៩៧ មុងជ្រលក់ថ្នាំមានប្រសិទ្ធិភាពយូរ, ១៥មុងអង្រឹងជ្រលក់ ថ្នាំមានប្រសិទ្ធិភាពយូរ និងបានជ្រលក់មុងចាស់របស់ពួកគាត់ចំនួន ៣.៦៥០ នៅក្នុងខេត្តប៉ៃលិន ។

**2.ធ្វើការបាញ់ថ្នាំតំបន់ដែលមានអ្នកជំងឺគ្រុនចាញ់នៅមានវត្តមានប៉ារ៉ាស៊ីតក្នុងឈាមក្រោយការព្យាបាល៣ថ្ងៃ**

អ្នកជំងឺគ្រុនចាញ់ចំនួន ៧៨ នាក់ដែលនៅមានផ្ទុកវត្តមានប៉ារ៉ាស៊ីត ក្នុងឈាមក្រោយការព្យាបាល ៣ថ្ងៃដែលបានស្រាវជ្រាវឃើញមកពី ៥មណ្ឌលសុខភាព រួមមានមណ្ឌលសុខភាព តាសាញ, មណ្ឌលសុខភាពសំពៅលូន, មណ្ឌលសុខភាពក្រចាប់, មណ្ឌលសុខភាពស្ទួនកុមារ និង មណ្ឌលសុខភាពប្រម៉ោយ បានធ្វើការស៊ើបអង្កេត និងផ្តល់ការពារការចំលងបន្ថែមដោយធ្វើការបាញ់ថ្នាំ។ អ្នកជំងឺទាំងនេះរស់នៅក្នុងភូមិចំនួន ២៥ នៃ ៥មណ្ឌលសុខភាព, ៤ស្រុកប្រតិបត្តិ ក្នុងខេត្តចំនួន ៣ ។ ភូមិទាំង ២៥ នេះបានទទួលការបាញ់ថ្នាំលើជញ្ជាំងជុំវិញកន្លែងរស់នៅរបស់ អ្នកជំងឺ ។

Figure 1- Map of focal D3 positive cases




### 3. ធ្វើការតាមដានប្រសិទ្ធិភាពមុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរដែលបានប្រើប្រាស់ក្នុងមូលដ្ឋានទៅនឹងភ្នាក់ងារចំលង ជំងឺគ្រុនចាញ់

មុងជ្រលក់ថ្នាំដែលមានប្រសិទ្ធិភាពយូរ គឺមុង (Olyset)បានយកមកធ្វើពិសោធន៍ ។ សំណាកចំនួន៣ (ដំបូល និង ចំហៀងទាំងពីរ) ដែលមានទំហំ ៥០ស.ម x ១៥០ស.ម បានកាត់ចេញមុងនេះ ដែលបានប្រើប្រាស់នៅមូលដ្ឋាន រហូតមានរយៈពេល៣ឆ្នាំ ។ មុងជ្រលក់ថ្នាំដែលមានប្រសិទ្ធិភាព យូរមួយចំនួនបានប្រមូលមកពីខេត្តចំនួន ៣ មានខេត្ត រតនគីរី, ខេត្ត ឧត្តរមានជ័យ និង ខេត្តកំពត។ សំណាក ទាំងនេះបានបោកទឹករយៈពេល ១អាទិត្យទើបយកមកធ្វើការពិសោធន៍នៅមូលដ្ឋាន ។ សំណាកទាំងនេះ បានរក្សាទុកក្នុងថង់ប្លាស្ទិក ។

ការពិសោធន៍នេះបានប្រើរបៀប(WHO plastic cone-bioassay) ចំពោះសំណាកនិមួយៗ ។ ដើម្បីកុំឲ្យមូសដែលពិសោធន៍មានការរំខាន ការពិសោធន៍នេះបានប្រើប្រាស់មូសតែ ៥ក្នុងការពិសោធន៍មួយៗ។ តែយ៉ាងហោចណាស់ត្រូវធ្វើចំនួន ៥លើកចំពោះសំណាកនិមួយៗ ។

ក្រោយការពិសោធន៍ចំនួន ៣នាទី មូសដែលពិសោធន៍ត្រូវផ្ទេរដាក់ក្នុងកែវជ័រចំណុះ ១៥០ម.ល ដោយមានទឹកស្ករ ។ ភាគរយមូសដែលធ្លាក់ក្រោយរយៈពេល ៦០នាទី និង ភាគរយមូសដែលស្លាប់ក្រោយរយៈពេល ២៤ម៉ោង ត្រូវបានកត់ត្រាទុក ។

ក្នុងរយៈពេល១០ថ្ងៃជាប់ៗគ្នា មូសដែកគោលចំនួន ១៤.៣៣៩ បានចាប់ដោយប្រើរបៀបចាប់លើទំលើមនុស្ស ។ ក្នុងចំណោមនេះ មានមូសដែកគោលប្រភេទ*An.dirus* ចំនួន២.២៧៩, មូសដែកគោលប្រភេទ*An. minimus* ចំនួន ៦.៣៩៧, មូសដែកគោលប្រភេទ*An. maculatus* ចំនួន ២.២៩៩ និង មូសដែកគោលប្រភេទ*An. epiroticus*ចំនួន៣.៣៦៤ ។ មូសទាំងនេះបានយកទៅធ្វើការពិសោធន៍ ក្រោមសីតុណ្ហភាពនិងសំណើមដូចតារាងទី៣ ខាងក្រោម៖


Insecticide Treated Net Coverage 2011
78%
49%
66%
52%
100%
73%
83%
91%
100%
69%
71%
53%
100%
100%
72%
68%
75%
58%
41%
100%
Legend
Province Boundary
Main River
* % of Net Coverage
<50%
51-80%
>80
Commune Boundary
* This coverage including LLIN, LLIHN, CTN and Treated net.
N
0
50
100 Kilometers

## តារាងទី២៖ការបែងចែកមុងក្នុងឆ្នាំ២០១១

Bed Net Distribution All Zones - 2011

| Province | Villages** Retreated | Population**** | HH | Survived | LLIN | LLIHN | Conv. |
|---|---|---|---|---|---|---|---|
| Banteay Meanchey | | 37 | of | 126 | 29% | 52,492 | of |
| | 108,111 | 49% | 23,732 | 42,287 | 1,000 | 7,600 | 0 |
| | 1,605 | | | | | | |
| Battambang | 259 | of | 336 | 77% | 274,076 | of | 330,668 |
| | 83% | 73,403 | 191,338 | 14,454 | 29,873 | 3,859 | 34,552 |
| Kg. Cham | 495 | of | 522 | 95% | 592,155 | of | 522,100 |
| | 113% | 110,016 | 76,320 | 337,985 | 70,700 | 0 | 107,150 |
| Kg. Chhnang | 104 | of | 119 | 87% | 104,552 | of | 79,442 |
| | 132% | 17,041 | 9,140 | 60,471 | 12,136 | 0 | 22,805 |
| Kg. Speu | 203 | of | 277 | 73% | 97,689 | of | 144,377 |
| | 68% | 29,612 | 65,976 | 0 | 23,312 | 1,698 | 6,703 |
| Kg. Thom | 252 | of | 273 | 92% | 206,704 | of | 171,326 |
| | 121% | 35,408 | 23,703 | 154,501 | 28,500 | 0 | 0 |
| Kampot | 80 | of | 171 | 47% | 121,274 | of | 208,152 |
| | 58% | 45,529 | 89,008 | 1,320 | 21,879 | 400 | 8,667 |
| Kep | 17 | of | 20 | 85% | 43,317 | of | 36,303 |
| | 119% | 7,336 | 6,500 | 30,817 | 6,000 | 0 | 0 |
| Koh Kong | 99 | of | 140 | 71% | 66,533 | of | 92,505 |
| | 72% | 18,975 | 37,519 | 2,531 | 14,733 | 1,805 | 9,945 |
| Kratie | 183 | of | 222 | 82% | 130,319 | of | 187,692 |
| | 69% | 36,917 | 56,031 | 21,316 | 27,400 | 1,268 | 24,304 |
| Mondul Kiri | 72 | of | 148 | 49% | 51,286 | of | 72,133 |
| | 71% | 14,417 | 18,687 | 8,600 | 11,500 | 0 | 12,499 |
| Oddar Meanchey | | 207 | of | 324 | 64% | 123,894 | of |
| | 158,868 | 78% | 33,331 | 74,378 | 3,520 | 30,074 | 0 |
| | 15,922 | | | | | | |
| Pailin | 56 | of | 116 | 48% | 78,360 | of | 86,336 |
| | 91% | 20,506 | 70,764 | 0 | 3,946 | 0 | 3,650 |
| Preah Vihear | 209 | of | 270 | 77% | 104,344 | of | 200,301 |
| | 52% | 40,980 | 56,428 | 15,303 | 31,800 | 813 | 0 |
| Pursat | 49 | of | 123 | 40% | 58,891 | of | 111,098 |
| | 53% | 23,668 | 31,756 | 0 | 15,475 | 0 | 11,660 |
| Ratanak Kiri | 211 | of | 330 | 64% | 130,257 | of | 177,377 |
| | 73% | 33,433 | 61,204 | 17,800 | 26,000 | 0 | 25,253 |
| Siem Reap | 180 | of | 267 | 67% | 140,507 | of | 211,873 |
| | 66% | 42,010 | 102,471 | 2,840 | 21,900 | 0 | 13,296 |
| Sihanoukville | 83 | of | 122 | 68% | 99,457 | of | 132,770 |
| | 75% | 27,267 | 58,791 | 0 | 22,833 | 0 | 17,833 |
| Stung Treng | 155 | of | 160 | 97% | 159,349 | of | 124,240 |
| | 128% | 23,731 | 41,470 | 95,932 | 17,907 | 0 | 4,040 |
| Takeo | 43 | of | 64 | 67% | 20,538 | of | 50,289 |
| | 41% | 11,780 | 10,664 | 0 | 9,874 | 0 | 0 |
| | 2994 | of | 4130 | 72% | 2,655,994 | of | 3,205,961 |
| | 83% | 669,092 | 1,124,435 | 768,390 | 433,442 | 9,843 | 319,884 |

* No of nets assumed to survive from previous years (100% for 3 years, 0% in fourth year)

** No. of villages that have distributed bed net for this year

**** Population coverage this year and previous survived (based on coverage ratio 1 net per 1 persons)

*Extracted due 08 February 2012 from MIS*

យើងបានកត់សំគាល់ឃើញថា មុងជ្រលក់ថ្នាំមានប្រសិទ្ធិភាពយូរ (Olyset ) ដែលបានប្រើប្រាស់ក្នុងមូលដ្ឋាន មានប្រសិទ្ធិភាពរហូតដល់ ៣ឆ្នាំ ចំពោះភ្នាក់ងារចំលងជំងឺគ្រុនចាញ់ប្រភេទ *An. dirus& An.epiroticus* ។ លើកលែងតែភ្នាក់ងារចំលងជំងឺគ្រុនចាញ់ប្រភេទ *An. minimus* មុងដែលប្រើ បាន៣ឆ្នាំ ប្រសិទ្ធិភាពរបស់វា តិចជាងកំរិតស្តង់ដារចំនួន ៥% និងចំពោះភ្នាក់ងារ ចំលងជំងឺគ្រុនចាញ់ប្រភេទ*An. maculatus* ប្រសិទ្ធិភាពរបស់វា តិចជាងកំរិតស្តង់ដារចំនួន ១០%, ១៥% និង ២០% ចំពោះមុងដែលប្រើបានរយៈពេល១ឆ្នាំ, ២ឆ្នាំនិង៣ឆ្នាំ។ វាមានភាពខុសគ្នារវាង ប្រសិទ្ធិភាពទៅតាមប្រភេទមូស ($P<0.5$) ។

Chart1- The 24h mortality of bioassay against malaria vectors




មុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរដែលកំណត់ដោយអង្គការសុខភាពពិភពលោកថាជាមុងដែល មានប្រសិទ្ធិភាពលើសមុងជ្រលក់ថ្នាំធម្មតា ។ ប្រសិទ្ធិភាពរបស់មុងនឹងថយចុះជាបណ្តើរៗបន្ទាប់ពី ការប្រើប្រាស់ រយៈពេលប្រើ និងការបោកគក់ជាដើម។ មុងជ្រលក់ថ្នាំប្រសិទ្ធិភាពយូរ(Olyset™)ដែលមានបច្ចេកទេសភ្ជាប់ទឹកថ្នាំថ្មី តែត្រូវការពេលវេលាដើម្បីឲ្យប្រសិទ្ធិភាពថ្នាំមានគ្រប់គ្រាន់ បន្ទាប់ពីការបោកគក់ និងអាស្រ័យដោយកំដៅ ដែលទាំងនេះបានបង្ហាញដោយការស្រាវជ្រាវរបស់ WHOPES ។ ដូច្នេះការសិក្សារបស់យើងត្រូវគិតគូរដល់ទំលាប់នៃការប្រើប្រាស់មុង ដូចជាការបោក គក់ និងរបៀបហាលផងដែរ ។ ហេតុដូចនេះការធ្វើ tunnel test ជាការចាំបាច់ក្នុងការវាស់វែងមុង ដែលមានប្រសិទ្ធិភាពក្រោមកំរិតស្តង់ដារដោយការរកអត្រាមូស ដែលនៅមានសមត្ថភាពអាចខាំឈាម ។

## 4. ធ្វើការតាមដានប្រសិទ្ធិភាពថ្នាំបាញ់ជញ្ជាំងទៅនឹងភ្នាក់ងារចំលងជំងឺគ្រុនចាញ់

ការគ្រប់គ្រងភ្នាក់ងារចំលងដោយការបាញ់ថ្នាំមូស (IRS) និងការប្រើប្រាស់មុងជ្រលក់ថ្នាំក្នុងការកាត់បន្ថយបន្ទុកជំងឺគ្រុនចាញ់ នឹងទប់ស្កាត់ការរីករាលដាលនៃភាពស៊ាំថ្នាំគ្រុនចាញ់(Artemisinine)ជាយុទ្ធវិធីដ៏ចំបងរបស់អង្គការសុខភាពពិភពលោកក៏ដូចជាមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ តាមរយៈការបាញ់ថ្នាំបន្ថែមនៅជុំវិញកន្លែងអ្នកជំងឺដែលនៅមានផ្ទុកប៉ារ៉ាស៊ីតនៅថ្ងៃទី៣។ ថ្នាំបាណកយាដ5% deltamethrin បានយកមកធ្វើពិសោធន៍ ប្រសិទ្ធិភាពរបស់វាដែលបាញ់លើជញ្ជាំង។ ការពិសោធន៍បានធ្វើនៅកន្លែង ៣ ក្រោមសីតុណ្ហភាពនិងសំណើមដូចតារាង ៥ ខាងក្រោម:

Table3- Temperature and humidity

| *Study sites* | *Temperature (Celsius)* | | | *Humidity (Degree)* | | |
|---|---|---|---|---|---|---|
| | At start | After 12h | At the End | At start | After 12h | At the End |
| *Pailin* | 26.6 | 31.5 | 25.9 | 25.1 | 26.8 | 25.2 |
| *Pursat* | 24.9 | 27.8 | 24.5 | 23.1 | 25.6 | 23.4 |
| *Koh Kong* | 27.0 | 29.8 | 26.6 | 24.5 | 27.5 | 26.2 |
| *Total* | 26.4 | 30.6 | 25.8 | 24.6 | 26.7 | 25.0 |

លទ្ធផលបង្ហាញថា ប្រសិទ្ធិភាពថ្នាំបាញ់ជញ្ជាំង5% deltametrinមានប្រសិទ្ធិភាពប្រឆាំងភ្នាក់ងារចំលងដូចជា*An. dirus, An.minimus, An.maculatus & An.epiroticus* ក្នុងរយៈពេលបាញ់ ៣ខែ ។ ក្រោយការបាញ់ ៣ខែប្រសិទ្ធិភាពវាបានថយចុះប្រហែល ៣%ក្រោមកំរិតស្តង់ដារ ចំពោះភ្នាក់ងារ ចំលង *An. minimus* and *An. maculatus* ។

Chart2: The bio-efficacy of insecticide treated wall against malaria vector




## 5. អភិបាលកិច្ចការងារបែងចែកមុងគ្រប់គ្រងមុងនិងការជ្រលក់មុងដល់មូលដ្ឋាន

ផ្នែកគ្រប់គ្រងភ្នាក់ងារចំលងបានធ្វើការតាមដាន និងផ្តល់ការអភិបាលចំពោះ ខេត្តទាំង ២០និង ៤៥ ស្រុកប្រតិបត្តិក្នុងគោលបំណងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងផ្តល់ការគាំទ្រទាំងស្មារតី ចំពោះសហគមន៍ ។ ដោយក្នុងឆ្នាំនេះការងារបែងចែកមុង មានលក្ខណៈទ្រង់ទ្រាយធំ (យុទ្ធនាការ) មជ្ឈមណ្ឌលជាតិបានបង្កើតក្រុមការងារចំនួន ៧ ដែលដឹកនាំដោយថ្នាក់ដឹកនាំរបស់មជ្ឈមណ្ឌល ក្នុងការផ្តល់ការអភិបាលដោយផ្ទាល់ចំពោះយុទ្ធនាការបែងចែកមុង ដល់ខេត្តទាំង ២០ នៃ ស្រុកប្រតិបត្តិចំនួន ៤៥ ។

## 6. ត្រៀមរៀបចំកំណត់ទីតាំងផែនទីភូមិដែលប្រឈមនឹងជំងឺគ្រុនចាញ់

ភូមិគោលដៅដែលប្រឈមនឹងជំងឺគ្រុនចាញ់ចំនួន ២០ ខេត្ត បានធ្វើការកំណត់ដោយយោងទៅតាមចំងាយពីព្រៃ និងអត្រាជំងឺគ្រុនចាញ់ ។ ក្នុងចំណោមខេត្តទាំង ២០ នៃខេត្តទាំង ២៤ មានស្រុកប្រតិបត្តិចំនួន ៤៥ ក្នុងចំណោមស្រុកប្រតិបត្តិ ៧៧ (៥៨%), មានមណ្ឌលសុខភាពចំនួន ៣៦៣ ក្នុង

ចំណោមមណ្ឌលសុខភាពចំនួន ១.០៨៦ (៣៣%) និង មានភូមិចំនួន ៤.១៣០ ក្នុងចំណោមភូមិ ១៥.១៦៧ (២៧%) ដែលបានកំណត់ជាកន្លែងដែលប្រឈមនឹងជំងឺគ្រុនចាញ់ ។

## ៤. ធានាថាសហគមន៍បានទទួលការយល់ដឹងទូលំទូលាយអំពីជំងឺគ្រុនចាញ់និងការប្រកាន់យកឥរិយាបថ ត្រឹមត្រូវក្នុងការបង្ការការចម្លងជំងឺគ្រុនចាញ់ចលនាសហគមន៍និងការគាំទ្រកម្មវិធីប្រយុទ្ធនឹងជំងឺ គ្រុនចាញ់

ដើម្បីឆ្លើយតបទៅនឹងការធានាអោយបានលើការយល់ដឹងទូលំទូលាយអំពីជំងឺគ្រុនចាញ់និងការប្រកាន់យកឥរិយាបថត្រឹមត្រូវក្នុងការបង្ការការចម្លងជំងឺគ្រុនចាញ់នៅសហគមន៍ផ្នែកអប់រំសុខភាពរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់និងដៃគូរអភិវឌ្ឍន៏បានសហការគ្នាអនុវត្តន៏នូវការងារមួយចំនួនដូចខាងក្រោមនេះ

ក-ផ្តល់ចំណេះដឹងអំពីមូលហេតុរោគសញ្ញានិងការចំលងនៃជម្ងឺគ្រុនចាញ់

ខ-បង្កើតចំណេះដឹងនិងផ្សព្វផ្សាយបន្ថែមដល់សហគមន៍ពីវិធានការណ៍ការពារជំងឺគ្រុនចាញ់។

គ-ពង្រឹងភាពជឿជាក់ដល់សហគមន៍លើការព្យាបាលជំងឺគ្រុនចាញ់ដើម្បីឈានទៅរកការកែប្រែទំលាប់ជាបណ្តើរៗ ។

ឃ-បង្កើនការយល់ដឹងដល់សហគមន៍តាមរយអ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិដោយវិធិសាស្រ្តអប់រំសុខភាពមានរូបភាពដែលមានប្រសិទ្ធិភាពខ្ពស់ដើម្បីឱ្យប្រជាជនចេះការពារខ្លួនដោយខ្លួន ឯងផ្ទាល់អោយចេះប្រើប្រាស់មុង និងមុងជ្រលក់ថ្នាំ និងមុងអង្រឹងជ្រលក់ថ្នាំនៅពេលចូលព្រៃ។

ង-បន្ថែមចំណេះដឹងដល់អ្នកស្មគ្រ័ចិត្តភូមិតាមរយៈការអប់រំសុខភាពដោយមានប្រើប្រាស់សំភារៈអប់រំសុខភាពបង្កើតឲ្យប្រជាជនដោយខ្លួនឯងអំពីការបង្ការដោយខ្លួនឯងក្នុងការប្រើប្រាស់មុងជ្រលក់ថ្នាំនិងមុងអង្រឹងជ្រលក់ថ្នាំនៅពេលទៅព្រៃ។

ឆ្លើយតបទៅនឹងចំនុចទាំង៥ខាងលើនេះសកម្មភាពមួយចំនួនត្រូវបានអនុវត្តន៏នៅក្នុងឆ្នាំ២០១១៖

**១- ពង្រាងរូបភាពនិងផលិតរូបភាពគំរូដើម**

<u>ក-ការផលិតសំភារៈអប់រំសុខភាពដោយកម្មវិធីជាតិ:</u>

-ផលិតសំភារៈអប់រំសុខភាពសំរាប់សហគមន៏មានដូចជាៈចំរៀងដែលមានខ្លឹមសារទាក់ទងនិង វិធីបង្ការជម្ងឺគ្រុនចាញ់ ការប្រិប្រាស់មុងនិងការស្វែងរកសេវាព្យាបាល ។

-ផលិតវីដេអូស្ពុតចំនួន៥ចំរៀងដែលមានខ្លឹមសារទាក់ទងនិងវីធីការពារជម្ងឺគ្រុនចាញ់ការប្រើប្រាស់មុងនិងការស្វែងរកសេវាព្យាបាល។

-ផលិតរឿងល្ខោនតាមវិទ្យុ ដែលមានខ្លឹមសារទាក់ទងទៅនិងការប្រើប្រាស់មុង

-រៀបចំជាសៀវភៅមគ្គុទេសន៏សំរាប់ប្រើសំភារៈអប់រំសុខភាពជាភាសារខ្មែរ

-រៀបចំលក្ខន្តិកៈសំរាប់ការផលិតសំភារៈដែលមានទាំងអស់៥ ចំណុចសំរាប់ការផលិតព្រមទាំងបានដាក់ឲ្យទៅខាងផ្នែកលទ្ធកម្មសំរាប់ធ្វើការដេញថ្លៃ។ក្នុងលក្ខន្តិកៈមានសំរាប់ការផលិតផ្ទាំងរូបភាព២រូបភាពបត់និងបដាប្លាស្ទីក២ផ្ទាំងមានខ្លឹមសារជំរុញឲ្យ ប្រជាជនស្វែងរកសេវាព្យាបាលបានត្រឹមត្រូវ ការប្រើប្រាស់ថ្នាំនិងវិធានការណ៏បង្ការ។

ខាងក្រោមនេះគឺជាតារាងដែលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានធ្វើការផ្សាយការផលិតសំភារៈសំរាប់អប់រំ ជូនដល់ សហគមន៏មួយចំនួនដូចខាងក្រោម :

| Nb | Name | Strength | Quantity | Budget |
|---|---|---|---|---|
| **I- TV and Radio Broadcasting** | | | | |
| 1 | CD song | item | 5 | GF SSF |
| 2 | Video spot | item | 5 | GF SSF |
| 3 | Video Drama | item | 1 | GF SSF |
| 4 | Radio Drama | item | 1 | GF SSF |
| 5 | Redio spots | item | 5 | GF SSF |
| **II- IEC material** | | | | |
| 1 | Cap | Piece | 21,000 | GF SSF |
| 2 | Desk calendar for year 2011 | Piece | 11,500 | GF SSF |
| 3 | Flipchart: Message ( what is malaria disease ? ) | Piece | 1,000 | GF SSF |
| 4 | Kit of bed net impregnated materials | Kit | 770 | GF SSF |
| 5 | Leaflet: Printed with key message and picture | sheet | 1,000 | GF SSF |
| 6 | Newsletter | sheet | 8,480 | GF SSF/R6 |
| 7 | Note book | book | 5,396 | GF SSF |
| 8 | Poster | poster | 15,000 | GF SSF |
| 9 | Printing plastic bag | unit | 287,500 | GF R2 RCC |
| 10 | Priting books on prevention | book | 11,000 | GF SSF |
| 11 | Rain Coat | Piece | 1,000 | GF SSF |
| 12 | Recording book for VHV | book | 5,396 | GF SSF |
| 13 | Tshirt color dark blue | Piece | 37,000 | GF SSF |
| 14 | Wall calendar for 2011 | Piece | 11,500 | GF SSF |

**ខ- ការផលិតសំភារៈអប់រំសុខភាពដោយបណ្តាក្រសួងនិងអង្គការជាដៃគូៈ**

ផ្នែកអប់រំសុខភាពបានសហការណ៏យ៉ាងជិតស្និទ្ធជាមួយនិងបណ្តាក្រសួងនិងអង្គការជាដៃគូក្នុងការផលិតសំភារៈនិងទទួលខុសត្រូវលើការឆែកនិងពិនិត្យសារឡើងវិញលើសំណៅដែលក្រសួងនិងអង្គការជាដៃគូបានផ្ញើរមកទាក់ទងនិងការងារបច្ចេកទេស។

សំភារៈដែលបានផ្ញើរមកផ្នែកអប់រំសុខភាពមានដូចជា វីដេអូស្ពុត ស្ពតវិទ្យុ រឿងល្ខោនវិទ្យុ ចំរៀង អាវយឺត មួក ឬសំភារៈផ្សេងៗទៀតជាច្រើនមុខទៀត។

**២-ពង្រឹងសេវាកម្មអប់រំសុខភាពជូនដល់ថ្នាក់ខេត្តស្រុកប្រតិបត្តិនិងមណ្ឌលសុខភាពតាមរយៈបណ្តុះបណ្តាល**

**ក- វគ្គបណ្តុះបណ្តាលគ្រូបង្គោលដោយកម្មវិធីជាតិៈ**

- ផ្នែកអប់រំសុខភាពបានបញ្ចប់ការកែសំរួលឡើងវិញចំពោះសៀវភៅណែនាំការបណ្តុះបណ្តាល គ្រូបង្គោលស្តីពីការអប់រំសុខភាពជម្ងឺគ្រុនចាញ់ដែលមានសន្លឹកទាំងអស់ចំនួន៨២ទំព័រចែកចេញជាពីរ

ផ្នែកគឺៈវិធីសាស្រ្តនៃការបង្រៀននិងឯកសារមេរៀន។មានគំពាងយកទៅបែងចែកដល់ថ្នាក់ខេត្តនិងស្រុកប្រតិបត្តិ។បានរៀបចំការបណ្តុះបណ្តាលវគ្គអប់រំសុខភាពគ្រូបង្គោលដល់សិក្ខាកាមដែលមកពីមន្ទីរសុខាភិបាលខេត្តក្រុងទាំង១៦មានដូចជាខេត្តៈ បាត់តំបង ពោធិសាត់ កំពង់ឆ្នាំង បន្ទាយមានជយ័ ប៉ៃលិន ឧត្តរមានជយ័ កំពត កែប តាកែវ កំពង់សោម កំពង់ស្ពឺ មណ្ឌលគីរី ស្ទឹងត្រែង កំពង់ចាម កំពង់ធំ សៀមរាប។ ទីកន្លែង បណ្តុះបណ្តាលមានពីខេត្តគឺខេត្តបាត់តំបងនិងខេត្តកំពង់ឆ្នាំង។លទ្ធផលនៃការសិក្សា មានអ្នកចូលរួមចំនួន៧៤នាក់(ទាំង២វគ្គ)ក្នុងមួយវគ្គៗមានរយៈពេល២ថ្ងៃ ។ វគ្គទី១លទ្ធផលមុនការសិក្សា៨៧%ក្រោយការសិក្សា៩៤%ពិន្ទុកើនក្រោយការសិក្សា៧%។ចំណែកវគ្គទី២លទ្ធផលមុនការសិក្សា៧៧%និងក្រោយការសិក្សា៨៦%ពិន្ទុកើនក្រោយការសិក្សាបាន៩%។

- បានចូលរួមបណ្តុះបណ្តាលគ្រូបង្គោលនៃក្រសួងមហាផ្ទៃនៅរាជធានីភ្នំពេញមានរយៈពេល ៣ថ្ងៃៈ មានសិក្ខាកាមចូលរួមចំនួន៣២នាក់មកពីខេត្តទាំង១១ដូចជាខេត្ត (កោះកុង ពោធិសាត់ បាត់ដំបងប៉ៃលិន បន្ទាយមានជយ័ សៀមរាប ក្រចេះ ស្ទឹងត្រែង រតនគីរី ឧត្តមានជយ័ ព្រះវិហារ)។ លទ្ធផលមុនការសិក្សា៥៧%និងក្រោយការសិក្សា៨៥%ពិន្ទុកើនក្រោយការសិក្សា២៨% ដែលជាមោទនភាពក្នុងការបណ្តុះបណ្តាល។
- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់គ្រូគរុកោសល្យដែលអញ្ជើញមកពីខេត្តទាំង១៨ៈទីតាំងបង្រៀននៅខេត្តព្រះសីហនុដែលមានសិក្ខាកាមទាំងអស់ចូលរួមចំនួន៦០នាក់ដែលរៀបជាពីរវគ្គ។ វគ្គទី១មានសិក្ខាកាមចូលរួមចំនួន២២នាក់លទ្ធផលមុនការសិក្សា៥០%និងក្រោយការ សិក្សា៨៦%ពិន្ទុ កើនបាន៣៦%។
 វគ្គទី២មានសិក្ខាកាមចូលរួមចំនួន៣១នាក់លទ្ធមុនការសិក្សា៥៤%និងក្រោយការសិក្សា៨៩%ពិន្ទុកើនក្រោយការសិក្សា៣៥%។អង្គការ*FHI360* បានអញ្ជើញបុគ្គលិកផ្នែកអប់រំសុខភាពឲ្យទៅបណ្តុះបណ្តាល លើការប្រើប្រាស់ក្រដាស់សំណួរសំរាប់ការធ្វើការសិក្សាស្រាវជ្រាវបែបគុណភាពដល់ក្រុមអ្នកយកទិន្នន័យ ដើម្បីធ្វើការស្រាវ ជ្រាវជាមួយនិងអ្នកចំណាកស្រុក។

## ខ-វគ្គបណ្តុះបណ្តាលគ្រូបង្គោលដោយកម្មវិធីគ្រុនចាញ់ថ្នាក់ខេត្តៈ

១. ខេត្ត៨ដែលបានធ្វើការបណ្តុះបណ្តាលបន្តទៅមន្ត្រីមណ្ឌលសុខភាពដូចជាខេត្ត
បន្ទាយមានជយ័ បាត់ដំបង តាកែវ កំពង់ឆ្នាំង កំពង់ចាម ព្រះសីហនុ ឧត្តរមានជយ័ កំពង់ស្ពឺ ចំណែកខេត្តដែលនៅសល់មិនទាន់បានធ្វើការបណ្តុះបណ្តាលលទ្ធផលនៃការបណ្តុះបណ្តាលមានៈ

| ល.រ | ខេត្ត | ចំនួនអ្នកចូលរួម | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | ពិន្ទុមុនការសិក្សា | ពិន្ទុក្រោយការសិក្សា | ប្រភពថវិការ |
|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជយ័ | ៨ | ២៩-០៨-១១ | 30-០៨-១១ | ៨៨% | ៨៧% | ជុំទី៩ |
| ២ | តាកែវ | ៤ | ១៩-១២-១១ | ១៩-០៨-១១ | ៨២% | ៩៧% | ជុំទី៩ |
| ៣ | កំពង់ឆ្នាំង | ៨ | ០៦-១០-១១ | ០៧-១០-១១ | ៩០% | ៩៤% | ជុំទី៩ |
| ៤ | កំពង់ចាម | ៦ | ២៩-០៨-១១ | 30-០៨-១១ | ៧១% | ៩៤% | ជុំទី៩ |
| ៥ | កំពង់ចាម | ១០ | ១២-០៩-១១ | ១៣-០៩-១១ | ៨៨% | ៩២% | ជុំទី៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | បាត់តំបង | ៩ | ០៨-០៩-១១ | ០៩-០៩-១១ | ៧៣% | ៩២% | ជុំទី៩ |
| ៧ | ខេត្តព្រះសិហនុ | ៩ | ៣០-០៨-១១ | ៣១-០៨-១១ | ៥៨% | ៨០% | ជុំទី៩ |
| ៨ | ឧត្តរមានជយ័ | ៩ | ១១-១០-១១ | ១២-១០-១១ | ៨៥% | ៩១% | ជុំទី៩ |

២.១២ខេត្តដែលបានធ្វើការបណ្តុះបណ្តាលវគ្គអប់រំសុខភាពដល់អ្នកស្មគ្រ័ចិត្តភូមិមានដូចជាៈពោធិសាត់ កំពង់ចាម កំពង់ធំ បាត់ដំបងនិងកំពង់ស្ពឺ លើកលែងតែខេត្ត៣ មិនទាន់បានធ្វើគឺ ខេត្តមណ្ឌលគីរី សៀមរាប ស្ទឹងត្រែង នឹងកំពុងតែរៀបចំ។

| ល.រ | ខេត្ត | មណ្ឌលសុខភាព | ចំនួនអ្នកចូលរួម | ថ្ងៃខែឆ្នាំបណ្តុះបណ្តាល |
|---|---|---|---|---|
| ១ | ប៉ៃលិន | ៦ | ១៣០ | វិច្ឆិការ ធ្នូ |
| ២ | ព្រះសីហនុ | ៩ | ១៧៣ | កញ្ញា -ធ្នូ |
| ៣ | បន្ទាយមានជយ័ | ៤ | ៦៣ | កញ្ញា |
| ៤ | កំពត | ៦ | ៧៧ | សីហា វិច្ឆិការ |
| ៥ | ឧត្តរមានជយ័ | ១២ | ២០១ | វិច្ឆិការ ធ្នូ |
| ៦ | កែប | ៤ | ៥៦ | តុលា |
| ៧ | តាកែវ | ៤ | ៩៦ | ធ្នូ |
| ៨ | កំពង់ឆ្នាំង | ៤ | ៨៨ | តុលា ធ្នូ |
| ៩ | ពោធិសាត់ | ៩ | ១៧១ | កក្កដា កញ្ញា |
| ១០ | កំពង់ចាម | ២០ | ៤៧៧ | កញ្ញា |
| ១១ | កំពង់ធំ | ៨ | ៧៨ | ធ្នូ |
| ១២ | បាត់តំបង | ៦ | ១៩៦ | សីហា កញ្ញា |
| **សរុប** | | **៩២** | **១៨០៦** | |

## ៣.តាមដាននិងគាំទ្រការអភិបាលការងារអប់រំសុខភាព

### ៣.ក-តាមដានការវគ្គបណ្តុះបណ្តាលបំប៉នដោយថ្នាក់ខេត្តៈ

-មានបង្កើតជាទំរង់ត្រួតពិនិត្យសំរាប់តាមដាននិងវាយតំលៃការបណ្តុះបណ្តាលទៅលើការបណ្តុះបណ្តាលដោយខេត្តឬដោយអង្គការជាដៃគូក្នុងគោលបំណងបំពេញបន្ថែមនូវចំនុចខ្វះខាតដែលមាន។

-ធ្វើការតាមដានជាបន្តទៅលើការបណ្តុះបណ្តាលពីការអប់រំសុខភាពជម្ងឺគ្រុនចាញ់ដែលរៀបចំ ឡើងដោយថ្នាក់ខេត្តជាពិសេសការបណ្តុះបណ្តាលលើអ្នកស្មគ្រ័ចិត្តនិងមេភូមិនិងបញ្ជាក់ឲ្យច្បាស់ថាមានការបណ្តុះបណ្តាល។

-បានចុះធ្វើការតាមដានវគ្គបណ្តុះបណ្តាលអប់រំសុខភាពគ្រូបង្រៀនទូទាំងប្រទេសដែលរៀបចំ ដោយនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំយុវជននិងកីឡាអំពីបច្ចេកទេសនៃកាបណ្តុះបណ្តាលនិងខ្លឹមសារទាក់ទងទៅនិងជម្ងឺគ្រុនចាញ់នៅសាលាគរុកោសល្យតំបន់ក្នុងខេត្ត៣គឺ ៖ ខេត្តសៀមរាបដែលគ្របដណ្តប់៦ខេត្តគឺៈ កំពង់ធំ ឧត្តរមានជយ័ ព្រះវិហារ បាត់តំបងបន្ទាយមានជយ័ និងប៉ៃលិន។ ខេត្តកំពង់ស្ពឺ គ្របដណ្តប់៤ខេត្តគឺៈ ខេត្តកោះកុង កំពត កំពង់ស្ពឺ និងខេត្តពោធិសាត់។ ខេត្តក្រចេះគ្របដណ្តប់៥ខេត្តគឺៈខេត្តកំពង់ចាមក្រចេះស្ទឹងត្រែងរតនគីរី និងខេត្តមណ្ឌលគីរី។ យើងបានផ្តល់ការគាំទ្រលើការងារបច្ចកទេសក្នុងការបណ្តុះបណ្តាល។

### ៣.ខ- សិក្ខាសាលា និង យុទ្ធនាការផ្សព្វផ្សាយៈ

-នៅខែមិនាឆ្នាំ២០១១បានរៀបចំការប្រជុំ២ដងជាមួយBCCWorkingGroupដើម្បីពិភាក្សារ សារអប់រំសំរាប់ឆ្នាំ២០១១។ ក្នុងពេលនោះមានការចូលរួមពីក្រសួងពាក់ពន្ធ័និងអង្គការជាដៃគូបានមកពិភាក្សាគ្នានិងរកបានសារអប់រំ ដែលសំរាប់ការបង្ការការស្វែងរកការព្យាបាលនិងសំរាប់ សេវាឯកជន។

**គ- ការចុះអភិបាលលើសកម្មភាពអប់រំសុខភាពៈ**

-ការប្រជុំប្រចាំខែនៅមណ្ឌលសុខភាពជាមួយអ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិៈ

បានធ្វើអភិបាលកិច្ចនៅពេលប្រជុំប្រចាំខែនៅមណ្ឌលសុខភាពជាមួយអ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិនៅខេត្តតាមខេត្ត ទាំង១៦ ដូចជាៈខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កែប មណ្ឌលគិរី ឧត្តរមានជ័យ ពោធិសាត់ សៀមរាប ប៉ៃលិន តាកែវ ស្ទឹងត្រែង និង កំពង់សោម ។ ពេលនោះដែរយើងក៏បានពិភាក្សាលើការ ប្រើប្រាស់សំភារៈអប់រំសុខភាព ពិនិត្យឡើង វិញលើបញ្ជីរឈ្មោះ អ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិនិងការបំពេញ របាយការណ៏ប្រជុំប្រចាំខែណែនាំពីវិធីស្នើសុំគ្រាប់ថ្នាំព្រួនព្រមទាំងដោះស្រាយរាល់បញ្ហាដែលបានលើកឡើងនៅពេលប្រជុំ។

-អភិបាលការងារជាប្រចាំជាមួយនិងថ្នាក់ខេត្តក្នុងតំបន់គ្រុនចាញ់មានន័យថាបានបង្កើនការយល់ដឹងរបស់សហគមន៏កាន់តែប្រសើរឡើងចំពោះបញ្ហាជម្ងឺគ្រុនចាញ់។និងឈានទៅរកការផ្លាស់ប្តូរឥរិយាបថស្វែងរកការព្យាបាលបានត្រឹមត្រូវ។

-អង្កេតទៅលើសំភារៈអប់រំសុខភាពដោយការពិនិត្យសារឡើងវិញតាមរយៈរបាយការណ៏អ្នកស្មគ្រ័ចិត្តភូមិដែលមកប្រជុំនៅមណ្ឌលសុខភាព។

-ផ្នែកអប់រំសុខភាពក៏បានចុះទៅធ្វើការអង្កេតទៅលើការចាក់ផ្សាយតាមប៉ុស្តិ៏ទូរទស្សន៏និងវិទ្យុដែលចាក់ផ្សាយដោយថ្នាក់ខេត្ត។

-ការអភិបាលលើការងារអប់រំសុខភាពជាប្រចាំលើអ្នកអភិបាលជម្ងឺគ្រុនចាញ់,មន្រ្តីមណ្ឌលសុខភាពការអភិបាលលើការងារអប់រំសុខភាពជាប្រចាំលើអ្នកអភិបាលជម្ងឺគ្រុនចាញ់ខេត្តក្នុងតំបន់គ្រុនចាញ់ត្រូវបានអនុវត្តន៏ក្នុងគោលដៅផ្ទៀងផ្ទាត់ពីសកម្មភាពដែលអ្នកអភិបាលជម្ងឺគ្រុនចាញ់បានក្នុងគោលបំណងតាមដានសកម្មភាពនិងពង្រឹងទៅលើសកម្មភាពការងារខ្លះដែលអសកម្មដើម្បីកែរលំអរក៏ដូចជាការបង្កើនការលើកទឹកចិត្តដល់មន្រ្តីដែលធ្វើការងារនៅថ្នាក់មូលដ្ឋាន។ ការសាកសួរសំណួរខ្លះៗត្រូវបានសាកសួរដោយប្រើក្រដាស់សំណួរនិងមានការបំពេញបន្ថែមនូវចំនុចខ្វះខាតដូចជាការទុកដាក់ឯកសារក៏ការបំពេញរបាយការណ៏មិនបានត្រឹមត្រូវឬមិនមានតារាងបែងចែកសំភារៈជាដើម។

សកម្មភាពចុះអភិបាលពេលអ្នកស្មគ្រ័ចិត្តប្រជុំៈ ខេត្តដែលបានចុះចំនួន១៥ខេត្ត មាន១៦ស្រុកប្រតិបត្តិនិងមណ្ឌលសុខភាពចំនួន៣២។ ដែលខេត្តនីមួយៗត្រូវបានចុះអភិបាលចំនួន០១ទៅ០២ដង។

## ៤-ការសិក្សាស្រាវជ្រាវ តាមដាន និងវាយតំលៃ:

ការសិក្សាស្រាវជ្រាវបែបគុណភាពនៅខេត្តកំពត និងខេត្តបាត់តំបងក្នុងគោលបំណងប៉ាន់ប្រមាណចំណេះដឹងនិងឥរិយាបថរបស់គាត់ទាក់ទងទៅនឹងការបង្ការទំលាប់នៃការស្វែងរកការព្យាបាលនិងការធ្វើរោគវិនិច្ឆ័យរហ័សនៃជម្ងឺគ្រុនចាញ់។

គោលបំណងចំបងនៃការសិក្សាគឺចង់ធ្វើឲ្យកាន់តែប្រសើរឡើងចំពោះសំភារៈអប់រំសុខភាពដែលមានពីមុនមកតាមរយៈវិធីសាស្រ្តថ្មី។និងម៉្យាងវិញទៀតមានគោលបំណងកំណត់នូវទំលាប់ដែលជាបញ្ហាដើម្បីឆ្ពោះទៅការរៀបចំវិធីសាស្រ្តអប់រំសុខភាពថ្នាក់ជាតិឲ្យកាន់តែប្រសើរឡើង។

បានធ្វើការតាមដានចំណេះដឹងនិងការប្រព្រឹត្តលើជម្ងឺគ្រុនចាញ់ជាមួយនិងសហគមន៍និង អ្នកស្ម័គ្រចិត្តដោយប្រើក្រដាស់សំណួរនៅខេត្តទាំង៦មានដូចជាខេត្តៈកំពតតាកែវកែបកំពង់សោមកំពង់ឆ្នាំងនិងពោធិសាត់។ គោលបំណងនៃការធ្វើការតាមដាននេះគឺចង់ដឹងពីការយល់ដឹងរបស់ប្រជាជនដែលរស់នៅក្នុងតំបន់គ្រុនចាញ់មានការយល់ដឹងដល់កំរិតណាក្រោយពេលបានធ្វើអន្តរាគមន៍ជាច្រើនមកដូចជាមានការអប់រំសុខភាពតាមរយៈអ្នកស្ម័គ្រចិត្តភូមិតាមវិទ្យុទូរទស្សន៍និងតាមរយៈរូបភាពផ្សេងៗនិងតាមរយៈអង្គការជាដៃគូរផងដែរ។

| លរ | ខេត្ត | ចំនួនHC | ចំនួនភូមិ | ចំនួនVHV | ចំនួនអ្នកភូមិ |
|---|---|---|---|---|---|
| ១ | តាកែវ | ១ | ១០ | ២០ | ១០០ |
| ២ | កែប | ២ | ១០ | ២០ | ១០០ |
| ៣ | កំពត | ១ | ១០ | ២០ | ១០០ |
| ៤ | ព្រះសីហនុ | ១ | ១០ | ២០ | ១០០ |
| ៥ | កំពង់ឆ្នាំង | ១ | ១០ | ២០ | ១០០ |
| ៦ | ពោធិសាត់ | ១ | ១០ | ២០ | ១០០ |
| សរុប | | ៧ | ៦០ | ១២០ | ៦០០ |

### ៥-ពង្រឹងនិងលើកទឹកចិត្តសហគមន៍បន្ថែមលើការគ្រប់គ្រងជម្ងឺគ្រុនចាញ់និងទងឹបង្ការ

<u>១. ទិវាជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់៖</u>

បានរៀបចំទិវាជាតិប្រយុទ្ធ នឹង ជំងឺគ្រុនចាញ់ក្នុងខេត្តទាំង២០ លើកលែងតែ ខេត្ត កណ្តាលព្រៃវែងស្វាយរៀងនិងក្រុងភ្នំពេញ។ក្នុងឱកាសនោះដែរក៏មានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំនៃក្រសួងសុខាភិបាលដែលញាំងឱ្យកម្មវិធីនេះកាន់តែមានភាពអធឹកអធមអ្នកចូលរួមគឺមកពីគ្រប់សត្តាបណ្ណ័ពាក់ពន្ធដូចជាៈ សាលារៀន, ប៉ូលីស,កងទ័ព, អ្នកស្មគ្រ័ចិត្តប្រជាជននិងអាជ្ញាធរដែនដីមានចំនួនប្រហាក់ប្រហែលជា៦០០ទៅ១០០០នាក់តាមខេត្តនិមួយៗ។

<u>២.ការផ្សព្វផ្សាយ៖</u>

បានចាក់ផ្សាយពីវិធានការការពារជំងឺគ្រុនចាញ់ និងការស្វែងរកសេវាព្យាបាលបានត្រឹមត្រូវតាមប្រព័ន្ធផ្សព្វផ្សាយខេត្តទាំង២០ ដូចជាទូរទស្សន៍ វិទ្យុ ទូរទស្សន៍ខ្សែកាបឬតាមរយៈវីដេអូរ ចល័តដែលមានការរៀបចំជាកាលវិភាគនិងមានការចុះកុងត្រាជាមួយនិងក្រុមហ៊ុន។ការតាមដានសកម្មភាពចាក់ផ្សាយស្ពតទាំងវិទ្យុនិងទូរទស្សន៍របស់ថ្នាក់ខេត្តនិងការធ្វើវីដេអូរចល័តបានត្រូវធ្វើទន្ទឹមពេលការចាក់ផ្សាយកំណើរការ។

៣. សកម្មភាពផ្សេងៗ៖

- រៀបចំតារាងបែងចែកសំភារៈអប់រំសុខភាពដល់ខេត្តក្រុងទាំង២៤អង្គការនិងដៃគូនានា។
- បង្កើតកំណត់ហេតុជាពង្រាងសំរាប់ការធ្វើឲ្យមានចលនាចូលរួមពីសហគមន៍លើការងារប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់។

-រៀបចំពត៌មានសំរាប់ព្រឹត្តិបត្តិដែលមានការចេញផ្សាយរៀងរាល់ត្រីមាស។ពត៌ទទួលបានពីផ្នែកផ្សេងៗនិងអង្គការជាដៃគូ ជារួមមានពត៌មានទាក់ទងនិងការសិក្សាស្រាវជ្រាវការបណ្តុះបណ្តាលការធ្វើសិក្ខាសាលាហើយពត៌មាននេះក្រោយពេលរៀបចំហើយក៏មានការបែងចែកទៅបណ្តាក្រសួងមន្ទីរនិងអង្គការជាដៃគូ។

៤.ការសន្និដ្ឋានៈ

ការបណ្តុះបណ្តាលដើម្បីបង្កើនគុណភាពការងារអប់រំនៃគ្រូបង្គោល នៅតាមសហគមន៍ និងទទួលចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងការការពារការស្វែងរកការព្យាបាលនិងការប្រើប្រាស់សំភារៈអប់រំសុខភាពឱ្យចំទិសដៅគឺជាចំណែកមួយចូលរួមក្នុងការកាត់បន្ថយជម្ងឺគ្រុនចាញ់។ប្រជាជនមានការយល់ដឹងច្រើនជម្ងឺគ្រុនចាញ់កាត់បន្ថយធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន។

- ការចុះអភិបាលលើការងារអប់រំសុខភាពជាប្រចាំជាមួយ*PMS*និងស្រុកប្រតិបត្តព្រមទាំងមណ្ឌលសុខភាពក្នុងតំបន់គ្រុនចាញ់ត្រូវបានអនុវត្តន៏ក្នុងគោលដៅផ្តល់ចំណេះដឹងបន្ថែមដល់អ្នកកាន់កម្មវិធីគ្រុនចាញ់ដើម្បីឲ្យគាត់ឈានទៅរកការពង្រឹងសមត្ថភាពមន្ត្រីមូលដ្ឋានបន្តហើយម៉្យាងវិញទៀតក៏ជាកំលាំងចលករជំរុញនិងជាការលើកទឹកចិត្តដល់មន្ត្រីថ្នាក់មូលដ្ឋានផងដែរ។

## ៥.គ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាពរួមបញ្ចូលទាំងប្រពន្ធ័ព័ត៌មានសុខាភិបាលនិងការតាមដានព្រមទាំងការសម្របសម្រួលនានាដែលនឹងនាំឲ្យការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់មានគុណភាពខ្ពស់និងទទួលបានជោគជ័យ។

ប្រកបដោយប្រសិទ្ធភាពរួមបញ្ចូលទាំងប្រពន្ធ័ព័ត៌មានសុខាភិបាលនិងការតាមដានព្រមទាំងការសម្របសម្រួលនានាដែលនឹងនាំឲ្យការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់មានគុណភាពខ្ពស់និងទទួលបានជោគជ័យការគ្រប់គ្រងកម្មវិធីដើម្បីប្រកបអោយមានប្រសិទ្ធភាពគុណភាពខ្ពស់និងទទួលបានជោគជ័យ,មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ បានបង្កើតប្រពន្ធ័ព័ត៌មានសុខាភិបាលនិងការតាមដានព្រមទាំងមានការសិក្សាស្រាវជ្រាវរិះរកបេកកំហើញថ្មីៗស្របតាមលក្ខណៈវិទ្យាសាស្ត្របច្ចុប្បន្នដើម្បីបង្កើតយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការអនុវត្តយុទ្ធសាស្ត្រជាតិនៃការលុបបំបាត់ជំងឺគ្រុនចាញ់អោយអស់នាឆ្នាំ២០២៥។

### ៥.១.ផ្នែកអេពីដេមីសាស្ត្រ

អេពីដេមីសាស្ត្រជាផ្នែកមួយដែលទទួលបន្ទុកប្រមូល ទិន្នន័យវិភាគទិន្នន័យព្រមទាំងវាយតំលៃពីស្ថានភាពជំងឺគ្រុនចាញ់ទូទាំងប្រទេស។ប្រព័ន្ធរបាយការណ៍ប្រចាំខែនៅគ្រប់គ្រឹះស្ថានសុខាភិបាលទាំងអស់ត្រូវបានផ្ញើរមកក្រសួងសុខាភិបាលតាមរយៈស្រុកប្រតិបត្តិនិងមន្ទីរសុខាភិបាលខេត្តហើយផ្នែកអេពីដេមីសាស្ត្រប្រមូលពត៌មានទាំងនោះពីមន្ទីរសុខាភិបាលខេត្ត។ នាឆ្នាំ២០១១នេះ ផ្នែកអេពីដេមីសាស្ត្ររបស់មជ្ឈលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានអនុវត្តន៏ការងារនឹងសំរេចលទ្ធផលបានៈ

យោងតាមទិន្នន័យគ្រុនចាញ់ដែលយើងទទួលបានតាមរយៈប្រព័ន្ធពត៌មានក្នុងឆ្នាំ២០១១នេះនិងក្រោយការវិភាគយើងសង្កេតឃើញថាៈ

-ចំនួនករណីគ្រុនចាញ់ព្យាបាលសរុបនៅឆ្នាំ២០១១មានការកើនឡើងបន្តិច បើប្រៀបធៀបទៅនឹងឆ្នាំ២០១០។ក្នុងឆ្នាំ២០១១មាន៦០.៧៧០ករណីដែលក្នុងឆ្នាំ២០១០មានតែ៥៨.៦២១ករណី។បើគិតជាអត្រាភាគរយនៃការថយចុះនៅទូទាំងប្រទេសគឺ៧%បើប្រៀបធៀបទៅនឹងករណីព្យាបាលឆ្នាំ២០១០។

-ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលទាំងអស់មានការកើន ឡើងពីខេត្តមួយចំនួន ប្រៀបធៀបនឹងឆ្នាំ២០១០។អត្រាអាំងស៊ីដង់មានការកើនឡើងពី៤.១ភាគពាន់ក្នុងឆ្នាំ២០១០ដល់៤.៣ភាគពាន់ក្នុងឆ្នាំ២០១១។

-ចំនួនករណីគ្រុនចាញ់ធ្ងន់ធ្ងរសរុបទូទាំងប្រទេសពីគ្រប់មន្ទីរពេទ្យបង្អែកទាំងអស់មានការថយចុះប្រហែល ៣៣.៩%ប្រៀបធៀបនឹងឆ្នាំ២០១០ដែលគិតជាចំនួនករណីគឺពី៦៩៨ក្នុងឆ្នាំ២០១មកនៅ៤៣៤៧ ក្នុងឆ្នាំ២០១១។

-ចំនួនករណីស្លាប់ដោយគ្រុនចាញ់មានការថយចុះប្រហែល៣៧.៧% ប្រៀបធៀបនឹងឆ្នាំ២០១០ដែលគិតជាចំនួនករណីស្លាប់គឺមានការថយចុះពី១៥១នាក់ក្នុងឆ្នាំ២០១០ មកនៅត្រឹម៩៤នាក់ក្នុងឆ្នាំ២០១១។អត្រាស្លាប់នៃជំងឺគ្រុនចាញ់មានការថយចុះពី១.១មកនៅត្រឹម០.៦០ក្នុងចំណោមប្រជាជន១០០,០០០នាក់ក្នុងឆ្នាំ២០១០និង២០១១។

-សមាមាត្រស្លាប់នៃជំងឺគ្រុនចាញ់ធ្ងន់ធ្ងរទាំងអស់ក៏មានការថយចុះពី២.៣%ក្នុងឆ្នាំ២០១០មកនៅត្រឹ២.២% ក្នុងឆ្នាំ២០១១។

-ចំនួនករណីវិជ្ជមានពិនិត្យដោយមីក្រូទស្សន៍និងឌីបស្ទីកក៏មានការកើនឡើងពី៤៩.៣៥៥ក្នុងឆ្នាំ២០១០មកដល់៥៧,៤២៣ករណីក្នុងឆ្នាំ២០១១។

-សមាមាត្រនៃករណីវិជ្ជមានក្នុងចំណោមករណីព្យាបាលទាំងអស់មានការកើនឡើងពី ៨៤%ក្នុងឆ្នាំ ២០១០ដល់៩១%ក្នុងឆ្នាំ២០១១។ចំពោះសមាមាត្រនៃប្រភេទមេរោគគ្រុនចាញ់នៅឆ្នាំ២០១១គឺប្រភេទហ្វាល់ស៊ីប៉ារូម៤៦%, វីវ៉ាក់៣៧%និងចំរុះ១៧%។

-ចំពោះក្រុមអាយុដែលមានគ្រុនចាញ់ភាគច្រើនគឺចន្លោះពី១៥ទៅ៤៩ឆ្នាំដែលមានរហូត ដល់៣ភាគកណ្ដាលនៃករណីព្យាបាលនិងករណីវិជ្ជមានទាំងអស់ត្រូវបានរាយការណ៍ដែលមិនសូវ មានការខុសគ្នាខ្លាំងទេប្រៀបធៀបនឹងឆ្នាំ២០១០។

## ➢ ការបកស្រាយនិងការវាយតំលៃទូទៅពីស្ថានភាពជំងឺគ្រុនចាញ់នៅឆ្នាំ២០១១

ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលទាំងអស់មានការថយចុះនៅទូទាំងប្រទេសពីមួយឆ្នាំ ទៅមួយឆ្នាំរហូតដល់ឆ្នាំ២០០២ហើយកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០៣( ពី១១០,៧៦២ករណីឆ្នាំ២០០២មក១៣២,៧៦២ករណីឆ្នាំ២០០៣)ការកើនឡើងនេះគិតជាភាគរយប្រហែល១៦,៤ភាគរយ។ចំនួនករណីគ្រុនចាញ់មានការកើនឡើងដល់៦០,៧៧២ករណីក្នុងឆ្នាំ២០១១។

មួយចំណែកនៃការកើនឡើងនេះគឺបណ្ដាលមកពីការពង្រីកសកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់រហូតដល់តំបន់គ្រុនចាញ់ឆ្ងាយៗដាច់ស្រយាលហើយក៏អាចមកពីការគ្របដណ្ដប់នៃកម្មវិធីយ៉ាងធំទូលាយក្នុងឆ្នាំ២០១១។ការប្រើប្រាស់នូលមូលនិធិសមធម៌ដែលកំពុងដំណើរការនៅក្នុងខេត្តមួយចំនួនក៏ជាកត្តាមួយរួមចំណែកក្នុងស្ថានភាពនេះដែរ។ការថយចុះនៃសមាមាត្រករណីគ្រុនចាញ់ធ្ងន់ធ្ងរនិងករណីស្លាប់ដោយគ្រុនចាញ់ក្នុងឆ្នាំ២០១១នេះអាចអោយយើងកំណត់ដឹងថាគុណភាពនៃការព្យាបាលជំងឺគ្រុនចាញ់នៅតាមសេវាសុខភាពសាធារណៈត្រូវពង្រឹងថែមទៀតរួមជាមួយនឹងផែនការផ្ដល់ឱសថគ្រុនចាញ់បានគ្រប់សំរាប់ឆ្នាំ២០១១ជាពិសេសឱសព្យាបាលគ្រុនចាញ់ថ្មីប្រើនៅក្នុងតំបន់ទី១។វាក៏អាចមកពីការមកប្រើប្រាស់សេវាសុខាភិបាលសាធារណៈរបស់ប្រជាជនដែលរស់នៅក្នុងតំបន់គ្រុនចាញ់ដាច់ស្រយាលបានប្រសើរជាងមុន។ប្រពន្ធ័ដឹកជញ្ជូនជំងឺមកកាន់មន្ទីរពេទ្យបង្អែកពីភូមិឆ្ងាយៗលែងជាបញ្ហាចំបងដូចមុនទៀតហើយ។តាមការវិភាគពត៌មានគ្រុនចាញ់នៅតាមខេត្តបានបង្ហាញអោយឃើញថាស្ថានភាពជំងឺគ្រុនចាញ់មានការខុសប្លែកគ្នាពីខេត្តមួយទៅខេត្តមួយទៀត។ខេត្តមួយចំនួនធំមានករណីគ្រុនចាញ់ដែលបានព្យាបាលថយចុះយ៉ាងខ្លាំងប្រៀបធៀបនឹងឆ្នាំ២០១០។ភាពខុសគ្នានេះអាចបណ្ដាលមកពីលក្ខណ្ឌ័ភូមិសាស្ត្រខុសគ្នារួមទាំងកត្តាមនុស្សទឹកភ្លៀងដង់ស៊ីតេនៃព្រៃឈើចលនាប្រជាជននិងសកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ផងដែរ។ការថយចុះនៃ

ចំនួនករណីគ្រុនចាញ់ធ្ងន់ធ្ងរនិងករណីស្លាប់ក្នុងឆ្នាំ២០១១នេះអាចបញ្ជាក់ពីគុណភាពនៃការព្យាបាលមានភាពល្អប្រសើរ។

សមាមាត្រករណីវិជ្ជមានក្នុងចំណោមករណីព្យាបាលមានការកើនឡើងពី៤២%ទៅ៧៨%ចាប់ពីឆ្នាំ២០០២ដល់២០០៦ហើយមានការកើនឡើងនៅឆ្នាំ២០១១(៩១%)ដែលអាចបញ្ជាក់ពីសេវាមន្ទីរពិសោធន៍និងការធ្វើរោគវិនិច្ឆ័យកាន់តែប្រសើរ។ ដោយសារទិន្នន័យនេះយើងបានទទួលតែពីប្រពន្ធ័ព័ត៌មានសុខាភិបាលសាធារណៈធ្វើអោយយើងពិបាកធ្វើការបកស្រាយ។ទោះជាយ៉ាងនេះក៏ដោយ,ក៏ទិន្នន័យនេះមានសារៈសំខាន់ណាស់សំរាប់កម្មវិធីជាតិទាំងមូលដើម្បីបង្កើនគុណភាពនៃរបៀបចុះបញ្ជីជាពិសេសនៅសេវាពិគ្រោះជំងឺក្រៅសំរាកពេទ្យនិងមន្ទីរពិសោធន៍។

តារាងទី១ ៖ចំនួនករណីគ្រុនចាញ់, ស្លាប់និងអត្រាស្លាប់និងអត្រាអាំងស៊ីដង់ក្នុង ចំណោមប្រជាជន១០០០នាក់ , ឆ្នាំ១៩៩៦-២០១១នៅក្នុងប្រទេសកម្ពុជា៖

| ឆ្នាំ | ចំនួន ករណី | ចំនួនកញ្ចក់ ឈាមវិជ្ជមាន | ចំនួនឌីប ស្ទីកវិជ្ជមាន | ករណី ស្លាប់ | CFR % | IR per 1000 |
|---|---|---|---|---|---|---|
| 1996 | *107265* | *80691* | *N/A* | *741* | 0.69 | 9.5 |
| 1997 | *170387* | *88029* | *N/A* | *865* | 0.51 | 15.0 |
| 1998 | *140843* | *58874* | *N/A* | *621* | 0.44 | 12.4 |
| 1999 | *139107* | *58478* | *6201* | *891* | 0.64 | 12.3 |
| 2000 | *129167* | *51320* | *11122* | *608* | 0.47 | 11.4 |
| 2001 | *115614* | *42150* | *11451* | *476* | 0.41 | 9.6 |
| 2002 | *110762* | *38048* | *8854* | *457* | 0.41 | 8.6 |
| 2003 | *132571* | *42227* | *29031* | *492* | 0.37 | 10.26 |
| 2004 | *101857* | *37389* | *22356* | *382* | 0.38 | 7.5 |
| 2005 | *74185* | *26914* | *22522* | *296* | 0.40 | 5.5 |
| 2006 | *100943* | *33010* | *45686* | *396* | 0.39 | 7.2 |
| 2007 | *59848* | *22081* | *20437* | *241* | 0.40 | 4.2 |
| 2008 | *58887* | *20347* | *21777* | *209* | 0.35 | 4.1 |
| 2009 | *83777* | *24999* | *39596* | *279* | 0.33 | 6.22 |
| 2010 | *56,217* | *13,545* | *32,556* | *135* | 0.24 | 4.07 |
| 2011 | *62,770* | *13,792* | *43,631* | *94* | 0.13 | 4.32 |

*Reported at public health facilities through health Information System*

**Note: CFR% : Case Fatality Rate of total treated cases , IR: Incidence Rate*



# of malaria tested cases, treated cases and confirmed cases, 2000 to 2011, Cambodia
Tested cases
Treated cases
Confirmed cases
Source: Epidemiology Unit,CNM, 31 Jan 2012
Number of cases
250000
200000
150000
100000
50000
0
2000: 122555, 129167, 62442
2001: 145619, 115614, 53601
2002: 133921, 110762, 46902
2003: 160354, 132571, 71265
2004: 150952, 101857, 59745
2005: 147782, 74185, 49436
2006: 197050, 100943, 78696
2007: 135731, 59848, 42518
2008: 130995, 58887, 42124
2009: 191674, 83777, 64595
2010: 178364, 56217, 46101
2011: 216712, 62770, 57423




# of Malaria treated cases, Severe cases and Deaths, 2000 to 2011 in Cambodia
Source: Epidemiology Unit,CNM, 31 Jan 2012
Treated cases
Severe cases
Deaths
Number of cases
Number of deaths
140000
120000
100000
80000
60000
40000
20000
0
700
600
500
400
300
200
100
0
2000: 129167, 6207, 608
2001: 115614, 5453, 476
2002: 110762, 4214, 457
2003: 132571, 4936, 492
2004: 101857, 3720, 382
2005: 74185, 2560, 296
2006: 100943, 4392, 396
2007: 59848, 2648, 241
2008: 58887, 2755, 209
2009: 83777, 4045, 279
2010: 56217, 2484, 135
2011: 62770, 2727, 94




Source: Epidemiology Unit,CNM, 31 Jan 2012




Source: Epidemiology Unit,CNM, 31 Jan 2012

**Malaria Mortality in Cambodia, 2000 to 2011**




Source: Epidemiology Unit,CNM, 31 Jan 2012

- **របាយការណ៍បណ្តុះបណ្តាលនៃផ្នែកអេពីដេមីសាស្រ្តឆ្នាំ២០១១**

ការគ្រប់គ្រងទិន្នន័យគ្រុនចាញ់គឺជាឧបករណ៍ដ៏សំខាន់សំរាប់ការសំរេចចិត្តក្នុងការវាយតំលៃស្ថានភាពបច្ចុប្បន្ននៃជំងឺគ្រុនចាញ់។ប៉ុន្តែសមត្ថភាពរបស់មន្រ្តីជំនាញពិសេសនៅថ្នាក់ខាងក្រោមចំពោះការគ្រប់គ្រងទិន្នន័យនិងលក្ខណៈគ្រឹះនៃការធ្វើវិភាគទិន្នន័យនៅតែមានគំរិតទាបនៅឡើយ។ដើម្បីបង្កើនសមត្ថភាពបុគ្គលិកអោយកាន់តែប្រសើរឡើងជាពិសេសអ្នកដែលទទួលបន្ទុកផ្នែកគ្រប់គ្រងទិន្នន័យលក្ខណៈគ្រឹះនៃការវិភាគទិន្នន័យផ្នែកសុច្ចនាករជំងឺគ្រុនចាញ់ផ្នែកអេពីដេមីសាស្រ្តនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្រ្តនិងបាណកសាស្រ្តបានលើកគំរោងស្នើសុំទៅមូលនិធិសកលនូវសកម្មភាពវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងទិន្នន័យការបណ្តុះបណ្តាលផ្នែកអេពីដេមីសាស្រ្តនិងការគ្រប់គ្រងទិន្នន័យតាមរយៈប្រពន្ធ័ផែនទីភូមិសាស្រ្ត។អាស្រ័យហេតុនេះនៅក្នុងឆ្នាំ២០១១ការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងទិន្នន័យតាមរយៈប្រពន្ធ័ផែនទីភូមិសាស្រ្តត្រូវបានរៀបចំឡើងដោយផ្នែកអេពីដេមីសាស្រ្តរួមសហការជាមួយផ្នែកសិក្សាស្រាវជ្រាវនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ជូនដល់មន្រ្តីជំនាញទាំងអស់នៅមន្ទីរសុខាភិបាលស្រុកប្រតិបត្តិនិងមន្ទីរពេទ្យបង្អែក។

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះមានៈ

-ផ្តល់ចំណេះដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងទិន្នន័យ

-ពង្រឹងប្រពន្ធ័តាមដានជំងឺនៅថ្នាក់ក្រោម

-ផ្តល់នូវគោលការណ៍គ្រឹះនៃការគ្រប់គ្រងទិន្នន័យនៅថ្នាក់ខេត្តនិងថ្នាក់ស្រុកប្រតិបត្តិ

-ដើម្បីណែនាំការប្រើប្រាស់កម្មវិធីប្រពន្ធ័ផែនទីភូមិសាស្រ្តថ្មី៤.៣ សំរាប់ប្រើប្រាស់លើប្រពន្ធ័ទិន្នន័យជំងឺគ្រុនចាញ់នៅថ្នាក់ក្រោម

-ផ្តល់នូវវិធីសាស្រ្តក្នុងការបង្ហាញទិន្នន័យវិភាគទិន្នន័យនិងបកស្រាយទិន្នន័យដោយប្រើប្រាស់កម្មវិធី ប្រពន្ធ័ផែនទីភូមិសាស្រ្តនិងឧបករណ៍អេពីដេមីសាស្រ្ត។

-ផ្តល់នូវចំណេះដឹងជាមូលដ្ឋានក្នុងការសង្ខេបទិន្នន័យនិងវិភាគទិន្នន័យទៅតាមទិន្នន័យជាក់ស្តែងដែលមាន ស្រាប់ដើម្បីបង្ហាញលទ្ធផលដល់ការសំរេចចិត្តអោយបានត្រឹមត្រូវ

-ពង្រឹងសមត្ថភាពមន្ត្រីសុខាភិបាលថ្នាក់ក្រោមក្នុងការបង្ហាញនិងវិភាគទិន្នន័យគ្រុនចាញ់ តាមរយៈ ប្រពន្ធ័ផែនទីភូមិសាស្រ្តដើម្បីកំណត់នូវការធ្វើអន្តរាគមន៍និងធនធានតំរូវការ។

ប្រធានបទសំខាន់ៗនៃវគ្គបណ្តុះបណ្តាលគឺការគ្រប់គ្រងទិន្នន័យនិងការប្រើប្រាស់ឧបករណ៍របស់កម្មវិធីប្រពន្ធ័ផែនទីភូមិសាស្រ្ត៤.៣។ប្រធានបទលំអិតដែលបានបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាលគឺចែកចេញជាពីរផ្នែកធំៗគឺរបៀបប្រើប្រាស់ប្រពន្ធ័ផែនទីភូមិសាស្រ្ត៤.៣និងការគ្រប់គ្រងទិន្នន័យតាមប្រពន្ធ័ផែនទីភូមិសាស្រ្ត៤.៣។ ក្នុងផ្នែកទី១យើងបានណែនាំអំពីរបៀបបង្ហាញសុច្ចនៈករទាំងអស់ដែលមាននៅលើផែនទីនិងផ្នែកទី២យើងបាន ណែនាំអំពីរបៀបបញ្ចូលទិន្នន័យជាក់ស្តែងរបស់ថ្នាក់ខេត្តនិងស្រុកប្រតិបត្តិនិងមណ្ឌលសុខភាពនៅលើផែនទីនិងវិធីផ្សេងៗក្នុងការយកទិន្នន័យពីខាងក្រៅចូលផ្ទុកនៅក្នុងប្រពន្ធ័ផែនទីភូមិសាស្រ្ត៤.៣។នៅក្នុងមេរៀននៃវគ្គបណ្តុះបណ្តាលនីមួយៗយើងបានបែងចែកជាបុគ្គលនិងជាក្រុមអនុវត្តដើម្បីពិភាក្សានិងធ្វើលំហាត់សាកល្បងដើម្បីស្វែងរកចំនុចពិបាករបស់មេរៀននិងដោះស្រាយនូវចំនុចពិបាកទាំងនោះ។ការបង្ហាញលទ្ធផលពីកិច្ចការលំហាត់ត្រូវបានធ្វើឡើងដោយក្រុមនីមួយៗនិងពិភាក្សាដើម្បីកែតំរូវពីក្រុមផ្សេងទៀត។

បន្ទាប់ពីបញ្ចប់មេរៀននីមួយៗការរំលឹកឡើងវិញនិងការប្រើប្រាស់ទិន្នន័យជាក់ស្តែងរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ត្រូវបានដាក់បញ្ចូលយកមកអនុវត្ត។ចំពោះផ្នែកគ្រប់គ្រងទិន្នន័យការអនុវត្តជាច្រើនទៀតអំពីរបៀបបញ្ចូលសុច្ចនៈករជំងឺគ្រុនចាញ់សំរាប់ថ្នាក់ខេត្តស្រុកប្រតិបត្តិមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពគឺជាចំនុចដែលមានសារៈសំខាន់បំផុតនៃវគ្គបណ្តុះបណ្តាល។ ក្នុងឆ្នាំ២០១១វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កម្មវិធីប្រពន្ធ័ភូមិសាស្រ្តត្រូវបានធ្វើឡើងក្នុងខេត្តចំនួន៦ដែលមានខេត្តសៀមរាបដែលមានអ្នកចូលរួមចំនួន៣០រូបខេត្តបន្ទាយមានជ័យដែលមានអ្នកចូលរួមចំនួន៣៥រូបខេត្តព្រះសីហនុដែលមានអ្នកចូលរួមចំនួន៣០រូបខេត្តបាត់ដំបងដែលមានអ្នកចូលរួមចំនួន៣៣រូបខេត្តកំពតដែលមានអ្នកចូលរួមចំនួន៣០រូបនិងខេត្តកំពង់ចាមដែលមានអ្នកចូលរួមចំនួន៣០រូប។ ចំពោះលក្ខណ៍នៃការជ្រើសរើសសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលគឺមន្ត្រីសំខាន់ៗដែលមកពីកម្មវិធីគ្រុនចាញ់ ប្រពន្ធ័ព័ត៌មានសុខាភិបាលការិយាល័យបច្ចេកទេសដែលទទួលបន្ទុកលើទិន្នន័យជំងឺគ្រុនចាញ់របស់មន្ទីរសុខាភិបាលការិយាល័យស្រុកប្រតិបត្តិនិងមន្ទីរពេទ្យបង្អែក។

ការវាយតំលៃនៃវគ្គសិក្សានីមួយៗបានផ្អែកលើលទ្ធផលពិន្ទុនៃសំនួរសរសេរសាកល្បងមុននិងក្រោយវគ្គសិក្សា។ចំពោះមធ្យមភាគនៃពិន្ទុសាកល្បងមុននិងក្រោយវគ្គសិក្សាមានការប្រែប្រួលខុសគ្នាខ្លះពីខេត្តមួយទៅខេត្តមួយទៀត។មធ្យមភាគសរុបនៃការកើនឡើងពិន្ទុបាន២០,៦០ភាគរយចំពោះវគ្គសិក្សាទាំងអស់នៅក្នុងខេត្តទាំង៦ខាងលើ។

តារាងពិន្ទុលំអិតនៃលទ្ធផលពិន្ទុមុននិងក្រោយវគ្គសិក្សាតាមខេត្តនីមួយៗមានដូចក្នុងតារាងខាងក្រោមៈ

**លទ្ធផលពិន្ទុវាយតំលៃមុននិងក្រោយវគ្គសិក្សាការគ្រប់គ្រងទិន្នន័យតាមភូមិសាស្រ្តឆ្នាំ២០១១**

| ឈ្មោះខេត្ត | % ពិន្ទុមុនការសិក្សា | %ពិន្ទុក្រោយវគ្គសិក្សា | % កំណើនពិន្ទុ |
|---|---|---|---|
| ខេត្តកំពង់ចាម | ៣៤,៥០ | ៥៥,៧៥ | ២១,២៥ |
| ខេត្តកំពត | ៣១,៦៧ | ៥៤,៤២ | ២២,៧៥ |
| ខេត្តព្រះសីហនុ | ៣៨,០៨ | ៥៩,៧៥ | ២១,៦៧ |
| ខេត្តសៀមរាប | ៣៥,៧៥ | ៥១,៧៥ | ១៦,០០ |

| | | | |
|---|---|---|---|
| ខេត្តបាត់ដំបង | ៣៧,០៥ | ៥៦,៦៧ | ១៩,៦២ |
| ខេត្តបន្ទាយមានជ័យ | ៤០,៦៩ | ៦២,៩៩ | ២២,២៩ |
| មធ្យមភាគសរុប | ៣៦,២៩ | ៥៦,៨៩ | ២០,៦០ |

## ៥.២. ផ្នែកសិក្សាស្រាវជ្រាវ:

### ៥.២.១.ការសិក្សាស្រាវជ្រាវអំពីភាពស៊ាំមេរោគគ្រុនចាញ់ទៅនឹងថ្នាំ DHA-PIP និង A+M

ការសិក្សាស្រាវជ្រាវអំពីភាពស៊ាំគ្រុនចាញ់ DHA-PIP និង A+M បានធ្វើឡើងនៅ ប៉ៃលិន វាលវែង រវៀង និង ស្នួល ។ ក្នុងរយះពេលចាប់ពីខែ០៦ឆ្នាំ២០១១ និង០២ ឆ្នាំ២០១២យើងរើសបានអ្នកជំងឺបានចំនួន២៩ នាក់ នៅប៉ៃលិន៤៤ នាក់នៅវាលវែង ៦១ នាក់នៅរវាង និង ៦០នាក់នៅស្នួល ។ អត្រាព្យាបាលជោគជ័យរបស់ A+M គឺ ១០០% នៅប៉ៃលិន អត្រព្យាបាលជោគជ័យរបស់ DHA-PIP គឺ ៩២.៥% នៅវាលវែង ៩៦.៥% នៅរវាង និង ៩៦.៣% នៅស្នួល ។ អត្រាថ្ងៃទីបីវិជ្ជមានមានចំនួន៥១.៧% សំរាប់ A+M នៅប៉ៃលិន ហើយសំរាប់ DHA-PIPគឺ ៣៦.៤%វាលវែង៩.៨%នៅរវាងព្រះវិហារនិងនៅស្នួលខេត្តក្រចេះ។ទោះជាយ៉ាងនេះក៏ដោយយើងនៅតែបន្តការតាមដានមើលប្រសិទ្ធភាពរបស់ថ្នាំនេះអោយបានជាប់លាប់។សូមអានរបាយការណ៏លំអិតនៅឧបសម្ពន្ធ១ទំព័រទី៩៦ ។

### ៥.២.២ ការសិក្សាទៅលើជីវសាស្រ្តនិងបរិស្ថានសាស្រ្តនៅលើភ្នាក់ងារចំលង

បាណកសាស្រ្តនៅក្នុងសុខភាពសាធារណះគឺការសិក្សាទៅលើជីវសាស្រ្តនិងបរិស្ថានសាស្រ្តនៅលើភ្នាក់ងារចំលងដែលចំលងជំងឺគ្រុនចាញ់និងគ្រុនឈាមនិងមេរោគផ្សេងៗទៀត។ការសិក្សាអំពីបុគ្គលិកលក្ខណៈនៃការខាំកន្លែងសំរាកក្រោយការខាំអាយុរបស់របស់ភ្នាក់ងារចំលងដង់ស៊ីតេតាមម៉ោងនិងខែគឺជាសុច្ចនករក្នុងការបង្កើតនិងប្រតិបត្តនៅយុទ្ធសាស្រ្តដ៏មានប្រសិទ្ធិភាពក្នុងការបង្ក្រាបភ្នាក់ងារចំលងនៅក្នុងបរិស្ថានផ្សេងៗគ្នា។ហេតុដូចនេះការតាមដានបាណកសាស្រ្តការតាមដានអំពីភាពស៊ាំរបស់ថ្នាំបាណកឃាតដែលកំពុងប្រើប្រាស់នៅក្នុងតំបន់គ្រុនចាញ់គឺជាមានសារះសំខាន់។ការរួមបញ្ជូលពត័មានបាណកសាស្រ្តនិងផ្នែកដទៃទៀតគឺគន្លឹះសំខាន់សំរាប់កម្មវិធីជាតិប្រយុទ្ធជំងឺគ្រុនចាញ់ក្នុងការបង្កើតនៅយុទ្ធសាស្រ្តប្រសិទ្ធិភាពថ្មីៗសំរាប់ទប់ស្កាត់នឹងជំងឺគ្រុនចាញ់។

**១.ការសិក្សាបាណកសាស្រ្តនៅឆ្នាំ២០១១មាន:**

១.ការសិក្សាបាណកសាស្រ្តនៅតំបន់ដែលជាកន្លែងទេសចណ៏មានករណីគ្រុនចាញ់។
២.ការសិក្សាតាមដានអំពីភាពស៊ាំរបស់ថ្នាំបាណកឃាតដែលកំពុងប្រើប្រាស់នៅក្នុងតំបន់គ្រុនចាញ់នៅភាគឥសាននៃប្រទេស។
៣. ការសិក្សាសេរ៉ូសាស្រ្តក្នុងឆ្នាំទី២ផ្អែកលើសេរ៉ូសំណាកនៅក្នុងខេត្តពោធិសាត់និងសៀមរាប។
៤. ការសិក្សាបន្ថែមនៅក្រៅប្រទេសលើការគ្រប់គ្រងទិន្នន័យដល់បុគ្គលិកបាណកសាស្រ្ត។

**២.គោលបំណង**

**២.១.គោលបំណងទូទៅ:**

- ផ្តល់ពត៌មានបាណកសាស្រ្តដល់អ្នកធ្វើផែនការយុទ្ធសាស្រ្តដោយផ្អែកទៅលើសុច្ចនករចំលងនិងភាពស៊ាំជាមួយ
  ជាមួយថ្នាំបាណកឃាតរបស់ភ្នាក់ងារចំលងនៅក្នុងបរិយាកាសប្រែប្រួលបរិស្ថាន។
- ពង្រឹងនិងបង្កើនសមត្ថភាពបុគ្គលិកបាណកសាស្រ្ត។

## ២.២.គោលបំណងសំខាន់:

- តាមដានជីវបរិស្ថានវិទ្យារបស់ភ្នាក់ងារចំលងជំងឺគ្រុនចាញ់នៅក្នុងបរិយាកាសប្រែប្រួលបរិស្ថាននៃភាគឥសាននៃប្រទេសនិងកន្លែងទេសចណ៍មានករណីគ្រុនចាញ់។
- បន្តការតាមដានជាប្រចាំភាពស៊ាំរបស់ភ្នាក់ងារចំលងជាមួយថ្នាំបាណកឃាតកំពុងប្រើប្រាស់និងស្វែងរកនៅយន្តកម្មនៃភាពស៊ាំពេលករណីចាំបាច់។
- វាយតំលៃនៅចលនករចំលងរបស់ជំងឺគ្រុនចាញ់ជាមួយនិងយុទ្ធវិធីផ្សេងទៀតក្រៅពីការសិក្សាបាណកសាស្ត្រ។
- អត្តសញ្ញាណនៅចលនករចំលងរបស់ជំងឺគ្រុនចាញ់នៅតាមបណ្តោយព្រំដែនកម្ពុជានិងវៀតណាម។

សូមអានរបាយការណ៍លំអិតនៅឧបសម្ពន្ធ២ទំព័រទី ១១០

## ៥.៣.ភស្តុភានិងការផ្គត់ផ្គង់

ផ្នែកភស្តុភានិងការផ្គត់ផ្គង់នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ទទួលបន្ទុកធ្វើផែនការ,តំរូវការ,ការទទួល,ការចែកចាយ,ការតាមដានឱសថ,បរិក្ខារ,សំភារៈពេទ្យ,ប្រតិករ,មុងដែលសំរាប់ប្រើប្រាស់កម្មវិធីរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់អោយដំណើរការទទួលជោគជ័យ ។

### ៥.៣.១. ការងារលទ្ធកម្មដែលទាក់ទងជាមួយVPP Volunteer Pooling Procurement ( GF ) and UN AGENCY ( UNICEF, UNOPS, PSI/HQ )

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានទិញថ្នាំជ្រលក់មុង(LLITK)សំរាប់អង្គការបំរើសុខភាពប្រជាជនកម្ពុជា(PSI/CNM)ចំនួន ១,៨៧០,០០០ គីត ពីអង្គការ PSI/HQ ហើយបានទទួលនៅចុងឆ្នាំ២០១១នេះ។
- ទិញមុងជ្រលក់ថ្នាំ(LLIN) ចំនួន ២,៤២១,០០០មុងក្នុងគំរោងCNM R6និងSSF Grant នឹងមុងអង្រឹងជ្រលក់ថ្នាំ(LLIHN) ២៧៥,០០០មុងនឹងបានមកដល់នៅចុងឆ្នាំ ២០១១ មានចំនួនពីរលើក។
- មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺគ្រុនចាញ់បានធ្វើការបែងចែក ទៅតាមខេត្តចំនួន ៦ (កំពង់ចាម, កំពង់ឆ្នាំង, កំពង់ធំ, ក្រចេះ, ស្ទឹងត្រែង និងកែប) នឹងធ្វើការបែងចែកលើកទី ២ ដោយចាប់ផ្តើមនៅចុងខែមករានេះ។

ការបែងចែកលើកទី១នូវមុងជ្រលក់ថ្នាំ( LLINs )ដូចនៅក្នុងតារាងខាងក្រោម៖

| No. | ទីកន្លែង | បរិមាណ LLINs ដែលទទួលបាន |
|---|---|---|
| 1 | កំពង់ឆ្នាំង | 65,750 |
| 2 | កំពង់ធំ | 163,800 |
| 3 | ក្រចេះ | 5,400 |
| 4 | ស្ទឹងត្រែង | 95,700 |
| 5 | កំពង់សោម | 412,500 |
| 6 | កែប | 32,350 |

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ទិញរថយន្តចំនួន២២ គ្រឿងសម្រាប់(SSF Malaria Grant) តាមរយៈ UNOPSហើយបានធ្វើការចែកចាយ រួចហើយតាំងពីខែឧសភាឆ្នាំ2011។
 មន្ទីរ , ក្រសួង នឹង អង្គភាព មួយចំនួន ដូចជាៈ

| | |
|---|---|
| • មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺគ្រុនចាញ់ | ចំនួន ៤ គ្រឿង |
| • ខេត្តឧត្តរមានជ័យ | ចំនួន ១ គ្រឿង |
| • ខេត្តកំពង់ចាម | ចំនួន ១ គ្រឿង |
| • ខេត្តកំពង់ធំ | ចំនួន ១ គ្រឿង |
| • ខេត្ត កោះកុង | ចំនួន ១ គ្រឿង |
| • ខេត្តក្រចេះ | ចំនួន ១ គ្រឿង |
| • នាយកដ្ឋានឱសថ និងចំណីអាហារ | ចំនួន ២ គ្រឿង |
| • ក្រសួងអប់រំ យុវជន និង កីឡា | ចំនួន ១ គ្រឿង |
| • ក្រសួងមហាផ្ទៃ | ចំនួន ១ គ្រឿង |
| • ក្រសួងកិច្ចការនារី | ចំនួន ១ គ្រឿង |
| • អង្គការបំរើសុខភាពប្រជាជនកម្ពុជា | ចំនួន ៤ គ្រឿង |
| • អង្គការសកម្មដើម្បីសុខភាពនិង កាត់បន្ថយភាពក្រីក្រ (HPA) | ចំនួន ១ គ្រឿង |
| • អង្គការដៃគូអភិវឌ្ឍន៏ (PFD) | ចំនួន ១ គ្រឿង |
| • អង្គការក្រុមអ្នកឯកទេសគ្រុនចាញ់(MC) | ចំនួន ១ គ្រឿង |
| • ខេត្តព្រះវិហារ | ចំនួន ១ គ្រឿង |

- ទិញតេស្តពិនិត្យឈាម(RDT) ការបញ្ជាទិញបន្ទាន់ចំនួន (៧៧៣,៦៩៥ តេស្ត) សំរាប់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ចំនួន ៣៣៧,៦៧៥ តេស្ត សំរាប់ អង្គការបំរើសុខភាពប្រជាជនកម្ពុជា(PSI/C)ចំនួន ៤៣៦,០២០តេស្ត បានមកដល់ខែ តុលា ឆ្នាំ ២០១១។
- ACT តាមរយៈ UNICEF យើងរំពឹងថានឹងមកដល់នៅក្នុងខែមេសានេះ។

**៥.៣.២. ការងារលទ្ធកម្មដែលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់(CNM) បានអនុវត្តផ្ទាល់ៈ**

- បានទិញ កង់ ៧៥០គ្រឿង សម្រាប់ក្រសួងកិច្ចការនារី (SSR).
- បោះពុម្ពអាវយឺត(៣៦,០០០), មួក(២០,០០០) សម្រាប់ចែកចាយទៅ ២០ ខេត្ត
- សៀវភៅកំណត់ត្រាចំនួន(៥,៣៩៦ ក្បាល) សម្រាប់អ្នកស្ម័គ្រចិត្តភូមិ.
- ប្រតិទិនព្យួរជញ្ជាំង និងលើតុ ១០,០០០សន្លឹក
- រៀបចំគំរូសំរាប់ផ្ទាំងផ្សព្វផ្សាយ,សន្លឹកប័ណ្ណ,បដា, សម្រាប់អ្នកស្ម័គ្រចិត្តភូមិប្រើប្រាស់
- ផលិតកម្មវិធីអប់រំៈ បទចម្រៀង ៥បទ, វីដេអូផ្សព្វផ្សាយ ៥រឿង, វីដេអូសាច់រឿងខ្លី១រឿង , ល្ខោននិយាយតាមរយៈវិទ្យុ ១រឿង និងតាមវិទ្យុ ផ្សព្វផ្សាយ ៣រឿង។

- ម៉ាស៊ីនបំបែកជាតុរីលីន ៣ គ្រឿង
- បោះពុម្ពលើថង់ផ្លាស្ទីកចំនួន ២៨៧,៥០០ សម្រាប់កម្មវិធីជ្រលក់មុង ប្រើប្រាស់។
- សំភារះប្រើប្រាស់ក្នុងការជ្រលក់មុងចំនួន៧៧០ គីត សម្រាប់កម្មវិធីជ្រលក់មុងប្រើប្រាស់ ។
- ផ្ទាំងប៉ាណូផ្សព្វផ្សាយចំនួន១២៧ផ្ទាំងបានលើកឡើងទៅតាម ១២៧ មណ្ឌលសុខភាព ស្ថិតនៅក្នុង១០ ខេត្ត (សៀមរាប, បន្ទាយមានជ័យ, កំពង់ស្ពឺ កំពត,កោះកុង, ឧត្តរមានជ័យ បាត់ដំបង, ព្រះសីហនុ, ព្រះវិហារ និង ពោធិសាត់)។
- DVD Player ចំនួន ២១៨ គ្រឿង, ទូរទស្សន៏ ចំនួន២១៨ គ្រឿង, Megaphones ចំនួន៣,៣៤០ និង ថង់យួរ ៣,៣៤០ សម្រាប់អ្នកស្ម័គ្រចិត្តភូមិប្រើប្រាស់។
- សៀវភៅតាមដានការចែកមុងតាមគ្រួសារ ៥០០,០០០ ក្បាល សម្រាប់ប្រើប្រាស់ក្នុងការចែកចាយមុង។ សៀវភៅនេះនឹងទទួលបាននៅចុងខែមករាហើយបានទទួលគ្រប់ចំនួននៅចុងខែកុម្ភះ២០១២ខាងមុខនេះ។
- បានធ្វើលទ្ធកម្មជូនដល់ផ្នែកទទួលជំនួយបន្ត(SRS/SSRS) គ្រឿងសង្ហារឹមដោយបានធ្វើការចែកចាយបានរួចរាល់តាមផែនការ។ មន្ទីរ , ក្រសួង នឹង អង្គភាពទទួលជំនួយបន្ត មួយចំនួន ដូចជា៖ នាយកដ្ឋានឱសថ, ក្រសួងអប់រំយុវជនកីឡា, ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី, អង្គការក្រុមឯកទេសគ្រុនចាញ់, អង្គការដៃគូរអភិវឌ្ឍន៍ និង អង្គការសកម្មដើម្បីសុខភាពនឹងកាត់បន្ថយភាពក្រីក្រ។

### ៥.៣.៣. ការងារសាងសង់ជួសជុលៈ

- ទាក់ទងជាមួយការជួសជុលយើងបានធ្វើការជួសជុលនូវអាគារសម្រាប់ផ្នែកគ្រុនចាញ់នៅក្រុងកែបនឹង ខេត្តកំពង់ឆ្នាំង។ (ក្រុងកែបបានធ្វើរួចរាល់ហើយ) ចំណែកខេត្តកំពង់ឆ្នាំង នឹងធ្វើហើយនៅក្នុង ខែកុម្ភះ ឆ្នាំ ២០១២។

### ៥.៣.៤.ការងារលទ្ធកម្មដែលក្រសួងផ្គត់ផ្គង់មកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់(CNM)

| Nb | Name | Strength | Qty Rec | Budget |
|---|---|---|---|---|
| ១ | Artemeter 1ml | 80mg/ml | 24,000 | National Budget |
| ២ | Chloroquine ( Base ) | 150mg | 130,000 | National Budget |
| ៣ | Insecticide for spraying | 1000ml | 800 | National Budget |
| ៤ | Quinine Dihydrochloride | 600mg/2ml | 2,600 | National Budget |
| ៥ | Quinine Sulfate | 300mg | 100,000 | National Budget |
| ៦ | Temephos sand granules | 1% | 140,000 | National Budget |
| ៧ | Tetracycline | 250mg | 100,000 | National Budget |
| ៨ | Dihydro Artemisinine+Piperaquine (Blist/9tabs) | 40mg + 320mg | 157,077 | WHO |

# កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម

# ត/របាយការណ៍បូកសរុបសភាពការណ៍ជម្ងឺគ្រុនឈាមឆ្នាំ២០១១

## I. សេចក្តីផ្តើម:

សភាពការណ៍ជម្ងឺគ្រុនឈាមនៅប្រទេសកម្ពុជា( Introduction: Dengue Situation in Cambodia )

ជម្ងឺគ្រុនឈាមជាប្រភេទជម្ងឺដែលកើតដោយសារវីរុសវាឆ្លងទៅមនុស្សដោយសារការខាំរបស់សត្វមូសខ្លា (*Aedes aegypti*) ភ្នាក់ងារចម្លងដែលមូសប្រភេទនេះច្រើនពងនៅក្នុងទឹកពាង/អាងដែលគេស្តុកទុកនៅតាមផ្ទះ។ជម្ងឺនេះមានលក្ខណៈរាតត្បាតជាប្រចាំជាពិសេសតាមប្រទេសដែលមានអាកាសធាតុក្តៅនិងក្តៅមធ្យមដូចជាប្រទេសកម្ពុជា។សព្វថ្ងៃនៅប្រទេសកម្ពុជាជម្ងឺនេះមានលក្ខណៈរាតត្បាតជា( endemo-epidemic )ហើយកាលពី 4 ឆ្នាំកន្លងទៅឆ្នាំ 2007មានការរាតត្បាតជាទ្រង់ទ្រាយធំទូទាំងប្រទេសទាំងរដូវប្រាំងនិងវស្សា។នាឆ្នាំកន្លងទៅថ្មីៗនេះមានការកើនឡើងនូវរបាយការណ៍នៃការកើនឡើងនូវករណីគ្រុនដាំងនិងគ្រុនឈាមដែលចំនួននេះមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងកំណើនប្រជាជនទីក្រុងភាវូបនីយកម្មអនាម័យនិងបរិស្ថានដែលនៅមានកំរិតទាបនិងការកើនឡើងស្របគ្នានូវមូសខ្លានិងមេរោគវីរុស-ភ្នាក់ងារចម្លងជម្ងឺគ្រុនឈាម។

ភ្នាក់ងារចម្លងមូសខ្លាមានភាពរាយប៉ាយនៅពាសពេញប្រទេសកម្ពុជាហើយភាគច្រើន( ៧៥-៨05 )ពងនៅតាមក្នុងពាង/អាងទឹកតូច-ធំដែលមាននៅខាងក្នុងនិងក្រៅផ្ទះនិងប្រមាណ (២០-២៥%) ពងនៅតាមរបស់របរដែលគេបោះបង់ចោលដូចជាសំបកកំប៉ុង-ខ្ទៅខ្ទង-ត្រឡោកដូង-សំបកកង់ឡាន-ថង់ប្លាស្ទីកនៅក្នុងបរិវេណដីធ្លីនិងតាមទីសាធារណៈនានា។

ភាពមានដ៏ច្រើនលើសលុបនូវពាង/អាងនិងបញ្ហាអនាម័យបានបង្កឱ្យមានការលំបាកជាខ្លាំងក្នុងការការពារពិសេសការងារគ្រប់គ្រងទូទាំងប្រទេសពីសំណាក់កម្មវិធីជាតិ។ការដាក់ថ្នាំបាណកឃាដអាបេតនៅតាមតំបន់សំខាន់ៗរួមផ្សំនិងការងារឃោសនាអប់រំនិងការលុបបំបាត់ជម្រកមូសដោយធ្វើអនាម័យបំផ្លាញវត្ថុដែលអាចដក់ទឹកបានគឺជាវិធានការដ៏មានប្រសិទ្ធិភាពតែក្នុងមួយរយៈកាលប៉ុណ្ណោះ។

រូបភាព១៖





ការងារអនុវត្តជាប់លាប់ដូចជាការងារដាក់ថ្នាំបាណកឃាដនៅតាមតំបន់ចំណុចផ្សេងៗដែលជាការងារត្រៀមបង្ការនិងពលកម្មអនាម័យសំអាតបរិស្ថានតាមផ្ទះនិងតាមសហគមជាប្រចាំអាចនាំឱ្យមានភាពធូរស្រាលនូវការរាតត្បាតនៃជម្ងឺនិងការកាត់បន្ថយនូវគ្រោះថ្នាក់ដោយជម្ងឺគ្រុនឈាម។វិធានការដែលមានប្រសិទ្ធិភាពយូរអង្វែងគឺជាការចូលរួមជាទ្រង់ទ្រាយធំរបស់សហគមក្នុងការកាត់បន្ថយនូវឥទ្ធិពលនៃការរាតត្បាតនិងការកាត់បន្ថយនូវគ្រោះគ្រុនឈាម។ជារួមការស្រាវជ្រាវឱ្យបានទាន់ពេលវេលានូវការរាតត្បាត-ការងារឆ្លើយតបឱ្យបានទាន់ពេលវេលា-ការស្គាល់និង

យល់ដឹងនូវរោគសញ្ញានិងការព្យាបាលជម្ងឺគ្រុនឈាមឱ្យបានត្រឹមត្រូវទៅតាមមគ្គុទេស្ទន៏ព្យាបាលអាចកាត់បន្ថយអត្រាឈឺការពារភាពធ្ងន់ធ្ងរនៃជម្ងឺនិងការថយចុះយ៉ាងខ្លាំងនូវអត្រាស្លាប់ដោយជម្ងឺគ្រុនឈាម។

រូបភាព២៖





និន្នាការនៃការរាតត្បាតពិសេសការស្លាប់និងការកើនឡើងនូវអត្រាឈឺរបស់កុមារដោយសារជម្ងឺនេះក្នុងចំណោមប្រជាជនក្រីក្រតាមទីក្រុងនិងការកើនឡើងនូវការសាយភាយនៃជម្ងឺនេះទៅតាមតំបន់ជនបទបានធ្វើឱ្យមានការគំរាមកំហែងយ៉ាងខ្លាំងនិងជានិរន្តន៍នូវបញ្ហាសុខភាពសាធារណៈ។នៅពេលដែលការព្យាបាលករណីសង្ស័យជម្ងឺគ្រុនមានភាពល្អប្រសើរនិងស្របទៅតាមមគ្គុទ្ទេសន៏ព្យាបាលរបស់កម្មវិធីជាតិបានធ្វើឱ្យមានការធ្លាក់ចុះនូវអត្រាស្លាប់គួរឱ្យកត់សំគាល់។ ប្រទេសកម្ពុជាយើងបានទទួលរងគ្រោះដោយការរាតត្បាតយ៉ាងខ្លាំងក្លាជាប្រចាំរវាង3-5 ឆ្នាំម្តងៗ។

នៅឆ្នាំ 1998- 2007 កម្ពុជាត្រូវបានទទួលរងគ្រោះដ៏ខ្លាំងក្លានូវការរាតត្បាតជម្ងឺគ្រុនឈាមដែលពេលនោះមានកុមារចំនួន 16.216នាក់ ត្រូវបានរាយការណ៏ថាមានករណីគ្រុនឈាមក្នុងនោះមានកុមារចំនួន 475នាក់ បានស្លាប់បាត់បង់ជីវិត (អត្រាមរណៈភាព 2.9%\ និងកុមារចំនួន 39.851នាក់ ត្រូវបានរាយការណ៏ថាបានដេកសំរាកនៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈដែលក្នុងនោះមានកុមារចំនួន 407នាក់ បានស្លាប់បាត់បង់ជីវិត (អត្រាមរណៈភាព 1.2%). ក្នុងរវាងឆ្នាំ 1999 និង 2005 អត្រាអាំងស៊ីដង់មានប្រមាណក្រោម 15.000នាក់/១ឆ្នាំ ជារៀងរាល់ឆ្នាំហើយអត្រាមរណៈភាពក្នុងចន្លោះ 1-1.9% និងឆ្នាំ 2008-2010 អត្រាអាំងស៊ីដង់នៃអ្នកជម្ងឺសង្ស័យបានស្ថិតនៅតិចជាង 12.000នាក់ ក្នុងមួយឆ្នាំៗនិងអត្រាស្លាប់ 0.68 និង 0.30% (ក្រាហ្វិក១)។

DISTRIBUTION OF DENGUE CASES BY YEAR THROUGH THE NDCP SURVILLANCE SYSTEM IN CAMBODIA 1995-2011(as at 27 Dec. 2011)




## II. សភាពការណ៍គ្រុនឈាមឆ្នាំ២០១១ ( Dengue situation in 2011 )

ចាប់ពីដើមឆ្នាំ 2011 សភាពការណ៍ទូទៅទូទាំងប្រទេសនៃជម្ងឺគ្រុនឈាមមានសភាពល្អប្រសើរច្រើនបើធៀបទៅនឹង៣ឆ្នាំកន្លងទៅ តែមានភាពមិនសូវល្អប្រសើរទេបើប្រៀបធៀបទៅនឹងឆ្នាំ 2010 ។នៅក្នុងអំឡុង2ខែដើមឆ្នាំ(អាទិត្យទី១-៨)សភាពការណ៍ទូទាំងប្រទេសនៃជម្ងឺគ្រុនឈាមមានភាពមិនប្រក្រតីដោយវាស្ថិតនៅលើដែនកំណត់ខាងក្រោមហើយបន្ទាប់មកដល់អាទិត្យទី១៨ (អំឡុងខែមេសា)សភាពការណ៍ទូទៅនៃជម្ងឺគ្រុនឈាមមានភាពល្អប្រសើរនិងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មវិធីជាតិ។បន្ទាប់មកចាប់ពីអាទិត្យទី20-25សភាពការណ៍បានធ្លាក់ក្នុងស្ថានភាពប្រកាសអាសន្ន។ ចំនួនករណីនៃកុមារដែលសង្ស័យកើតជម្ងឺគ្រុនដាំងនិងគ្រុនឈាមពី១អាទិត្យទៅ១អាទិត្យមានការកើនឡើងចំនួន 1.3 ទៅ 3.5 ដងប៉ុន្តែជានិច្ចជាកាលនៅក្រោមនិងជួនកាលបានស្ថិតនៅលើខ្សែដែនកំណត់ខាងលើ( the cases are always under and sometimes touching the ULL ) )មានន័យថាសភាពការណ៍ស្ថិតនៅក្នុងស្ថានភាពប្រកាសអាសន្នហើយនឹងបានឡើងខ្ពស់ជាងខ្សែដែនកំណត់ខាងលើដល់ចំណុចកំពូលក្នុងរវាងអាទិត្យទី២៩។ នៅឆ្នាំ2011ចំនួនករណីសរុបនៃកុមាររងគ្រោះដោយជម្ងឺគ្រុនឈាមហើយបានដេកសំរាកព្យាបាលនៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈមានចំនួន15.980នាក់ដែលក្នុងនោះមានកុមារចំនួន73នាក់ បានស្លាប់បាត់បង់ជីវិត(អត្រាមរណៈភាព០.៤៦5) ហើយប្រសិនបើធ្វើការប្រៀបធៀបទៅនឹងឆ្នាំ 2010រយៈពេលដូចគ្នាដែលមានចំនួនតែ12.500 ដែលក្នុងនោះមានកុមារចំនួន38នាក់បានស្លាប់បាត់បង់ជីវិត ( អត្រាមរណៈភាព0.30% )។

ក្នុងអំឡុងត្រីមាសទី១ឆ្នាំ២០១១ ចំនួនជាមធ្យមនៃករណីជម្ងឺគ្រុនដាំងនិង គ្រុនឈាមប្រចាំខែមានចំនួន 112krNI/ខែ តែករណី នេះបានកើនឡើងយ៉ាងរហ័សចំនួន 12-27 ដងច្រើនជាង ជារៀងរាល់ត្រីមាស។ នៅក្នុងត្រីមាសទី២និងទី៣ ចំនួនជាមធ្យមនៃករណី ដែល បានរាយការណ៍ចាប់ពីខែមេសាដល់ខែមិថុនានិងខែកក្កដា- ខែកញ្ញាមានចំនួន 1.358នាក់/ខែនិង 3.095នាក់/ខែ ហើយចំនួន នេះបានកើនឡើងដល់ចំណុចខ្ពស់បំផុតក្នុងរវាងអាទិត្យទី២៩ ( ពាក់កណ្តាលខែកក្កដា ) ដែលនៅពេលនោះមានករណីចំនួន 854នាក់/អាទិត្យត្រូវបានរាយការណ៍ ក្រាហ្វិក២។ នៅអំឡុង 12ខែ ឆ្នាំ 2011 អត្រា ឈឺក្នុងប្រជាជន 100.000នាក់មានចំនួន 119.30នាក់ ច្រើនជាងឆ្នាំ កន្លងទៅ ឆ្នាំ 2010យ៉ាងច្រើន ដែលមានចំនួនតែ ( ៨៩.១០/១០០.០០០នាក់ ) ប៉ុន្តែមានចំនួន 3.8ដងតិចជាង2007 ដែលមានចំនួន រហូតដល់ 437/100.000នាក់។

RELATIONSHIP OF DENGUE CASES BY WEEKS IN CAMBODIA 2011 (as at 27 Dec. 2011)
WITH Mean AND Mean+2SD DURING 2005-2010 (*Excluded 2007)




តែទោះជាយ៉ាងណាក៏ដោយហេតុការណ៏នេះបានកើតមានជាការរាតត្បាតរប៉េះរប៉ោះគ្រប់ទីកន្លែងតាមទីក្រុងជាយក្រុងនិងទីប្រជុំជននៃទីជនបទនៃខេត្តមួយចំនួនក្នុងប្រទេសដោយតំបន់ខ្លះការរាតត្បាតជាទ្រង់ទ្រាយតូចនិងធំតាមបណ្តាខេត្តមួយចំនួនដូចជាខេត្តបាត់តំបង (បាត់តំបង-ថ្មគោល-ម៉ោងឬស្សី-រតនៈមណ្ឌល-តាសាញ់-កោះក្រឡ )- ខេត្តសៀមរាប (សៀមរាប-ក្រឡាញ់-ជីក្រែង-សូទ្រនិគម )- រាជធានីភ្នំពេញ (សង្កាត់ដង្កោរ-ព្រៃវែង) - ខេត្តកណ្តាល (អង្គស្នួល-ខ្សាច់កណ្តាល-កោះធំ-ស្អាង-គៀនស្វាយ) - ខេត្តកំពង់ចាម (កំពង់ចាម-កំពង់សៀម-ព្រៃឈរ-ពញាឬក្រែក-ស្ទឹងត្រង់-ចំការលើ-ក្រូចឆ្មារ ) - ខេត្តកំពង់ឆ្នាំង (កំពង់ឆ្នាំង-កំពង់ត្រឡាច-បរិបូរណ៏-រលាប្អៀរ)-ខេត្តកំពង់ធំ (កំពង់ធំ-ស្ទឹងសែន-ស្ទោង-ប្រាសាទបាល្ល័ង្គ-ប្រាសាទសំបូរណ៏-បារាយណ៏-សន្ទុក ) - ខេត្តកំពត (អង្គរជ័យ-ឈូក) - ខេត្តកែប-ខេត្តតាកែវ (ដូនកែវ-បាទី-សំរោង-ព្រៃកប្បាស)-ខេត្តព្រៃវែង (កំចាយមារ-ព្រះស្តេច)-ខេត្តបន្ទាយមានជ័យ (មង្គលបូរី-ប៉ោយប៉ែត-ថ្មពួក-អូរជ្រៅ-មាឡៃ) - ខេត្តកំពង់ស្ពឺ (កំពង់ស្ពឺ-គងពិសី-ឧដុង្គ-បរសេដ្ឋ) - ខេត្តឧត្តរមានជ័យ (សំរោង-អន្លង់វែង-ចុងកាល់) - ខេត្តស្វាយរៀង (រមាសហែក-ស្វាយរៀង)-ខេត្តពោធិសាត់ (បាកាន-ស្វាយដូនកែវ)-ខេត្តកោះកុង-ខេត្តព្រះវិហារ (ឆែប-រវៀង-ត្បែងមានជ័យ)-ខេត្តក្រចេះ (ឆ្លូង-សំបូរ) -ខេត្តរតនៈគិរី (វ៉ុនសៃ-កូនមុំ-កច្ញាញ)-ខេត្តមណ្ឌលគិរី (កោះញែក-កែវសីមា-សែនមនោរម្យ) ( ផែនទី១)

**Cumulative Incidence of Dengue cases by District in Cambodia 2011** ( n: 15,980/73)



## ២.១.ប្រភេទវីរុសគ្រុនឈាមនិងប្រជាសាស្ត្រ( Dengue serotype and demography )៖

ដោយកិច្ចសហការជាមួយវិទ្យាស្ថានជាតិប៉ាស្ទ័រ-កម្ពុជាកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានការគាំទ្រថវិកានិងបច្ចេកទេសពីអង្គការសុខភាពពិភពលោកនិងវិទ្យាស្ថានជាតិប៉ាស្ទ័រប៉ារីស ប្រទេសបារាំងនិងគាំទ្របច្ចេកទេសពីវិទ្យាស្ថានជាតិប៉ាស្ទ័រ-កម្ពុជាបានបន្តធ្វើការតាមដានភាពបំរែបំរួលប្រភេទវីរុស-មេរោគជម្ងឺគ្រុនឈាម។ ហូតមកដល់ពេលនេះរយៈពេល៥២អាទិត្យចំនួនសរុប 422 (១២៧)នៃសំណាកឈាមត្រូវបានបញ្ជូនមកវិទ្យាស្ថានជាតិប៉ាស្ទ័រដើម្បីធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ដោយ IHA, PCR or virus isolation and ELISA tests។មន្ទីរពេទ្យប្រតិបត្តចំនួន 2 នៅភាគខាងជើងឈាងខាងលិចៈខេត្តបាត់តំបង-ខេត្តសៀមរាប-មន្ទីរពេទ្យប្រតិបត្តចំនួន 2 ទៀតនៅភាគខាងត្បូងឈាងខាងកើតៈ ខេត្តកំពង់ចាម-ខេត្តតាកែវ និង ភាគកណ្តាលៈរាជធានីភ្នំពេញ (មន្ទីរពេទ្យកុមារជាតិ)ត្រូវបានបញ្ជូនមកជាទៀងទាត់និងជារៀងរាល់សប្តាហ៏នូវសំណាមឈាមមកវិទ្យាស្ថានជាតិប៉ាស្ទ័រដើម្បីធ្វើការផ្ទៀងផ្ទាត់និងមួយចំនួនតាមរយៈក្រុមឆ្លើយតបបន្ទាន់នៃកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដែលចុះតាមតំបន់រាតត្បាតមួយចំនួននៃខេត្តកំពង់ធំ-ខេត្តសៀមរាប-ខេត្តព្រៃវែង-ខេត្តរតនៈគិរី ជាលទ្ធផលយើងទទួលបានៈ

- មេរោគដាំងប្រភេទ 1 មានចំនួន 150 (៥២)ករណី
- មេរោគដាំងប្រភេទ 2 មានចំនួន 36 (៤)ករណី
- មេរោគដាំងប្រភេទ 3 មានចំនួន 04 (១)ករណី
- មេរោគដាំងប្រភេទ 4 មានចំនួន 4 ករណី
- មេរោគដាំងវីរុស (DENV)មានចំនួន 51 (១៦)ករណី
- ផ្លាវីវីរុស (Flavivirus) មានចំនួន 98 (២០)ករណី
- Undetermined status (US) 76 (៣៣)ករណី
- AIR: 01 (១)ករណី
- ផ្សេងៗ៖ 2 ករណី

ជាសន្និដ្ឋានៈមានមេរោគវីរុសដាំងទាំង៤ប្រភេទដែលកំពុងចរាចរពាសពេញក្នុងប្រទេសដែលក្នុងនោះភាគច្រើនគឺមេរោគវីរុសដាំងប្រភេទ១និងវីរុសដាំងប្រភេទ២ដាំងប្រភេទ៣និងដាំងប្រភេទ៤បន្តបន្ទាប់ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិច៣៖

**SEROTYPE OF DENGUE IN CAMBODIA, 2011**






## ២.២. **របាយនៃករណីនិងការស្រាវជ្រាវ** (Case distribution and detection )

នៅក្នុងអំឡុងឆ្នាំ2011លើសពី97.5%នៃករណីដែលបានរាយការណ៍ច្រើនកើតមានលើកុមារដែលមានអាយុតិចជាង១៥ឆ្នាំ។ មួយភាគធំនៃករណីដែលបានរាយការណ៍ច្រើនជាក្រុមកុមារដែលមានអាយុពី 5-9ឆ្នាំ (៦,៩៨០ករណី= 43.67%បន្ទាប់មកក្រុមកុមារដែលមានអាយុពី0-4ឆ្នាំ (៥,១៥៦ករណី= 32.26 %និងអាយុពី 10-14ឆ្នាំ ( 3,450ករណី= 21.58%). មិនមានភាពខុសគ្នារវាងក្មេងប្រុសនឹងក្មេងស្រីនៃអត្រារងគ្រោះដោយជម្ងឺគ្រុនឈាមទេ (8,003ករណី=50.08% និង7,977ករណី=49.91%)ដែលក្នុងនោះអត្រាមរណៈមានកំរិតខ្ពស់លើក្រុមកុមារដែលមានអាយុតិចជាងឬស្មើរនឹង4ឆ្នាំ។ តែទោះជាយ៉ាងណាក៏ដោយគេក៏សង្កេតឃើញមនុស្សពេញវ័យមួយចំនួនដែលមានអាយុ១៥ឆ្នាំ ឬលើសក៏បានទទួលរងគ្រោះហើយបានមកទទួលការព្យាបាលនៅតាមមន្ទីរពេទ្យសាធារណៈដែលមានចំនួន 394ករណី = 2.46 % (ក្រាហ្វិច៤)។

ក្នុងចំណោម 15,980ករណីអ្នកជម្ងឺគ្រុនឈាមចំនួន 13,084ករណី( ៨១.៨៧ %) បានរាយការណ៍ពីមន្ទីរពេទ្យចំណុចទាំង5និងមានតែចំនួន2,896ករណីប៉ុណ្ណោះដែលចូលនិងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យបង្អែកខេត្តនៃបណ្តាខេត្ត/ក្រុងទាំង24។ មួយភាគធំនៃករណីទាំងនោះបានទទួលការព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផា-ភ្នំពេញចំនួន 6,966ករណី (៤៣.៥៩%)បន្ទាប់មកមន្ទីរពេទ្យ កុមារជាតិ-ភ្នំពេញ 1,820ករណី (១១.៣៨%)- មន្ទីរពេទ្យខេត្ត/ក្រុងទាំង 24៖ 2,896ករណី (១៨.១២%)- មន្ទីរពេទ្យជ័យវរ្ម័នទី៧-សៀមរាបៈ 3,196ករណី (២០.០០%)- និងមន្ទីរពេទ្យកុមារអង្គរ-សៀមរាបៈ 1,102ករណី (៦,៨៩%) ក្រាហ្វិច៥។

ក្រាហ្វិច៤



ក្រាហ្វិច៥




នាក្នុងអំឡុងឆ្នាំ 2011 ខេត្តដែលទទួលរងគ្រោះធ្ងន់ធ្ងរនិងមានករណីគ្រុនឈាមជាងគេគឺ : រាជធានីភ្នំពេញ-ខេត្តកំពង់ចាម-ខេត្តកណ្តាល-ខេត្តកំពង់ធំ-ខេត្តសៀមរាប-ខេត្តព្រៃវែង-ខេត្តបន្ទាយមានជ័យ-ខេត្តកំពង់ស្ពឺនិងខេត្តតាកែវ ដែលខេត្តទាំងនោះមានដង់ស៊ីតេប្រជាជនខ្ពស់និងចលនាផ្លាស់ប្តូរ/ប្រជាជនចល័តច្រើន។ ក្នុងផែនទីករណីជាច្រើនបានកើតមានផ្តុំគ្នាដែលចំណុចខៀវ១ស្មើនឹង១០ករណីគ្រុនឈាមឯ ១ចំណុចក្រហមស្មើនឹងករណីស្លាប់ម្នាក់។ហើយករណីទាំងនេះបានសាយភាយនិងរាតត្បាតចូលដល់តំបន់ផ្សេងៗនៃខេត្តដ៏ទៃទៀតផង ដូចដែលបានបង្ហាញក្នុងផែនទីខាងក្រោម (ផែនទី៣)។

III. **.ការងារប្រយុទ្ធនឹងជម្ងឺគ្រុនឈាមនៅប្រទេសកម្ពុជា**( Dengue control in Cambodia )៖

**៣.ក / វិធានការណ៍សកម្មភាពនៅដំណាក់កាលត្រៀម** ( Measures taken during the Pre-emergency phase )៖

ជារៀងរាល់ឆ្នាំដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោកកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមបានរៀបចំនិងអនុវត្តយុទ្ធនាការបឋមដូចជា:

**Cumulative Incidence of Dengue cases and Death by District in Cambodia 2011**




## ៣.១..ការងារឃោសនាអប់រំតាមមូលមូលដ្ឋាននិងអប់រំចល័ត

### ៣.១.១- ការងារកំចាត់ភ្នាក់ងារចម្លងគ្រុនឈាមតាមសាលារៀន-សហគមនិងការអប់រំចល័ត

ការផ្សព្វផ្សាយអប់រំតាមរយៈស្ថានីយទូរទស្សន៏ ( TV Bayon, TV3, TVK, TV11- SEA- TV5 និង TV9) ពីថ្ងៃទី 20 សីហា- 22តុលា-ឆ្នាំ2011 ក្នុងន័យផ្តល់ព័ត៌មានជូនដល់បងប្អូនប្រជាជនសហគមនូវវិធានការណ៏ការពារនិងរោគសញ្ញាសំខាន់ៗនៃជម្ងឺគ្រុនឈាមដែលត្រូវបញ្ជូនអ្នកជម្ងឺទៅទទួលការព្យាបាលនៅសេវាសាធារណៈដែលនៅជិតបំផុតឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។ ក្រុមអប់រំចល័តត្រូវបានធ្វើសកម្មភាពក្នុងន័យផ្តល់នូវចំណេះដឹងដល់ប្រជាជនតាមសហគមនិងបំផុសការចូលរួមនៅរដូវនៃការចម្លងពិសេសតាមកន្លែងដែលមានការរាតត្បាតជម្ងឺគ្រុនឈាម (រូបភាពទី៣)។













- សហគមនិងការអប់រំចល័ត (School and Community-based vector control and mobile health education):

- ដើម្បីបង្កើនសមត្ថភាពយល់ដឹងរបស់សហគមនិងសិស្សានុសិស្សតាមសាលារៀនស្តីពីវិធានការការពារនិងរោគសញ្ញាបឋមសំខាន់ៗនៃករណីសង្ស័យជម្ងឺគ្រុនឈាមបញ្ជូនកុមារទៅទទួលការព្យាបាលឱ្យបានសមស្របនៅសេវាព្យាបាលសាធារណៈផ្នែកអប់រំនៃកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានកិច្ចសហការជាមួយនាយកដ្ឋានអប់រំសិក្សានៃក្រសួងអប់រំនិង មន្ទីរសុខាភិបាលខេត្តក្រោមការឧបត្ថម្ភជាថវិកា ពីអង្គការធនាគារពិភពលោក HSSP2_Pooled Fund និងអង្គការធនាគារអភិវឌ្ឍន៍អាស៊ី ADB_CDC2 បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលនិងការងារតាមដានក្រោយការបណ្តុះបណ្តាលនិងការងារពង្រីក ការងារបណ្តុះបណ្តាលវិធានការការពារតាមសាលាបឋមសិក្សានៃខេត្តមួយចំនួនទៀតដូចជាខេត្តព្រះវិហារ-ខេត្តកំពង់ធំ-ខេត្តព្រះស៊ីហនុ-ខេត្តកំពង់ស្ពឺនិងខេត្តសៀមរាបតាមតារាងខាងក្រោម៖

| Activities | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| Follow-up training to school directors on school based dengue prevention in high risk provinces | | | | | | |
| | 36 | 15 | | Kg Cham | 14-18Mar 11 | HSSP2_Pooled F |
| | 36 | 08 | | Takeo | 21-25Mar 11 | HSSP2_Pooled F |
| | 34 | 12 | | Kampot | 28-01Apr 11 | HSSP2_Pooled F |
| | 34 | 09 | | Kandal | 04-08Apr 11 | HSSP2_Pooled F |
| Extension Training of schools clusters and directors on school based dengue prevention and control | | | | | | |
| 1st session<br>2nd session | 52<br>88 | 11<br>08 | | Kg Speu<br>Kg Speu | 9-11 Mar 2011<br>02-04Nov 11 | HSSP2_Pooled F<br>HSSP2_Pooled F |
| 1st session<br>2nd session | 55<br>80 | 13<br>17 | | PVH<br>PVH | 22-24Mar 11<br>13-15Sep 11 | HSSP2_Pooled F<br>HSSP2_PooledF |
| 1st session<br>2nd session | 56<br>86 | 22<br>28 | | Kg Thom<br>Kg Thom | 19-21Apr 11<br>06-08Sept 11 | HSSP2_Pooled F<br>HSSP2_Pooled F |
| 1st session<br>2nd session | 84<br>86 | 17<br>21 | | PSV<br>PSV | 15-17 Nov 11<br>13-15 Dec 11 | HSSP2_Pooled F<br>HSSP2_Pooled F |
| 1st session | 40 | 13 | | SiemReap | 20-22Dec 11 | HSSP2_Pooled F |

និងការងារប្រជុំព្រៀងនិងផលិតឡើងវិញនូវសំភារៈអប់រំតាមសាលារៀនដែលបានធ្វើនៅរាជធានីភ្នំពេញនិងខេត្តតាកែវនិងការងារផលិតស្លាតស្តីពីការងារប្រយុទ្ធនឹងការពារជម្ងឺគ្រុនឈាមដែលកំពុងដំណើរការ។

### ៣.១.២.ទិវាអនាម័យប្រយុទ្ធនឹងជំងឺគ្រុនឈាម៖

រៀបចំទិវាអនាម័យប្រយុទ្ធនឹងជម្ងឺគ្រុនឈាមនៅរាជធានីភ្នំពេញក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល-ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ-យុវជននិងកីឡា នៅថ្ងៃទី 20 មិថុនាគឺជាសារដ៏ពិសេសមួយក្នុងន័យជូនដំណឹងដល់ប្រជាជនតាមសហគមនិងអាជ្ញាធរដែនដីឱ្យមាន

ការចូលរួមនិងជូនដំណឹងដល់មន្ទីរសុខាភិបាលខេត្ត/ក្រុង ទាំងអស់ឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការការពារការរាតត្បាតជម្ងឺគ្រុនឈាមដូចជា៖

- ជំរុញនិងណែនាំដល់សហគមឱ្យធ្វើអនាម័យសំអាតជុំវិញលំនៅដ្ឋានតាមទីសាធារណៈនានា ការលាងពាងឬអាងឱ្យបានជារៀងរាល់អាទិត្យប្រសិនក្នុងពាង/អាងនោះគ្មានថ្នាំបាណកឃាដឬដាក់ត្រីពព៌ណឱ្យវាស៊ីដង្កូវទឹក
- ការងារថែរក្សាកុមារ-កុមារីកុំឱ្យមូសខាំ
- ហើយប្រសិនបើវាឈឺគ្រុនក្តៅសង្ស័យជម្ងឺគ្រុនឈាមសូមយកអ្នកជម្ងឺទៅទទួលការព្យាបាលឱ្យបានទាន់ពេលវេលានិងត្រឹមត្រូវនៅមន្ទីរពេទ្យរដ្ឋដែលនៅជិតបំផុត។ ទិវានេះមានសិក្ខាកាមចូលរួមសរុបចំនួន 672នាក់ដែលក្នុងនោះមាននារីចំនួន 155នាក់។

## ៣.២.-ការងារតាមដានអេពីដេមីសាស្ត្រ (Epidemiologicalsurveillance )៖

ការងារតាមដានអេពីដេមីសាស្ត្រនៃជម្ងឺគ្រុនឈាមត្រូវបានអនុវត្តជាប្រចាំជារៀងរាល់សប្តាហ៍ នៅតាមមន្ទីរពេទ្យកុមារចំណុចសំខាន់ៗចំនួន5ដែលយើងហៅថាការតាមដានសកម្ម(active-like dengue surveillance ) ដែលការងារនេះត្រូវបានអនុវត្តដោយកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមនិងគាំទ្រដោយអង្គការសុខភាពពិភពលោក និងការតាមដានសេរូឡូស៊ីដោយមានកិច្ចសហការជាមួយវិទ្យាស្ថានជាតិប៉ាស្ទ័រ-ភ្នំពេញ។

តួរលេខនៃករណីសង្ស័យជម្ងឺគ្រុនឈាមដែលបានផ្ញើរមកពីមន្ទីរពេទ្យចំណុចទាំង៥ត្រូវបានធ្វើការវិភាគជារៀងរាល់48ម៉ោងម្តងៗដើម្បីកំណត់រកកន្លែងរាតត្បាតថ្មីៗ។ ពត៌មានត្រឡប់ត្រូវបានបញ្ជូនទៅតាមមន្ទីរសុខាភិបាលសាម៉ីដើម្បី ការឆ្លើយតបបន្ទាន់-អង្គការមិនមែនរដ្ឋាភិបាលនិងថ្នាក់ដឹកនាំក្រសួងដើម្បីជាពត៌មាន។

សិក្ខាសាលាមួយស្តីពីការដាក់បញ្ចូលលទិន្នន័យជម្ងឺគ្រុនឈាមមនុស្សពេញវ័យ(លើសពី១៥ឆ្នាំឡើង)ទៅក្នុងប្រព័ន្ធអង្កេតតាមដានជម្ងឺគ្រុនឈាមជាតិជូនដល់មន្ត្រីប្រព័ន្ធពត៌មាននៃមន្ទីរពេទ្យ (មន្ទីរពេទ្យកាល់ម៉ែត្រ)មន្ទីរពេទ្យព្រះកុសុមៈ-មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតមន្ទីរសុខាភិបាលខេត្តកំពង់ចាម-មន្ទីរសុខាភិបាលខេត្តសៀមរាប-មន្ទីរសុខាភិបាលខេត្តកំពត-មន្ទីរសុខាភិបាលខេត្តតាកែវ-មន្ទីរសុខាភិបាលខេត្តស្វាយរៀងដូចដែលបានបង្ហាញតាមតារាងខាងក្រោម (តារាង២)៖

| Activities | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| Dengue epidemiology surveillance for the adults health facilities | | | | | | |
| 1st session | 77 | 11 | | Kg Chhnang | 26-30Dec11 | HSSP2_Pooled Fund |

## ៣.៣.យុទ្ធនាការដាក់ថ្នាំបាណកឃាដ៖

ការរៀបចំនិងយុទ្ធនាការនិងការងារពង្រីកផែនការដាក់ថ្នាំបាណកឃាដដែលជាវិធានការបឋមនៅតាមតំបន់ចំណុចមួយចំនួននៃ24ខេត្ត/ក្រុងដែលប្រឈមខ្ពស់នឹងគ្រោះគ្រុនឈាមគឺជាវិធានការទប់ទល់ការរាតត្បាតជម្ងឺគ្រុនឈាម។ នៅឆ្នាំ2011កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមបានរៀបចំផែនការគ្របដណ្តប់គ្រប់តំបន់ចំណុចនៃខេត្ត/ក្រុងប្រឈមទាំង24។បរិមាណថ្នាំអាបេតចំនួន93,200គក្រត្រូវបានធ្វើការដឹកជញ្ជូនពីឃ្លាំងឱសថកណ្តាលទៅតាមចំណុចគោលដៅដើម្បីត្រៀមធ្វើការចែកចាយ។ តំបន់ដែលប្រឈមខ្ពស់នឹងគ្រោះគ្រុនឈាមនិងកន្លែងដែលរងការរាតត្បាតមួយចំនួនត្រូវបានកំណត់យកដើម្បីធ្វើការដាក់ថ្នាំបាណកឃាដនៅចន្លោះខែឧសភានិងមិថុនា។

ខ្នងផ្ទះសរុបចំនួន528.731ខ្នងផ្ទះនៅក្នុងភូមិចំនួន 2.797ភូមិ= 85 ស្រុកនៃ 20extp/ក្រុងត្រូវបានធ្វើការដាក់ថ្នាំបាណកឃាដដោយការពារប្រជាជនបានចំនួន 2,977,526 លាននាក់និងគ្របដណ្តប់បានពាង/អាងចំនួន

2,513,120Bag /អាង។ អត្រាគ្របដណ្តប់ផ្ទះបានចំនួន 90.73% និងប្រើប្រាស់ថ្នាំបាណកឃាដអស់ 77,547.98 គក្រ (បរិមាណថ្នាំអាបេតអស់ 74,917.19 គក្រ)។ ម្យ៉ាងវិញទៀតជំរកមូសផ្សេងៗទៀតដូចជាសំបកកង់រថយន្តចាស់ៗសំបកកំប៉ុង/ក្រឡថូវផ្កាតូចៗក៏ជាប្រភពសំខាន់នៃជំរកមូសដែលជាកតព្វកិច្ចនិងការទទួលខុសត្រូវផ្ទាល់ របស់ម្ចាស់ផ្ទះ និងអាជ្ញាធរដែនដីត្រូវតែមានវិធានការស្វ័យការពារដោយខ្លួនឯង។

យុទ្ធនាការខាងលើនេះត្រូវបានឧបត្ថម្ភថវិកាដោយធនាគារពិភពលោកនៃគំរោងទ្រទ្រង់វិស័យសុខាភិបាលជំហ៊ានទី២ HSSP2_Pooled Fund។ ទន្ទឹមនឹងយុទ្ធនាការនេះការប្រើប្រាស់វិធានការតាមជីវសាស្ត្រក្នុងការសម្លាប់ដង្កូវទឹកដែលហៅថា Bti (Baci llus Thurin giensis Israelensis) ត្រូវបានធ្វើការអនុវត្តនៅខេត្តកណ្តាលដោយមានកិច្ចសហការឧបត្ថម្ភថវិកាដោយ HSSP2 _Pooled Fund និង Valent Biosciences company ដូចជា ( Per-diem, Bti launching, training, IEC materials: T-shirts, Posters, leaflet s, Booklets, spray, plastic drum ....) ការងារដឹកជញ្ជូននិងការងារផ្សេងៗ។យុទ្ធនាការនេះបានគ្របដណ្តប់តំបន់ចំណុចនិងភូមិនៃស្រុកទាំង 06 នៃខេត្តកណ្តាល ដូចជាស្រុកអង្គស្នួល-ស្រុកពញាឮ-ស្រុកមុខកំពូល-ស្រុកខ្សាច់កណ្តាល - ស្រុកគៀនស្វាយ-និងស្រុកលើដែក។ ជាលទ្ធផល 06Rsuk= 59XMu និងប្រជាជនចំនួន 431,300នាក់ត្រូវបានការពារនិងគ្របដណ្តប់បានផ្ទះចំនួន 85,239ផ្ទះ= 764,632 ពាង/អាងនិងប្រើប្រាស់អស់ Bti ចំនួន 2,630.79KRk (ផែនទី 4-5)។

RESULT ON 1 rd OF ABATE AND Bti APPLICATION 2011




RESULT ON 1rd OF Bti APPLICATION 2011




ម្យ៉ាងវិញទៀតដើម្បីធានានូវភាពល្អប្រសើរនូវសភាពការណ៍គ្រុនឈាមពិសេសនារដូវចម្លងកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាម បានបន្តនិងរៀបចំនិងពង្រីកផែនការដាក់ថ្នាំបាណកឃាដចំនួន 73តោននៅលើកទី2។ ជាលទ្ធផលតំបន់ចំណុចតាមបណ្តា 22ខេត្ត/ក្រុងត្រូវបានគ្របដណ្តប់=88ស្រុក=426ឃុំ=3,608 ភូមិនិងគ្របដណ្តប់បានផ្ទះសរុបចំនួន 705,853 ខ្នងផ្ទះ (១០០.៦៥) គ្របដណ្តប់ពាង/អាងបានចំនួន 2,632,178 ពាង/អាងនិងការពារប្រជាជនបានចំនួន 3,437,487 លាននាក់និងប្រើប្រាស់បរិមាណថ្នាំបាណកឃាដអស់ 87,167.24KRk (អាបេតអស់ 84,625.04គីឡូក្រាម )ឧបត្ថម្ភថវិកាដោយគំរោងវិស័យសុខាភិបាលជំហ៊ានទី២ (HSSP2_Pooled Fund)ក្រសួងសុខាភិបាល។

ទន្ទឹមនឹងនេះដែរការប្រើប្រាស់វិធានការតាមជីវសាស្ត្រក្នុងការសម្លាប់ដង្កូវទឹកដែល ហៅថា Bti (Bacillus ThuringiensisIsraelensis)ត្រូវបានធ្វើការអនុវត្តនៅខេត្តកណ្តាលដោយមានកិច្ចសហការឧបត្ថម្ភថវិកាដោយ HSSP2_Pooled fund ( Per-diem) និង Valent Biosciences company ( Bti launching, IEC materials: T-shirts, Posters, leaflets, Booklets, spray cans....) ការងារដឹកជញ្ជូននិងការងារផ្សេងៗ។ យុទ្ធនាការនេះបានគ្របដណ្តប់តំបន់ចំណុចនិងភូមិនៃស្រុកទាំង 07 នៃខេត្តកណ្តាលដូចជាៈស្រុកពញាឮ-ស្រុក

មុខកំពូល-ស្រុកខ្សាច់កណ្តាល-ស្រុកអង្គស្នួល-ស្រុកគៀនស្វាយ-ស្រុកល្វាឯមនិងស្រុកលើដែក។ ជាលទ្ធផល 07 ស្រុក= 69ឃុំនិងប្រជាជនចំនួន 489,055 នាក់ត្រូវបានការពារនិងគ្របដណ្តប់បានផ្ទះ ចំនួន96,534 ផ្ទះ= 877,952 ពាង/អាងនិងប្រើប្រាស់អស់ Bti ចំនួន 2,992.20KRk (ផែនទី 6-7)។







## ៣.៤.វគ្គបណ្តុះបណ្តាលការងារព្យាបាលនិងការតាមដានក្រោយវគ្គបណ្តុះបណ្តាល៖

### ៣.៤.១.ដើម្បីការងារគ្រប់គ្រងល្អប្រសើរ នូវសភាពការណ៏គ្រុនឈាមនិងកាត់បន្ថយអត្រាស្លាប់ឱ្យនៅតិចជាង<1%

កម្មវិធីជាតិ ប្រយុទ្ធនឹងជម៉ឺគ្រុនឈាមបានសហការជាមួយអនុគណៈកម្មាធិការព្យាបាល (កម្មវិធីជាតិ-មន្ទីរពេទ្យគន្ធបុប្ផា-ភ្នំពេញ-មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម) ដឹកនាំដោយឯកឧត្តមសាស្ត្រាចារ្យ**ឃិតស៊ុនណារ៉ា**អនុរដ្ឋលេខាធិការក្រសួងសុខាភិបាលបានរៀបចំវគ្គបណ្តុះបណ្តាលការងារព្យាបាលនិងថៃទាំជម្ងឺគ្រុនឈាមជាច្រើនវគ្គជូនដល់គ្រប់បុគ្គលិកសុខាភិបាល (វេជ្ជបណ្ឌិត-គ្រូពេទ្យ-គិលានុប្បដ្ឋាក/យិកា)តាមបណ្តាមន្ទីរពេទ្យបង្អែកខេត្ត-ស្រុកនិងមណ្ឌលសុខភាព-តាមដាននិងអភិបាលឱសថ-សំភារៈបរិក្ខារតាមមន្ទីរពេទ្យបង្អែកខេត្ត-ស្រុកតាមតំបន់នៃខេត្តដែលរងការរាតត្បាត (រូបភាព៤-តារាង៣)៖

រូបភាព៤៖





តារាង៣

| Sessions | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| Nursing Care and Dengue Management and Control training to ODs and HCs. | | | | | | |
| 1st session | 52 | 0 | | NPH | 12-14 Jul-2011 | WHO |
| 2nd session | 52 | 24 | | NPH | 31Aug-02Sept2011 | WHO |
| 3rd session | 46 | 13 | | Kg Thom | 16-19 Aug 2011 | HSSP2_Pooled Fund |
| 4th session | 101 | 32 | | Kg Cham | 23-26 Aug 2011 | HSSP2_Pooled Fund |
| 5th session | 78 | 20 | | Prey Vaeng | 30 Aug-02 Sept | HSSP2_Pooled Fund |
| 6th session | 46 | 16 | | B.Mean Chey | 06-09 Sept 2011 | HSSP2_Pooled Fund |
| 7th session | 51 | 08 | | Takeo | 10-12 Oct-2011 | HSSP2_Pooled Fund |

**៣.៤..២.តាមដានក្រោយការបណ្តុះបណ្តាលនិងអភិបាលឪសថ-សំភារៈបរិក្ខារពេលមានការរាតត្បាត** (Followed-up training and supervised medical supplies during dengue outbreak ):

ដើម្បីឱ្យការងារគ្រប់គ្រងជម្ងឺគ្រុនឈាមមានភាពល្អប្រសើរកាត់បន្ថយអត្រាស្លាប់ធានានូវភាពមានគ្រប់គ្រាន់នូវឪសថសំភារៈបរិក្ខារដើម្បីទុកត្រៀមពេលមានការរាតត្បាត កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានកិច្ចសហការយ៉ាងជិតស្និត ជាមួយមន្ត្រី សុខាភិបាលខេត្តនិងឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៏អាស៊ី( ADB_CDC2) ធ្វើការត្រួតពិនិត្យឪសថនិងសម្ភារៈបរិក្ខារនិងអភិបាលបុគ្គលិកក្រោយការបណ្តុះបណ្តាលដើម្បីធ្វើការវាយតម្លៃនូវគុណភាពរបស់មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលហើយនៅតាមបណ្តាខេត្តដែលមានការរាតត្បាតមួយចំនួនដូចជាខេត្តព្រះស៊ីហនុ-ខេត្តតាកែវនិងខេត្តកំពត។

**៣.៤.៣.ការពិនិត្យនិងកែសំរួលមគ្គុទ្ទេសន៏ព្យាបាលជម្ងឺគ្រុនឈាម៖** ( Revised the National dengue guideline ):

ម្យ៉ាងវិញទៀតកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានកិច្ចសហការជាមួយអនុគណៈកម្មការព្យាបាល( មន្ទីរពេទ្យគន្ធបុប្ផា-មន្ទីរពេទ្យកុមារជាតិ-មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត-មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម-ខេត្តតាកែវខេត្តបន្ទាយមានជ័យ ) បានធ្វើការពិនិត្យនិងកែសំរួលឡើងវិញនូវមគ្គុទ្ទេសន៏ព្យាបាលជម្ងឺគ្រុនឈាមដោយឱ្យស្របទៅតាមមគ្គុទ្ទេសន៏ព្យាបាលរបស់អង្គការសុខភាពពិភពលោក។សកម្មភាពនៅកំពុងតែបន្តនិងកែលំអ។

**ខ.ការឆ្លើយតបបន្ទាន់ពេលមានការរាតត្បាតឆ្នាំ២០១១(Measures taken during the dengue outbreak period, 2011 )៖**

ដើម្បីធ្វើការហ៊ុំព័ទ្ធការរីករាលដាលនៃជម្ងឺគ្រុនឈាមពិសេសនារដូវចម្លងនិងការពារនូវការផ្ទុះធ្ងន់ធ្ងរជាយថាហេតុនៃជម្ងឺគ្រុនឈាមកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមក្រោមការគាំទ្រដ៏ខ្លាំងងក្លាពីក្រសួងសុខាភិបាលនិងអង្គការសុខភាពពិភពនិងគាំទ្រថវិកាពីគំរោងទ្រទ្រង់វិស័យសុខាភិបាលជំហ៊ាន២( HSSP2_Pooled Fund )ធនាគារអភិវឌ្ឍន៏អាស៊ី( ADB_CDC2 )និងកិច្ចសហការយ៉ាងជិតស្និតជាមួយមន្ទីរសុខាភិបាលខេត្ត-ស្រុកប្រត្តិបត្តនិងការខិតខំរបស់មន្ត្រីសុខាភិបាលពិសេសតាមមណ្ឌលសុខភាពបានអនុវត្តនូវសកម្មភាពការងារកំចាត់ភ្នាក់ងារចម្លងឆ្លើយតបបន្ទាន់តាមសហគមដូចជា ( ការងារអង្កេតស្រាវជ្រាវ-ឃោសនាអប់រំនិងអប់រំចល័ត )

- ការងារធ្វើអនាម័យបំបាត់ជំរកមូសខ្លា

- ការងារដាក់ថ្នាំបាណកឃាដអាបេតនិងការងារបាញ់ថ្នាំកំចាត់ភ្នាក់ងារចម្លងក្នុងលំហរអាកាស ក្នុងករណីចាំបាច់។ គោលបំណងនៃការឆ្លើយតបបន្ទាន់គឺដើម្បីធ្វើការកំណត់និងផ្ទៀងផ្ទាត់រកប្រភេទមេរោគដែលទទួលខុសត្រូវក្នុងការរាតត្បាត
- ការងារហ៊ុំព័ទ្ធការរាតត្បាតនិងកាត់បន្ថយល្បឿននៃការចម្លងជម្ងឺ-កាត់បន្ថយអត្រាអាំងស៊ីដង់ និងអត្រាមរណៈឱ្យនៅទាប។ ខេត្តទាំងនោះមានជាអាទិ៍ខេត្តកំពង់ធំ-ខេត្តសៀមរាប- រាជធានីភ្នំពេញ- ខេត្តកណ្តាល-ខេត្តកំពង់ចាម-ខេត្តបន្ទាយមានជ័យ-ខេត្តព្រះវិហារ- ខេត្តកំពង់ឆ្នាំង-ខេត្តក្រចេះ-ខេត្តកំពង់ស្ពឺ-ខេត្តកំពត-ខេត្តតាកែវ-ខេត្តព្រៃវែង-ខេត្តពោធិសាត់- ខេត្តបាត់ដំបង-ខេត្តឧត្តរមានជ័យ-ខេត្តស្វាយរៀង-ខេត្តកោះកុង-ខេត្តកែប-ខេត្តរតនៈគិរី- ខេត្តមណ្ឌលគិរី។

## ៣.៥.ការងារអភិបាលកិច្ចជម្ងឺគ្រុនឈាម៖

ការងារអភិបាលជម្ងឺគ្រុនឈាមគឺជាឧបករណ៍មួយដ៏មានសារៈសំខាន់ក្នុងការគ្រប់គ្រងឲ្យបានល្អប្រសើរ និងមានប្រសិទ្ធិភាពនូវសភាពការណ៍ជម្ងឺគ្រុនឈាមនៅមុនអំឡុងពេលនិងបន្ទាប់ពីការរាតត្បាតជម្ងឺគ្រុនឈាម។ យុទ្ធសាស្ត្រអាចធ្វើឱ្យយើងអាចក្តាប់បាននូវរាល់គ្រប់ចំណុចសំខាន់ៗតាមខេត្តនិមួយៗជាពិសេសខេត្តចំណុចដែលមានដង់ស៊ីតេប្រជាជនខ្ពស់-កន្លែងដែលតែងតែធ្លាប់ទទួលរងនូវការរាតត្បាតពីពេលមុនៗ។ កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានការឧបត្ថម្ភនិងគាំទ្រថវិកាពីគំរោងទ្រទ្រង់វិស័យសុខាភិបាលជំហ៊ាន២( HSSP2_Pooled Fund) និងធនាគារអភិវឌ្ឍន៍អាស៊ីបានអនុវត្តនូវការងារអភិបាលនៅតាមចំណុចប្រឈមនឹងគ្រោះថ្នាក់និងរាតត្បាតជម្ងឺគ្រុនឈាមនៃខេត្តមួយចំនួនដូចជា: ខេត្តកំពង់ចាម-ខេត្តព្រះស៊ីហនុ-ខេត្តសៀមរាប-ខេត្តកំពង់ឆ្នាំង-ខេត្តកំពត-ខេត្តតាកែវ - ខេត្តកំពង់ស្ពឺ។





## ៣.៦.ការសិក្សាស្រាវជ្រាវៈការប្រយុទ្ធនឹងជំងឺគ្រុនឈាមក្នុងប្រទេសអាស៊ានដោយប្រើត្រីៗពណ៌

(Operational Research ):

៣.៦.១.Combating dengue in the ASEAN country by using 7 color fish

ក្នុងន័យស្វែងរកយុទ្ធសាស្ត្រផ្សេងៗដែលជាការរួមបញ្ចូលនូវវិធានការកំចាត់ភ្នាក់ងារ ចម្លងកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមដោយមានការគាំទ្របច្ចេកទេសពីអង្គការសុខភាពពិភពលោកនិងឧបត្ថម្ភថវិកាដោយអង្គការADB ក្រសួងសុខាភិបាលបានរួមសហការយ៉ាងជិតស្និតជាមួយមន្ទីរសុខាភិបាលខេត្តកំពង់ចាមបានរៀបចំការសិក្សាការងារកំចាត់ភ្នាក់ងារចម្លងតាមសហគមដែលហៅថា"ការប្រយុទ្ធនឹងជម្ងឺគ្រុនឈាមក្នុងប្រទេសអាស៊ានរបស់សហគមន៍ដោយប្រើត្រីប្រាំពីរពណ៌ "រួមផ្សំនិងការងារសំអាតបរិស្ថានបំបាត់ជំរកមូសនានាដែលស្ថិតនៅជុំវិញផ្ទះក្នុងសហគមនៅស្រុកព្រៃឈរចម្ងាយប្រមាណ 120Km ពីរាជធានីភ្នំពេញ។ គំរោងនេះត្រូវបានចាប់ផ្តើមនៅថ្ងៃ 29

ខែ 07 ឆ្នាំ 2010 ដោយមានការចូលរួមពី **ឯកឧត្តមឌួងសុជាតិ**នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រនិងលោកស្រីវេជ្ជបណ្ឌិតCarol (HLSP)។

**គោលបំណង:**

បង្កើននិងផ្តល់ចំណេះដឹងដល់សហគមន៍នូវវិធានការណ៍ការពារជម្ងឺគ្រុនឈាមដោយប្រើ ត្រីប្រាំពីរពណ៌កាត់បន្ថយដង់ស៊ីតេដង្កូវទឹកមូសខ្លាក្នុងពាង/អាងទឹកតាមភូមិ/ឃុំចំណុចក្នុងបំណងដូចខាងក្រោម:

- បង្កើនសមត្ថភាពរបស់សហគមលើការបំបាត់ជំរកមូសខ្លា
- ការដាក់បញ្ចូលការប្រើភ្នាក់ងារជីវសាស្ត្រក្នុងការកាត់បន្ថយភ្នាក់ងារចំលងជំងឺគ្រុនឈាមក្នុងពាងឬអាងក្នុងភូមិចំណុចដោយប្រើប្រាស់ត្រីប្រាំពីរពណ៌និងគំរបពាង
- ដាក់មញ្ចូលលនូវយុទ្ធសាស្ត្រជាក់ស្តែងក្នុងការអនុវត្តនូវវិធានការណ៍កំចាត់ភ្នាក់ងារចម្លងនិងប្រភពរបស់វា

**ទីកន្លែង:**

កន្លែងដែលអនុវត្តនូវគំរោងនេះគឺការប្រើត្រីរួមផ្សំនិងការងារអនុវត្តនូវគោលការណ៍ COMBIនៅមណ្ឌលសុខភាពតុងរ៉ុងនិងមណ្ឌលសុខភាពព្រែកក្របៅ(តំបន់អនុវត្ត)និងមណ្ឌលសុខភាពគរដោយធ្វើអនាម័យជាទៀងទាត់ (សំរាប់តាមដាន )។

តារាង៤៖

| Area | No. of villages | No. of houses | Population |
|---|---|---|---|
| Kor Health Centre area (control) | 13 | 2,588 | 12,940 |
| Prek Krabao health centre area (intervention) | 11 | 1,829 | 9,145 |
| Tong Rong health centre (intervention) | 18 | 2,271 | 12,124 |

គំរោងនេះត្រូវបានអនុវត្តដោយមានការចូលរួមពីមន្ទីរសុខាភិបាលខេត្តកំពង់ចាមការិយាល័យស្រុកប្រត្តិបត្តព្រៃឈរនិងមណ្ឌលសុខភាព។សកម្មភាពជាច្រើនត្រូវបានអនុវត្តដូចខាងក្រោម:

- មណ្ឌលសុខភាព:បុគ្គលិកមណ្ឌលសុខភាពត្រូវបានទទួលការបណ្តុះបណ្តាលការងារចាប់ដង្កូវទឹកនិងមូសនិងចូលរួមប្រជុំជារៀងរាល់ខែនិងរាយការណ៍មកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់
  - តាមដាននិងត្រួតពិនិត្យអ្នកស្ម័គ្រចិត្តភូមិដែលចុះពិនិត្យតាមផ្ទះ
  - ចុះជាទៀតទាត់ពិនិត្យតាមផ្ទះមួយចំនួនក្នុងន័យបញ្ជាក់ថាតើអ្នកស្ម័គ្រចិត្តបានអនុវត្តត្រឹមត្រូវនៅកន្លែងទាំងនោះឬទេ អ្នកស្ម័គ្រចិត្តភូមិ:
  - អ្នកស្ម័គ្រចិត្តភូមិម្នាក់ទទួលខុសត្រូវប្រហែលចំនួន៥០ខ្នងផ្ទះ
  - ចូលរួមប្រជុំ 2ខែម្តងនៅមណ្ឌលសុខភាព
  - ចុះត្រួតពិនិត្យតាមផ្ទះជាទៀងទាត់-ដោយផ្ទះនិមួយឱ្យបាន 2dgknúg1Ex
  - ពិនិត្យនិងត្រូវប្រាកដថាពិតជាមានត្រីប្រាំពីរពណ៌នៅតាមគ្រប់ពាង/អាងទឹកតាមផ្ទះនិមួយៗ
  - ផ្តល់ដំបូន្មានដល់ម្ចាស់ផ្ទះនូវការពិនិត្យមើលត្រីតាមពាង/អាងទឹក
  - យកត្រីប្រាំពីរពណ៌ទៅដាក់បំពេញតាមពាង/អាងទឹកណាដែលពុំមានត្រី

- លើកទឹកចិត្តម្ចាស់ផ្ទះការងារថែរក្សាត្រីប្រាំពីរពណ៌និងណែនាំឱ្យចេះត្រួតពិនិត្យវត្ថុដែលដក់ទឹកជុំវិញផ្ទះនិងណែនាំឱ្យផ្តាប់វត្ថុទាំងនោះចោលឱ្យអស់
- លើកទឹកចិត្តនិងណែនាំម្ចាស់ផ្ទះក្នុងការនាំសមាជិកគ្រួសារទៅកាន់គ្លីនិកឬមន្ទីរពេទ្យរដ្ឋករណីដែលមានគ្រុនក្តៅ
- ធ្វើការស្តុកនិងចិញ្ចឹមត្រីពពណ៌នៅតាមផ្ទះអ្នកស្ម័គ្រចិត្ត។

• នាយកសាលា/លោកគ្រូ-អ្នកគ្រូ:
  - លើកទឹកចិត្តសិស្សានុសិស្សក្នុងការថែរក្សានូវត្រីប្រាំពីរពណ៌តាមផ្ទះរៀងៗខ្លួននិងតាមសាលារៀន
  - អប់រំ-បង្រៀនដល់សិស្សានុសិស្សនូវវដ្តរបស់ភ្នាក់ងារចម្លងវិធានការណ៍ការពារជម្ងឺគ្រុនឈាមនិងការប្រើប្រាស់ត្រីប្រាំពីរពណ៌ដើម្បីបំបាត់ជំរកមូសខ្លាជាលទ្ធផល:







### ៣.៦.២.សហការជាមួយអង្គការNAMRU2

ក្នុងការសិក្សាMulti-center evaluation of Panbio point-of care and Elisa diagnostic sweats ពីខែកក្កដាឆ្នាំ 2010- ដល់ខែកក្កដាឆ្នាំ 2013, ឧបត្ថម្ភដោយអង្គការ NAMRU2.

### ៣.៦.៣.សហការជាមួយអង្គការKOICA-WHO

ក្នុងការសិក្សានូវ Nationwide dengue vector surveys, ខេត្តសៀមរាប-ខេត្តកំពង់ធំ by KOICA-WHO, ពីខែសីហា-ខែធ្នូឆ្នាំ 2011.

### ៣.៦.៤.រួមសហការជាមួយមន្ទីរពេទ្យកុមារជាតិ

ក្នុងការសិក្សាស្តីImproving the clinical case management and strengthening of dengue fever in Cambodia study, ពីខែមិថុនាឆ្នាំ 2011 ដល់ខែឧសភាឆ្នាំ 2012 ដោយ REDI Singapore.

### ៣.៦.៥.សហការជាដៃគូរជាមួយនាយកដ្ឋានឧត្តុនិយមនិងបរិស្ថាន

សិក្សាអំពីផលប៉ះពាល់របស់បំរែបំរួលអាកាសធាតុទៅនឹងការកើតជម្ងឺគ្រុនឈាមឧបត្ថម្ភដោយអង្គការ WHO/KOICA:កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមបានធ្វើការតាមដាននូវដង់ស៊ីតេរបស់ភ្នាក់ងារចម្លងនិងសិក្សានូវជីវសាស្ត្ររបស់វាទៅនឹងបំរែបំរួលអាកាសធាតុនៅប្រទេសកម្ពុជា។ខេត្តចំនួន 4 ត្រូវបានជ្រើសរើសយកមកធ្វើការសិក្សា:ភូមិ2៖ភូមិ១នៅក្នុងទីប្រជុំជននិងភូមិ១ទៀតនៅតាមទីជនបទដែលតំបន់ទាំងនោះត្រូវបានធ្វើការជ្រើសរើសទៅតាមចំណុចសំរាប់ការអង្កេតដង្កូវទឹក:ខេត្តកណ្តាល:ភូមិព្រែកហូរកើតនិងភូមិអំពៅព្រៃ2-ខេត្តសៀមរាប: ភូមិ

ថ្នល់ទទឹងនិងភូមិដំណាក់ ខេត្តបន្ទាយមានជ័យៈភូមិពង្រនិងភូមិគោឡាដ្ឋាននិងខេត្តមណ្ឌលគិរីៈភូមិពូរ៉ាដែតនិងភូមិកណ្តាល។ផ្ទះចំនួន១០០ខ្នងផ្ទះនៅតាមទីប្រជុំជននៃខេត្តនិមួយៗត្រូវបានធ្វើការអង្កេតបាណកសាស្ត្រនារដូវប្រាំងដូចគ្នាដែរផ្ទះចំនួន១០០ខ្នងផ្ទះនៅតាមចំណុចទាំងនោះតាមទីជនបទដែលនៅជិតទីប្រជុំជនក៏បានធ្វើការអង្កេតផងដែរ។ជាសរុបចំនួនផ្ទះ៨០០ខ្នងបានធ្វើការអង្កេតហើយសំណាកអង្កេតត្រូវបានបញ្ជូនមកមជ្ឈមណ្ឌលដើម្បីធ្វើការអង្កេតនិងផ្ទៀងផ្ទាត់។ប្រព័ន្ធ GPS ត្រូវបានប្រើប្រាស់ក្នុងការកំណត់ទីតាំងដើម្បីការងារអង្កេតនេះ។ឯលទ្ធផលវិភាគនិងធ្វើការបង្ហាញបន្ទាប់ពីចប់គំរោង។

**៣.៧.កិច្ចសហការអន្តរជាតិ-អន្តរក្រសួងនិងឯកជន** ( Inter-sectoral collaboration including private sectors )

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់បានសហការជាមួយភាគីប្រទេសថៃក្នុងគំរោងប្រយុទ្ធនឹងជម្ងឺឆ្លងតាមព្រំដែនរៀបចំវគ្គបណ្តុះបណ្តាលការងារធ្វើរោគវិនិច្ឆ័យព្យាបាលនិងការងារថែទាំអ្នក-ជម្ងឺនិងវគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រនៃជម្ងឺគ្រុនក្តៅស្រួច (AFI) ដោយមានការគាំទ្រថវិកាដោយមូលនិធិម្ចាស់ក្សត្រី Mahachakrei Sirindhorn៖

• បណ្តុះបណ្តាលការងារធ្វើរោគវិនិច្ឆ័យ-ព្យាបាលនិងការងារថែទាំអ្នកជម្ងឺៈ

| | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| Training MD-MA as core trainers | 15 | 01 | | Siem Reap | 7-9Feb 2011 | Sirindhorn Fund |
| Nursing care training as core trainers | 20 | 03 | | Siem Reap | 10-12Feb2011 | Sirindhorn Fund |
| TOT MD-MA to Paediatricians | 16 | 02 | | Rattanakiri | 22-23March11 | Sirindhorn Fund |
| TOT on Nursing care to Nurses at Provincial RH | 23 | 05 | | Rattanakiri | 24-25March 11 | Sirindhorn Fund |
| Continous training of CM to HC and HP staff | | | | Rattanakiri | 28 March 2011 | Sirindhorn Fund |
| Continous training of CM and Dengue prevention to VHVs and Community. | | | | Rattanakiri | 29 March 2011 | Sirindhorn Fund |
| Continous training of CM to HC and HP staff | | | | Mondulkiri | 31March 2011 | Sirindhorn Fund |

| | | | | | | |
|---|---|---|---|---|---|---|
| Continous training of CM and Dengue prevention to VHVs and Community. | | | | Mondulkiri | 1st Apr 2011 | Sirindhorn Fund |

•វគ្គបណ្តុះបណ្តាលអេពីដេមីសាស្រ្ត:

| | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| Training on Epidemiology | | | | Kg Cham | | Sirindhorn Fund |

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់បានសហការជាមួយផ្នែកឯកជនគឺក្រុមហ៊ុន SC Jonhson Jonhson ( RAID/ OFF for kids ) នៃផលិតផលថ្នាំបាញ់មូស RAID រៀបចំទិវាអនាម័យប្រយុទ្ធនឹងជម្ងឺគ្រុនឈាម ( walk rally, commu- nity health education and TV spots on dengue prevention measures ) ក្នុងន័យជូនដំណឹងនិងប្រកាសអាសន្នដល់សហគមទាំងអស់ឱ្យយល់និងដឹងនូវសភាពការណ៏ជម្ងឺគ្រុនឈាមក្រោមអធិបតីភាពលោក**វេជ្ជបណ្ឌិតចម៉េងចួ**នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់នៅរាជធានីភ្នំពេញ។
- ទទួលថវិកាចំនួន 3,514 USD ពីអង្គការ ASSAR ជូនដល់មន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺក្នុងការជួយសកម្មភាពការពារជម្ងឺគ្រុនឈាម:

ការងារដាក់ថ្នាំបាណកយាជអាបេតនៅមណ្ឌលសុខភាពកាហែងនិងតាអរ-ខេត្តកំពង់ស្ពឺ។
រូបភាព6៖





## IV. សកម្មភាពការពារជម្ងឺគ្រុនឈាមផ្សេងៗទៀត( Other dengue prevention activities )

ដើម្បីរក្សាបាននូវស្ថានភាពល្អប្រសើរនូវសភាពការណ៍ជម្ងឺគ្រុនឈាម ,សកម្មភាពជាច្រើនទៀតត្រូវបានអនុវត្តតាំងពីដើមខែមករាហូតមកដល់ខែធ្នូដែលមានដូចជាៈ

- រក្សានិងបង្កើនការតាមដានអេពីដេមីសាស្ត្រជាប្រចាំ
- ធ្វើការប្រមូលនិងទទួលរបាយការណ៏អកម្មនៃជម្ងឺគ្រុនឈាមជាទៀងទាត់តាមបណ្តាខេត្តនានានិងរបាយការណ៏សកម្មតាមមន្ទីរពេទ្យចំណុចជារៀងរាល់អាទិត្យនិងចុះធ្វើការអង្កេតស្រាវជ្រាវជាបន្ទាន់បើសិនចាំបាច់។
- ទំនាក់ទំនងជាមួយ Stakeholders អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសុខភាពពិភពលោកក្នុងការផ្សព្វផ្សាយនិងធ្វើឱ្យមានភាពទាន់សភាពការណ៏នូវរបាយការណ៏អេពីដេមីសាស្ត្រជារៀងរាល់48ម៉ោង ម្តង។
- ទំនាក់ទំនងជាមួយវិទ្យាស្ថានជាតិប៉ាស្ទ័រក្នុងការស្រាវជ្រាវរកភាពបំរែបំរួលនិងមេរោគវីរុសដែលរាតត្បាតជម្ងឺគ្រុនឈាម។
- រៀបចំសិក្ខាសាលាស្តីពីគោលការណ៏ប្រើប្រាស់ថាថ្នាំបាណកឃាដក្នុងវិស័យសុខាភិបាល សាធារណៈចំនួន ១វគ្គជូនដល់ក្រុមការងារឆ្លើយតបបន្ទាន់ជម្ងឺគ្រុនឈាមដល់មន្ត្រីថ្នាក់ខេត្តទាំង24 ខេត្ត/ក្រុង ( តារាងទី 6)៖

| Activities | Participants | | | Places | Date | Funding source |
|---|---|---|---|---|---|---|
| | Total | Female | Ethnic | | | |
| **Training** on Rational use of Public Health Insecticide of Emergency Vector Control | | | | | | |
| 1st session | 92 | 18 | | Kg Speu | 26-30Dec 11 | HSSP2_Pooled Fund |

- ការងារប្រជុំជម្ងឺគ្រុនឈាមប្រចាំខែជារៀងរាល់ 2- 3Exmþg នៅខេត្តតាកែវនិងរាជធានីភ្នំពេញពិភាក្សានិងជូនដំណឹងដល់គណៈកម្មាធិការជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមនិងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការពិគ្រោះនិងប្តូរបទពិសោធការងារគ្រប់គ្រងល្អប្រសើរនូវសភាពការណ៏ជម្ងឺគ្រុនឈាម។
- កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាមបានទទួលនូវសម្ភារៈការិយាល័យពីគំរោងទ្រទ្រង់វិស័យសុខាភិបាលជំហ៊ានទី២ ( HSSP2_PF ) ដូចជា៖

  តារាង 7:

| Items | | Number | Sources |
|---|---|---|---|
| Laptop | Lenovo B4 50- GL40 | 01 | HSSP2_Pooled |
| Desktop | lenovo | 01 | HSSP2_Pooled |
| LCD projector | NEC NP 115P | 01 | HSSP2_Pooled |
| Laptop | | 05 | HSSP2_Pooled |
| Desktop | | 04 | HSSP2_Pooled |
| Printer ( color laserjet ) | FUJI Xerox FX CLJ C 2200 | 01 | HSSP2_Pooled |

## V. ការបែងចែកឱសថនិងថ្នាំបាណកយាដ

( Drugs, Insecticides distributed and other supplies ) ៖

ដើម្បីជានាត្រៀមទប់ស្កាត់ការរាតត្បាតជាយថាហេតុនៃជម្ងឺគ្រុនឈាមកម្មវិធីជាតិបានសហការជាមួយឃ្លាំងឱសថកណ្តាលធ្វើការបែងចែកដល់គ្រប់មន្ទីរសុខាភិបាលខេត្ត/ក្រុងទាំង 24 នូវសម្ភារៈ-បរិក្ខារអប់រំនិងថ្នាំបាណកយាដ។

តារាង 8:

**Distribution list of larvicides and adulticide to 24 Provinces ( 2Rounds ), 2011**

| | Province'names | 1R Abate Quantity ( Kg ) | 1RBti Quantity ( kgs ) | 2R AbateQuantity ( Kg ) | 2R Bti Quantity ( kgs ) | Additional |
|---|---|---|---|---|---|---|
| 1 | Phnom-Penh | 8,000 | | 11,000 | | Insecticide space spray 400L |
| 2 | Kg Cham.. | 11,000 | | 0 | | |
| 3 | Kandal | | 2,600 | | 260 0 | Additional Bti 300Kgs |
| 4 | Siem Reap | 8,000 | | 12,000 | | |
| 5 | B Mean Chey | 8,000 | | 8,000 | | |
| 6 | Battambang | 7,000 | | 7,000 | | |
| 7 | Pailin | 1,200 | | 1,200 | | |
| 8 | Oddor Mean Chey | 1,800 | | 2,000 | | |
| 9 | Pursat | 6,200 | | 6,200 | | |
| 10 | Kg Chhnang.. | 1,300 | | 1,300 | | |
| 11 | Kg Thom | 4,000 | | 4,500 | | Insecticide space spray 150L |
| 12 | Prah vihea | 2,500 | | 2,600 | | |
| 13 | Prey Veng | 1,700 | | 0 | | |

| | | | | | | |
|---|---|---|---|---|---|---|
| 14 | Kg Speu | 6,000 | | 6,000 | | |
| 15 | Prah Sihanuok.. | 1,300 | | 3,000 | | |
| 16 | Koh Kong | 2,200 | | 0 | | |
| 17 | Rattanakiri | 1,500 | | 2,000 | | |
| 18 | Mondolkiri | 500 | | 0 | | |
| 19 | Stung Traeng | 1,500 | | 0 | | |
| 20 | Takeo | 5,000 | | 0 | | |
| 21 | Kampot | 4,000 | | 0 | | |
| 22 | Kep | 1,000 | | 1,000 | | |
| 23 | Svay Rieng | 2,500 | | 2,700 | | |
| 24 | Kratie | 2,000 | | 2,500 | | |
| 25 | National Program | 5,000 | | 0 | | |
| | | 93,200 | 2,600 | 73,000 | 2,6<br>00 | |

Distribution list of IV fluid and suppliies to differents 24 Provinces and Central Hospitals, April 2011

| | Province' names | Dextran40+ Set | Dextran40 (500ml) without Set | Acetate Ringer 1000ml | Acetate Ringer 1000ml without set | Dextrose5%+ Nacl 9% (100ml) | Dextrose5%+ Nacl3% (1000ml) | Dextrose5%+ Acetate (1000ml) | Catheter No 22 |
|---|---|---|---|---|---|---|---|---|---|
| 1 | Phnom-Penh | 0 | 30 | 30 | 30 | 30 | 160 | 20 | 410 |
| 2 | Kg Cham | 175 | 70 | 50 | 70 | 120 | 310 | 70 | 950 |
| 3 | Kandal | 0 | 80 | 20 | 80 | 80 | 192 | 60 | 480 |
| 4 | Siem Reap | 0 | 45 | 30 | 45 | 40 | 145 | 50 | 400 |
| 5 | B.Mean Chey | 60 | 45 | 50 | 50 | 85 | 190 | 50 | 400 |
| 6 | Battambang | 65 | 20 | 30 | 20 | 60 | 140 | 50 | 300 |
| 7 | Pailin | 0 | 25 | 15 | 25 | 35 | 70 | 36 | 150 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 8 | OddorM. Chey | 0 | 20 | 20 | 20 | 30 | 70 | 30 | 130 |
| 9 | Pursat | 20 | 0 | 30 | 0 | 50 | 130 | 30 | 350 |
| 10 | Kg Chhnang | 0 | 50 | 30 | 40 | 55 | 110 | 30 | 350 |
| 11 | Kg Thom | 40 | 30 | 30 | 35 | 35 | 120 | 30 | 350 |
| 12 | Prah vihea | 20 | 50 | 30 | 40 | 40 | 100 | 30 | 250 |
| 13 | Prey Veng | 40 | 60 | 35 | 60 | 110 | 270 | 70 | 600 |
| 14 | Kg Speu | 20 | 35 | 30 | 35 | 35 | 140 | 30 | 300 |
| 15 | Prah Sihanuok | 20 | 10 | 20 | 10 | 40 | 70 | 20 | 250 |
| 16 | Koh kong | 20 | 35 | 20 | 45 | 35 | 90 | 30 | 220 |
| 17 | Rattanakiri | 0 | 40 | 20 | 30 | 40 | 60 | 30 | 200 |
| 18 | Mondolkiri | 0 | 30 | 20 | 30 | 30 | 70 | 10 | 150 |
| 19 | Stung Traeng | 0 | 30 | 20 | 30 | 40 | 70 | 20 | 200 |
| 20 | Takeo | 0 | 100 | 30 | 84 | 104 | 175 | 70 | 450 |
| 21 | Kampot | 40 | 60 | 20 | 60 | 70 | 140 | 30 | 400 |
| 22 | Kep | 0 | 20 | 15 | 20 | 30 | 70 | 30 | 145 |
| 23 | Svay Rieng | 0 | 50 | 20 | 50 | 60 | 110 | 40 | 300 |
| 24 | Kratie | 20 | 50 | 20 | 50 | 55 | 90 | 20 | 220 |
| 25 | Nati. PaedHop | | | 75 | 100 | 150 | 150 | 100 | 200 |
| 26 | KanthaBopha | | | 80 | 100 | 150 | 150 | 100 | 200 |
| 27 | Alien Khmero-Soviet Hosp | 55 | 55 | 60 | 75 | 130 | 150 | 90 | 200 |
| | Whole Country | **595** | **1,040** | **850** | **1,234** | **1,739** | **3,542** | **1,176** | **8,555** |

## IV. **បណ្តុះបណ្តាល**( Capacity building )

- បណ្តុះបណ្តាល/ប្រជុំក្រៅប្រទេស (oversea training/ conference)

- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម 2រូបបានត្រូវបញ្ជូនទៅចូលរួមសិក្ខាសាលាស្តីពី ″Asia-Pacific Dengue Prevention Board: Planning for introduction of Dengue Vaccine ″ ឆ្នាំ 2011 នាទីក្រុងហាណូយ ប្រទេសវៀតណាមឧបត្ថម្ភថវិកាដោយ Dengue Vaccine Initiative (DVI) ។
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់បច្ចេកទេសលើការលុបបំបាត់ជម្ងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជាថ្ងៃទី 8-9មិថុនាឆ្នាំ 2011 នៅសណ្ឋាគារ Raffles Hotel Le Royal ឧបត្ថម្ភថវិកា ដោយអង្គការសុខភាព ពិភពលោក។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម 1រូបបានត្រូវបញ្ជូនទៅចូលរួមសិក្ខាសាលាស្តីពី ″ ASEAN Dengue Day″ នៅថ្ងៃទី 15 ខែមិថុនាឆ្នាំ 2011 នៅប្រទេសសាំងហ្គាពួរដែលឧបត្ថម្ភដោយរដ្ឋាភិបាលសាំងហ្គាពួរ។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម 1រូបនឹង០១រូបទៀតមកពីនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លង-ក្រសួងសុខាភិបាលបានត្រូវបញ្ជូនទៅចូលរួមសិក្ខាសាលាស្តីពី ″ ASEAN Dengue Day″ នៅទីក្រុងហ្សាការតា-ប្រទេសឥណ្ឌូនេស៊ីពីថ្ងៃទី 13- 15 ខែមិថុនាឆ្នាំ 2011 ឧបត្ថម្ភដោយរដ្ឋាភិបាល ឥណ្ឌូនេស៊ី។
- មន្ត្រីជាន់ខ្ពស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់-កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនឈាម2រូបបានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ‟ WHO ASEAN Workshop on Priority Actions for Dengue Prevention and Control ″ ថ្ងៃទី 3-5ឧសភា 2011 នៅទីក្រុងម៉ានីល-ប្រទេសហ្វីលីពីនឧបត្ថម្ភថវិកាដោយ USAID IDENTIFY Project។

- មន្ត្រីជាន់ខ្ពស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ 3រូប( CNM 1រូបនិង NDCP 2រូប )បានអញ្ជើញចូលរួមសិក្ខាសាលាផ្តួចផ្តើមស្តីអំពីបំរែបំរួលអាកាសធាតុនៅថ្ងៃទី 29 ខែមិនាឆ្នាំ 2011 សណ្ឋាគារភ្នំពេញរាជធានីភ្នំពេញឧបត្ថម្ភថវិកាដោយអង្គការសុខភាពពិភពលោក (WHO)។
- ចូលរួមសន្និបាតបូកសរុបការងារប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់នៅសណ្ឋាគារអំព្រេស-សៀមរាប-អង្គរ។
- បានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវមគ្គុទ្ទេសន៏ព្យាបាលសម្មារណកម្មជម្ងឺកុមារថ្ងៃទី 11-12 មេសាឆ្នាំ 2011 នៅសណ្ឋាគារឆ្នេរខ្សាច់មាស-ខេត្តព្រះស៊ីហនុឧបត្ថម្ភថវិកាដោយអង្គការសុខភាព ពិភពលោក (WHO)។
- ចូលរួមសិក្ខាសាលាស្តីពីការងារពិនិត្យលទ្ធផលឆមាសទី១នៃការអនុវត្តន៏ផែនការប្រតិបត្តឆ្នាំ2011 នៅសណ្ឋាគារកាំបូឌីយាំណាភ្នំពេញថ្ងៃទី 4-5 កក្កដាឆ្នាំ 2011។
- ចូលរួមសិក្ខាសាលាចាប់ផ្តើមអនុវត្តនគម្រោងប្រយុទ្ធនឹងជម្ងឺឆ្លងក្នុងមហាអនុតំបន់មេគង្គទី២គំរោងគ្រប់គ្រងជម្ងឺឆ្លងក្នុងតំបន់ (GMS_CDC2) នៅសណ្ឋាគារភ្នំពេញ 7-8 កក្កដាឆ្នាំ 2011 ឧបត្ថម្ភដោយ HSSP2/ADB_GMS CDC2។
- ចូលរួមជាមួយមជ្ឈមណ្ឌលលើកកំពស់សុខភាពក្នុងទិវាប្រយុទ្ធនឹងជម្ងឺគ្រុនឈាមនៅខេត្តកំពង់ចាមនិងខេត្ត សៀមរាបឧបត្ថម្ភថវិកាដោយអង្គការ Plan។

- ចូលរួមកិច្ចប្រជុំស្តីពី "The use of Wolbachia as a novel approach to dengue control, a consultation with neighboring countries" នៅទីក្រុងហាណូយថ្ងៃទី២៤ខែសីហាឆ្នាំ 2011 ឧបត្ថម្ភដោយអង្គការ AusAID។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម១រូបនិង 1រូបទៀតមកពីវិទ្យាស្ថានប៉ាស្ទ័របានចូលរួមកិច្ចប្រជុំស្តីពីជម្ងឺ Chikunkunya survey ខែកញ្ញាឆ្នាំ2011 នៅទីក្រុងប្រទេសម៉ាឡេស៊ី។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម២រូបបានចូលរួមសិក្ខាសាលាស្តីពី the EpiData- Data Management and Basic Statistic នៅសណ្ឋាគារតារាអង្គរ-សៀមរាបពីថ្ងៃទី១១-១៣ខែតុលាឆ្នាំ២០១១ឧបត្ថម្ភដោយ អង្គការ NAMRU-2។
- ចូលរួមសិក្ខាសាលាស្តីពី 1st Regional Workshop and 1st Regional Steering Committee Meeting of the Second GMS Regional Communicable Diseases Control Project នៅសណ្ឋាគារ Don Chan Palace Hotel ទីក្រុងវៀងច័ន្ទសាធារណៈរដ្ឋប្រជាមានិតឡាវថ្ងៃទី 29-30 ខែវិច្ឆិកាឆ្នាំ 2011 ឧបត្ថម្ភដោយ ADB_GMS _CDC2។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម១រូបបានចូលរួមសិក្ខាសាលាស្តីពី the EpiData- Data Management and Basic Statistic ពីថ្ងៃទី 18-21 ខែមករាឆ្នាំ២០១១ទីក្រុងវៀងច័ន្ទសាធារណៈរដ្ឋប្រជាមានិតឡាវ-ឧបត្ថម្ភដោយ Regional Emerging Diseases Intervention ( REDI )។
- មន្ត្រីជាន់ខ្ពស់កម្មវិធីជាតិគ្រុនឈាម១រូបបានចូលរួមកិច្ចប្រជុំ ASTMH នៅទីក្រុង Philadelphia សហរដ្ឋអាមេរិកពីថ្ងៃ៤-៨ខែធ្នូឆ្នាំ២០១១ឧបត្ថម្ភដោយ Valent Biosciences corporation។
- ក្រុមការងារកម្ពុជាដែលមានមន្ត្រីសុខាភិបាលចំនួន១២រូប( ៣រូបពីកម្មវិធីជាតិ-៩រូបពីខេត្តកំពង់ចាម )បានចូលរួមកិច្ចប្រជុំបញ្ចប់ស្តីពី the Regional Public Goods for Health Combating Dengue in ASEAN នៅថ្ងៃទី 13-14 ខែធ្នូឆ្នាំ 2011 នៅសណ្ឋាគារ Mercure Hotel សាធារណៈរដ្ឋប្រជាមានិតឡាវ-ឧបត្ថម្ភដោយ HLSP។

# កម្មវិធីកំចាត់ជំងឺដង្កូវព្រូន

# ឃ/របាយការណ៏បូកសរុបការងារផ្នែកកំចាត់ជំងឺដង្កូវព្រូនឆ្នាំ២០១១

## I.ការគ្រប់គ្រង និងសំរបសំរួលសហប្រតបត្តិការ

ផែនការសកម្មភាពថ្នាក់ជាតិសំរាប់ការ រួមបញ្ចូលការគ្រប់គ្រងកម្មវិធីកំចាត់ជំងឺដង្កូវព្រូននៅតំបន់ប្រទេសក្តៅដែលគេមិនចាប់អារម្មណ៏នៅប្រទេសកម្ពុជាបានត្រូវរៀបចំចងក្រងឡើងក្នុងខែធ្នូ២០១០និងបានបញ្ចប់ជាស្ថាពរ ក្នុងខែធ្នូ២០១១ដោយការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្រ្ត និង បាណកសាស្រ្ត (ម.គ.ច) នៃក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងមាន ការជួយសំរបសំរួល និងកែលំអរដោយអង្គការសុខភាពពិភពលោក (WHO)។ ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះ បុគ្គលិកអង្គការ WHO ដែលបានចូលរួមចំណែកជួយចែករំលែកក្នុងការបង្កើតជាឯកសារនេះឡើង។ (សូមមើលអត្ថបទទាំងស្រុងក្នុងឧបសម្ពន្ធទី៣)។

កម្មវិធីដង្កូវព្រូនក៏បានបង្កើតនិងចងក្រងផងដែរ នូវការវិភាគពីគំលាតមូលនិធិដើម្បីជួយផ្នែកថវិការសំរាប់ទ្រទ្រង់ផែនការសកម្មភាពរបស់កម្មវិធីកំចាត់ជំងឺដង្កូវព្រូនក្នុងគោលបំណង៖

1. កំណត់ពីតម្លៃនៃផែនការសកម្មភាពជាតិរួមបញ្ចូលស្តីពីជំងឺដង្កូវព្រូនស្របគ្នាជាមួយនឹងមគ្គុទេស៏អន្តរជាតិ និងផែនការថ្នាក់ជាតិសំរាប់ប្រទេស។
2. កម្រិតចំនួនប្រភពធនធានដែលមានពីរាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៏
3. កំណត់ពីគំលាតមូលនិធិដែលត្រូវការបំពេញបន្ថែមដើម្បីសំរេចគោលដៅកម្មវិធីជាតិក្នុងទិសដៅលុបបំបាត់ជំងឺព្រូនមួយចំនួន។

លទ្ធផលជាវិជ្ជមានដែលកម្មវិធីដង្កូវព្រូនទទួលបានពីការប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូថ្នាក់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ (stakeholder) នៅសណ្ឋាគារ រ៉ាហ្វាលឡឺរ៉ូយ៉ាល់, ភ្នំពេញ ដោយកម្មវិធីជាតិរំពឹងថានឹងបានទទួលនូវជំនួយថ្នាំទំលាក់ព្រូនពីអង្គការ World Vision Australia (Albendazole400mg 10 million tables and Praziquantel600mg 300,000 tablets) ដែលបន្ថែមលើជំនួយរបស់អង្គការJ&J (Mebendazole500mg 5 million tables)។ទន្ទឹមគ្នានោះដែរទីភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិ សហរដ្ឋអាមេរិក (USAID)ក៏បានសន្យានឹងជួយឧបត្ថម្ភថវិការមួយចំនួនរួមចំណែកក្នុងការអនុវត្តន៏ផែនការ សកម្មភាពក្នុងទិសដៅជួយស្តាសុខភាពកុមារអោយឆ្លងផុតពីការចំលងនៃដង្កូវព្រូនដើម្បីអោយកុមារមានសុខភាពល្អនិងជួយដល់កម្មវិធីក្នុងការឈានទៅលុបបំបាត់ជំងឺ ព្រូនប្រភេទខ្លះដែលធ្វើអោយប៉ះពាល់ដល់កាយសម្បទា ប្រជាជនរំខានដល់ជីវភាពរស់ នៅនិងអាចអាយស្លាប់ដូចជា: ជំងឺ ស៊ីស្តូ (Schistosomiasis),ជំងឺព្រូនអំបោះ (Lymphatic filariasis)។

សមាជិកសមាជិកាដែលបានចូលរួមនៅក្នុងសិក្ខាសាលាស្តីពី NTD stakeholder meetingមានអង្គការថ្នាក់ជាតិ និងអន្តរជាតិដូចជា:WPRO, USAID, WVA, WHO, FHI 360, CWW, GIZ, HKI ព្រមទាំងក្រសួង, ស្ថាប័ន, និងអង្គភាពជាដៃគូសហការមួយចំនួនដូចជា៖ រដ្ឋបាលជលផល, នាយកដ្ឋានសុខភាពសិក្សា, ក្រសួងកិច្ចការនារី, ក្រសួងអភិវឌ្ឍន៏ជនបទ, មជ្ឈមណ្ឌលលើកកំពស់សុខភាព, មជ្ឈមណ្ឌលគាំពារមាតានិងទារក, កម្មវិធីចាក់ថ្នាំបង្កា, HSSP2 ect……

## II. ការតាមដានពីប្រសិទ្ធិភាពនៃការផ្តល់ថ្នាំទំលាក់ព្រូន:

រៀងរាល់ឆ្នាំមុននឹងចាប់ផ្តើមអនុវត្តការផ្តល់ថ្នាំជាសមូហភាពកម្មវិធីជាតិកំចាត់ជំងឺព្រូននៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងប៉ាណកសាស្ត្រដោយរួមសហការជាមួយមន្ទីរសុខាភិបាលខេត្តបានចុះធ្វើការ អង្កេតស្រាវជ្រាវរកមើលជំងឺស៊ីស្តូ និង ព្រូនពោះវៀនតាមរយៈការពិនិត្យសំណាកលាមកពីកុមារសិស្សសាលាបឋមសិក្សា និងពីសហគមន៏នៅខេត្តមួយចំនួន*(see table 1)* ដើម្បីវាយតម្លៃអំពី ប្រសិទ្ធភាពថ្នាំព្រូនប្រភេទPraziquantel(40mg/kg) និង Mebendazol (500mgលេបម្តង)ក៏ដូចជាការវាស់វែងអំពីចំណេះដឹងរបស់សហគមន៍អំពីវិធីសាស្ត្រ ការពារជំងឺ។

តាមរយៈកម្មវិធីជាតិប្រជាជនចំណុច ទាំងអស់ត្រូវបានទទួលថ្នាំព្រូនព្យាបាលដោយមិនគិតថ្លៃ ។

Table 1: *ការសិក្សាស្រាវជ្រាវ នឹងតាមដានរកអត្រាប្រេវ៉ាឡង់នៃជម្ងឺដង្កូវព្រូនមុនធ្វើការព្យាបាលតាមសាលាបឋមសិក្សា នឹង ក្នុងសហគមន៍ក្នុងឆ្នាំ ២០១១ របស់គម្រោង* HSSP2:

| Province | *T. trichiura* | Hookworm | *A.Imbricoides* | *Enterobius vermicuralis* | *Hymenolepis nana* | Schisto |
|---|---|---|---|---|---|---|
| Kratie(2287) | 1 (0.04) | 521 (22.78) | 3 (0.13) | 3 (0.13) | 4 (0.18) | 3 (0.13) |
| Kg.Cham (524) | 3 (0.57) | 11 (2.09) | 12 (2.29) | 3(0.57) | 0 | 0 |
| Prey Veng (1133) | 0 | 109 (9.62) | 1 (0.08) | 0 | 2 (0.17) | 0 |
| Mondul kiri (1230) | 0 | 186 (15.12) | 1(0.08) | 3 (0.24) | 3 (0.24) | 0 |
| koh kong(266) | 1 (0.37) | 22 (8.27) | 8 (3.00) | 0 | 0 | 0 |
| kg.speu (269) | 1 (0.37) | 27 (10.03) | 3 (1.11) | 0 | 3 (1.11) | 0 |
| Sihanouk vill(208) | 18 (8.65) | 28 (13.46) | 4 (1.92) | 0 | 2 (0.96) | 0 |
| StungTreng(3185) | 0 | 432 (13.56) | 0 | 0 | 0 | 5 (0.16) |
| Ratanakiri (417) | 0 | 22 (5.28) | 14 (3.36) | 1 (0.24) | 2 (0.48) | 0 |
| Pursat (206) | | 22 (10.68) | 14 (6.80) | 1 (0.48) | 0 | 0 |
| Pailin(210) | 4 (1.90) | 18 (8.57) | 11 (5.23) | 0 | 3 (1.42) | 0 |
| B.bang (516) | 0 | 37 (7.17) | 12 (2.33) | 0 | 18 (3.49) | 0 |
| **Total (7,266)** | **28 (0.39)** | **1435 (19.75)** | **83 (1.15)** | **11 (0.15)** | **37 (0.50)** | **8 (0.11)** |

### ក-ការប្រយុទ្ធនឹងជំងឺដង្កូវព្រូនដែលឆ្លងតាមការប៉ះពាល់ដី:

ដូចជាព្រូនចង្កឹះ (*Ascaris lumbricoide*), ព្រូនទំពក់ (Hookworms: *Ancylostoma duodenal and Nacator americanis*), ព្រូនអៀន (Pinworm:*Enterobius vermicularis*); ព្រូនរំពាត់សេះ (*Trichuris trichiura*); ព្រូនខ្សែអំបោះ(*Strongyloide stercoralis*)ដែលសព្វថ្ងៃមានប្រជាជនប្រឈមជាង៨.៥លាននាក់ ។

អន្តរាគមន៏ដែលត្រូវអនុវត្តន៏ជាប្រចាំចំពោះព្រូនដែលឆ្លងតាមការប៉ះពាល់តាមដីមាន៣គឺ៖

**ទី១.**បន្ថយការកើតជំងឺដង្កូវព្រូនដែលចំលងតាមរយ:ការប៉ះពាល់ដី ចំពោះកុមារត្រៀមចូលសាលា, កុមារសិស្សសាលាបឋមសិក្សា, ស្ត្រីស្ថិតក្នុងវ័យបន្តពូជដោយការផ្តល់ថ្នាំទំលាក់ព្រូនជាសមូហភាព។

**ទី២**.បង្កើនចំណេះដឹងដើម្បីអោយមានការផ្លាស់ប្តូរទំលាប់និងការប្រព្រឹត្តក្នុងន័យការពារស្កាត់ការចំលងរាលដាលនៃពពួកដង្កូវព្រូនដែលចំលងតាមដីតាមរយៈគ្រូបង្រៀននិងមន្ត្រីមណ្ឌលសុខភាពដោយការប្រើប្រាស់ សំភារៈ អប់រំសុខភាព។

**ទី៣**.បង្កើនចំណេះដឹងផ្នែកអនាម័យផ្ទាល់ខ្លួននិងបរិស្ថានដល់កុមារសិស្សសាលានឹងសហគមន៍ ។

ចាប់តាំងពីឆ្នាំ ២០០៥ មកអត្រាគ្របដណ្តប់ការផ្តល់ថ្នាំទំលាក់ព្រូន២ដងក្នុង១ឆ្នាំសំរាប់ សិស្សសាលាបឋមសិក្សាសំរេចបានលើសពី៩០%។ ក្នុងឆ្នាំ២០១១អត្រានេះមាន៩៣% សំរាប់ជុំទី១និង៨៨%នៅជុំទី២ដោយមាន គ្រោះទឹកជំនន់។

ក្នុងឆ្នាំ២០១១អត្រាគ្របដណ្តប់នៃការផ្តល់ថ្នាំទំលាក់ព្រូនលើកុមារអាយុពី១២-៥៩ខែ មានការកើន ឡើងពី៦៥%ក្នុងឆ្នាំ២០១០ មកដល់៧៥% ក្នុងឆ្នាំ២០១១។ ស្ត្រីក្នុងវ័យបន្តពូជមាន អាយុចាប់ពី ១៥-៤៥ឆ្នាំ ក្នុង៨ខេត្ត(ព្រៃវែង,កំពត,ព្រះសីហនុ,បាត់ដំបង,កំពង់ធំ,ស្ទឹងត្រែង,រតនគីរី និង មណ្ឌលគីរី) បានទទួលថ្នាំព្រូនចំនួន ៩៩,៤៩០នាក់ រស្មើនឹង ២៣% ។ អង្គការ សុខភាពពិភពលោកបានប្រកាសថា ប្រទេសកម្ពុជា ជាប្រទេសទី១ លើពិភពលោក ដែលបានសំរេចសុច្ចនករនេះបានលើសពី ៧៥% មុនឆ្នាំ២០១០។ កត្តាបរិស្ថាននិងសង្គមសេដ្ឋកិច្ចចំពោះស្ថានភាពរស់ នៅរបស់ប្រជាជន ជាពិសេស អ្នកក្រីក្រនៃប្រទេសកម្ពុជា ដែលជាកត្តានាំអោយកុមារត្រូវទទួលរងនឹងការចំលងឡើងវិញរយះពេល ៣-៤ខែក្រោយ ពីការលេបថ្នាំទំលាក់ព្រូន។ ហេតុនេះកម្មវិធីផ្តល់ ថ្នាំទំលាក់ព្រូន ត្រូវតែបន្តជាប្រចាំនូវការផ្តល់ថ្នាំទំលាក់ព្រូនមេបង់ដាហ្សូល់ឲ្យបាន២ដងក្នុង១ ឆ្នាំដល់កុមារក្នុង វ័យសិក្សា (៥-១៥ឆ្នាំ) ទាំងអស់តាមរយះកម្មវិធីទំលាក់ព្រូននៅតាមសាលារៀននិងកុមារត្រៀមចូលសាលារៀន (១២-៥៩ខែ) តាមរយះសេវាចុះមូលដ្ឋានដោយមិនគិតពីអត្រាប្រេវ៉ាឡង់ដោយហេតុថាការព្យាបាលជ្រើសរើស តែអ្នកដែលមានវត្តមានដង្កូវព្រូនគឺមិនអាចធ្វើទៅបានទេនៅក្នុងប្រទេសកម្ពុជា។ ចំណែកឯសមាជិកសហគមន៍ ដទៃទៀតជាពិសេសស្ត្រីក្នុងវ័យបន្តពូជក៏ត្រូវតែផ្តល់ថ្នាំទំលាក់ព្រូនផងដែរ។

Mass deworming coverage of different risk groups in Cambodia, Actual 2006 – 2011 vs plan 2012

| Population group | 2007 | 2008 | 2009 | 2010 | 2011 Target | 2011 actual | 2012 Target |
|---|---|---|---|---|---|---|---|
| Preschool children | | | | | | | |
| Population at risk | 1,324,650 | 1,386, 592 | 1,124,668 | 1,386,453 | 1,386,453 | 1,386,453 | 1,386,453 |
| Population targeted | 1,324,650 | 1,339, 571 | 1,124,668 | *1,386,453* | *1,386,453* | *1,386,453* | *1,386,453* |
| Population treated & program coverage ( % ) | 1,226,530 ( 90% ) | 1,146,2 05 ( 85.6 % ) | 966,960 ( 86% ) | *1,073,049* | *1,125,349* | *1,125,349* | *1,285,518* |
| National coverage of population at risk | 90% | 82.7% | 86% | *77 %* | *81%* | *81%* | *92.71* |
| Geographic coverage ( of endemic provinces ) | 24/24 ( 100% ) | 23/24 ( 96% ) | 24/24 ( 100% ) | *24/24 ( 100% )* | *24/24 ( 100% )* | *24/24 ( 100% )* | *24/24* |
| School aged children | | | | | | | |
| Population at risk | 2,574,197 | 2,481,699 | 2,811,671 | *2,640,000* | *2,628,381* | *2,628,381* | *2,628,381* |
| Population targeted | 2,574,197 | 2,481,6 99 | 2,811,671 | *2,563,440* | *2,378,094* | *2,378,094* | *2,628,381* |
| Population treated &program coverage ( % ) | 2,377,49 3 ( 92.4% ) | 2,429,114 ( 97.9% ) | 2,520,114 ( 90% ) | *2,563,440* | *2,378,094* | *2,378,094* | *2,524,389* |
| National coverage of population at risk | 92.4% | 97.9% | 90% | *97.1%* | *90.47%* | *90 %* | *96 %* |
| Geographic coverage ( of endemic provinces ) | 24/24 ( 100% ) | 24/24 ( 100% ) | 24/24 ( 100% ) | *24/24 ( 100% )* | *24/24 ( 100% )* | *24/ 24( 100% )* | *24/24 ( 100% )* |
| Women of Child Bearing age | | | | | | | |
| Population at risk | 3,685,000 | 3,800,000 | 3,900,000 | *3,455,929* | *3,455,929* | *3,455,929* | *3,455,929* |
| Population targeted | Antenatal & lactating women ( 360,000 ) | Antenatal &lactating women ( 375,000 ) | Antenatal & lactating women ( 414,000 ) | Antenatal & lactating women ( 290,000 ) | Antenatal & lactating women ( 43,772 ) | Antenatal & lactating women ( 43,772 ) | Antenatal & lactating women ( 856,815 ) |
| Population treated & program coverage ( % ) | 226,333 ( 62.8% ) | 290,461 ( 77.4% ) | 314,640 ( 76% ) | *277,820 ( 95.8% )* | *99,490 ( 23% )* | *99,490 ( 23% )* | *820,000 ( 95% )* |
| National coverage of population at risk | 6.14% | 7.6% | 8.6% | *7.02%* | *2.8%* | *2.8%* | *24 %* |
| Geographic coverage ( of endemic provinces ) | 24/24 ( 100% ) | 24/24 ( 100% ) | 24/24 ( 100% ) | *24/24 ( 100% )* | *8/24 ( 100% )* | *8/24( 100% )* | *10/24( 100% )* |

**ខ.ការប្រយុទ្ធនឹងព្រូនស៊ីស្តូ (Schistosomiasis) ដែលឆ្លងតាមការប៉ះពាល់ទឹក**

ដោយកូនដង្កូវព្រូន *ចេញពីសត្វខ្យងខ្លា*រួចហើយហែលទឹកមកចូលជ្រៀតតាមស្បែកចូលក្នុងខ្លួនមនុស្ស បង្កឲ្យមានជំងឺថ្លើម។ សកម្មភាពប្រយុទ្ធនឹងជំងឺនេះ ទទួលជោគជ័យតាមរយៈការផ្តល់ឱសថ ប្រាស៊ីកង់តែលទូទាំងសហគមន៍ (Mass Drug Administration) នៅភូមិដែលមានស៊ីស្តូ ក្នុងខេត្តក្រចេះ (៥៨ភូមិ) និងខេត្តស្ទឹងត្រែង (៥៨ភូមិ) ក្នុងនោះ។ អត្រាឈឺនៅភូមិទាំងនេះត្រូវបានកាត់បន្ថយពី ៧២% នាឆ្នាំ១៩៩៥ មកនៅក្រោម ៥%នាឆ្នាំ២០០៤ ក៏ប៉ុន្តែជំងឺនេះ មិនអាចលុបបំបាត់បានទេពីព្រោះយើងមិនអាចប្រើថ្នាំសំលាប់សត្វខ្យងខ្លា នៅខេត្តក្រចេះ-ស្ទឹងត្រែងបាន ដោយមូលហេតុប៉ះពាល់បរិស្ថាន ជាពិសេសនៅ កន្លែងដែលមានសត្វផ្សោត ហេតុនេះ នៅឆ្នាំ២០០៧ អត្រាឈឺចាប់មានឡើងវិញក្នុងកំរិត ៤-៧% ប៉ុន្តែត្រូវកាត់បន្ថយវិញមកដល់០.១៣% នៅខេត្តស្ទឹងត្រែង និង០.១៦%នៅខេត្តក្រចេះ ក្នុងឆ្នាំ២០១១។ ទោះបីការធ្វើតេស្តអេលីហ្សាឆ្នាំ២០១០ឃើញ មាន អត្រាវិជ្ជមានទាប នៅភូមិ កំពង់ក្របី,អាចេន (៨%) សំបូរ(១១%),ចារថ្នោល(៥%),សំបុក(៨%) និងកោកណ្តាល (១១%) ក៏ដោយ ក៏យើងនៅមានការព្រួយបារម្ភចំពោះអត្រាខ្ពស់នៅក្បាលជ្រូវ (៥១%) និងកំពង់ក្របី (២៧%) និងស្រែខឿន (១៧%)ដែរ។ លទ្ធផលពិនិត្យខ្យងខ្លា នៅពុំឃើញមានស៊ីស្តូ នៅក្បាលជ្រូវ(២០០០ខ្យង) ក្រគរ (៥៧៣ខ្យង) ប៉ុន្តែឃើញវិជ្ជាន៩ក្បាលក្នុងខ្យង ១,៣២៥ នៅកំពុងផៃក្រុងក្រចេះ(០,៦៨%) ។ ការពិនិត្យលាមកគោ,ក្របី ២២វត្ថុតាងមិនឃើញមានស៊ីស្តូទេ ហើយការពិនិត្យសត្វកណ្តុរតាមមាត់ទន្លេ ៥២ក្បាល ក៏មិនឃើញមានការឆ្លងរោគដែរ។

**គ-ការប្រយុទ្ធ នឹងព្រូនដែលឆ្លងតាមម្ហូបអាហារ (Food Borne Trematode)**

ជាពិសេស សាច់ជ្រូក-គោ ឬសាច់ត្រីឆៅ ដូចជា ដង្កូវថ្លើម និងតេនីញ៉ាជាដើម។យើងកំពុងចាប់ផ្តើមស្រាវជ្រាវអំពីបញ្ហា ដង្កូវថ្លើមដែលអាចជាបញ្ហាសុខភាពសាធារណៈមួយដែរនៅកម្ពុជា ព្រោះយើងដឹងថា ប្រទេសថៃ ភាគឥសាន ដែលប្រជាជនទំលាប់ ហូបត្រីឆៅ,មុាំឆៅ គេបានរកឃើញថាដង្កូវថ្លើមជា មូលហេតុ ចំបងមួយរបស់ជំងឺមហារីក,ជំងឺផ្លូវប្រម៉ាត់ ឬជំងឺថ្លើម។ យើងទើបតែស្រាវជ្រាវឃើញ អត្រាផ្ទុកដង្កូវថ្លើម នៅភូមិ-ស្រុក១ចំនួនមានប្រហែល៤០% ក្នុងនោះមានភូមិអង្គស្វាយចេក ខេត្តតាកែវមានរហូតដល់៥៤% ឃុំសូគងមាន២៣% ខេត្តកំពង់ចាម,ដែលប្រជាជនក្នុងភូមិទំលាប់ចូលចិត្តហូបភ្លាត្រីឆៅ, ចំណែកឯខេត្តស្ទឹងត្រែងមាន១៤% ខេត្តរតនគីរីមាន៧% ក៏ប៉ុន្តែ នៅខេត្តព្រះវិហារនឹងខេត្តក្រចេះ មានតែ១%ទេ។ ទាមទារការស្រាវជ្រាវត្រូវធ្វើបន្តទៅទៀត។

**ឃ- ជំងឺដង្កូវព្រូន ក្នុងទឹករងៃ (Lymphatic filariasis)**

ដែលឆ្លងដោយមូសខាំ ហើយចូលទៅរស់ នៅក្នុងក្រពេញទឹករងៃ (ជាតុទឹកពណ៌លឿងឬឥតពណ៌ដែលជ្រាបចេញពីឈាម) ហើយ ដែលមានព្រូនឈ្មោលមានប្រវែង ៤០ ស.ម ញីមាន ៦-១០ស.ម។ ចាប់ពីឆ្លងកូនដង្កូវដោយមូសខាំដល់ពេលមានរោគសញ្ញាជំងឺនេះទាមទារ រយៈពេលរហូតដល់ទៅ២០ឆ្នាំ។ ព្រូននេះមិនសូវមានទេនៅកម្ពុជា ហើយកាលពីឆ្នាំ២០០៥ មជ្ឈមណ្ឌលជាតិបានរកឃើញក្នុងអត្រាផ្ទុកកូនដង្កូវក្នុងឈាមនៅខេត្តរតនគីរីមាន២,៧៥% ខេត្ត ស្ទឹងត្រែងមាន ០,៨០% ខេត្តសៀមរាបមាន ០,៤០-០,៨០% ខេត្តព្រះវិហារ ០,៤០%។ បន្ទាប់មកត្រូវបានកាត់បន្ថយនៅត្រឹម ០,១-០,៦% តាំងពីឆ្នាំ២០១០ មកក្រោយពីមជ្ឈមណ្ឌលបានបញ្ចប់ការផ្តល់ថ្នាំព្យាបាល និងការពារទូទាំងសហគមន៍ ជុំទី៥ ដល់ប្រជាជននៅតំបន់ទាំងនោះ ហើយបច្ចុប្បន្នដោយ អត្រាផ្ទុកដង្កូវក្នុងឈាម មានក្បៀសសូន្យមជ្ឈមណ្ឌលកំពុងតាមដានវាយតំលៃ ដើម្បីធ្វើផែនការសកម្មភាពលុបបំបាត់ទាំងស្រុងឲ្យក្នុងឆ្នាំ២០១៦។7

# ការិយាល័យរដ្ឋបាល, ហិរញ្ញវត្ថុ

## ខ/របាយការណ៍បូកសរុបការងាររដ្ឋបាល, ហិរញ្ញវត្ថុ, ឆ្នាំ២០១១

### ក.សកម្មភាពការងារផ្នែករដ្ឋបាល

ការិយាល័យរដ្ឋបាលជាសេនាធិការរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ ហើយបានអនុវត្តន៍ការងារដូចខាងក្រោមៈ

**១.សកម្មភាពការងារៈ**

- សំរបសំរួលការងារប្រចាំថ្ងៃ
- ពង្រាង តាក់តែង ចុះលេខ និង ចែកចាយលិខិតស្នាម
- ធ្វើសំណើរសុំបេសកកម្មចំនួនៈ ចំនួន 832 លើក
- ចុះលេខចេញៈ ២៣៤០ លេខ
- ចុះលេខចូលៈ ៦៩១ លេខ
- រៀបចំមហាសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ២០១០
- រៀបចំវគ្គបណ្តុះបណ្តាលមីក្រូទស្សន៍ជំងឺគ្រុនចាញ់
- រៀបចំវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសការព្យាបាលជំងឺគ្រុនចាញ់ និង គ្រុនឈាម
- ពិធីចុះហត្ថលេខារវាមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ជាមួយនឹងសេវាឯកជន និង សិក្ខាសាលាតំរង់ទិសស្តីអំពីការអនុវត្តន៍យុទ្ធសាស្ត្រភាពជាដៃគូរនៃសេវាសាធារណៈ និង ឯកជនរួមគ្នាប្រយុទ្ធនឹងជំងឺគ្រុនចាញ់

**២.បុគ្គលិកៈ**

- ជាអង្គភាពរដ្ឋបាលកណ្តាលមានមន្ត្រីរាជការសរុបចំនួន ១៤៩ នាក់ដោយរួមបញ្ចូលទាំងបុគ្គលិកគំពោងមូលនិធិលសកលផងដែរ ក្នុងនោះរួមមានៈ
  - មន្ត្រីរាជការចំនួន៨៨នាក់មានឈ្មោះក្នុងបញ្ជីតារាងប្រាក់បៀវត្សត្រឹមថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០១១
  - បុគ្គលិកកិច្ចសន្យាមានចំនួន ១១នាក់
  - បុគ្គលិកបណ្តែតមានចំនួន ២២ នាក់;
  - មន្ត្រីឈប់សំរាកគ្មានបៀវត្សចំនួន ០៥នាក់;
  - មន្ត្រីស្ថិតក្រោមគំរោងមូលនិធិសកល ចំនួន ២៣ នាក់

- មជ្ឈមណ្ឌលមានរចនាស័ម្ពន្ធរដ្ឋបាលដូចខាងក្រោមៈ
  - ប្រធាន ១រូប និង អនុប្រធាន ៧រូប
  - មានការិយាល័យ ៣គឺ ការិយាលរដ្ឋបាល ការិយាល័យគណនេយ្យ និង ការិយាល័យបច្ចេកទេស។

    **ការិយាល័យរដ្ឋបាល ៤៥នាក់;**

    - ផ្នែករដ្ឋបាល : ១៧ នាក់;
    - ផ្នែកឃ្លាំងឱសថ : ០៦ នាក់
    - ផ្នែកដឹកជញ្ជូន : ២២ នាក់

| | | |
|---|---|---|
| <u>ការិយាល័យគណនេយ្យ</u> | **០៥ នាក់;** | |
| - ផ្នែកគណនេយ្យ | : | ០៥ នាក់ |
| <u>ការិយាល័យបច្ចេកទេស</u> | **៧៤ នាក់** | |
| - ផ្នែកបច្ចេកទេស | : | ១៧ នាក់ |
| - ផ្នែកអេពីដេមីសាស្ត្រ | : | ៣ នាក់ |
| - ផ្នែកប៉ារ៉ាស៊ីតសាស្ត្រ | : | ១៧ នាក់ |
| - ផ្នែកបាណកសាស្ត្រ | : | ១០ នាក់ |
| - ផ្នែកអប់រំសុខភាព | : | ៧ នាក់ |
| - កម្មវិធីព្រូនអំបោះ | : | ០៥ នាក់ |
| - កម្មវិធីស៊ីស្ដូ | : | ០៣ នាក់ |
| - កម្មវិធីជម្ងឺគ្រុនឈាម | : | ១១ នាក់ |

## ៣. <u>ការងារក្របខ័ណ្ឌ</u>

| ល.រ | ប្រភេទ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | វេជ្ជបណ្ឌិត/ថ្នាក់ឯកទេស | ០១ | |
| ២ | ឱសថការី/ថ្នាក់ឯកទេស | | |
| ៣ | វេជ្ជបណ្ឌិត/ថ្នាក់បណ្ឌិត | ០២ | |
| ៤ | ឱសថការី/ថ្នាក់បណ្ឌិត | | |
| ៥ | វេជ្ជបណ្ឌិត/ថ្នាក់ Master | ០៥ | |
| ៦ | ឱសថការី/ថ្នាក់ Master | | |
| ៧ | ទន្តបណ្ឌិត/ថ្នាក់ Master | | |
| ៨ | គ្រូពេទ្យមធ្យម/ថ្នាក់ Master | ០១ | |
| ៩ | វេជ្ជបណ្ឌិត | | |
| ១០ | ឱសថការី | ៤១ | |
| ១១ | ទន្តបណ្ឌិត | | |
| ១២ | គ្រូពេទ្យមធ្យម | ៩ | |
| ១៣ | ឱសថការីមធ្យម | ១ | |
| ១៤ | ទន្តពេទ្យ | | |
| ១៥ | គិលានុបដ្ឋាកមធ្យម | ២១ | |
| ១៦ | ឆ្មបមធ្យម | | |
| ១៧ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | ១៥ | |
| ១៨ | គិលានុបដ្ឋាកបថម | ១ | |

| | | | |
|---|---|---|---|
| ១៩ | ឆ្មបបឋម | | |
| ២០ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម | | |
| ២១ | បុគ្គលឹកតិលានសង្គ្រោះ | ១ | |
| ២២ | បុគ្គលិគ្គរដ្ឋបាល | ៤ | |
| ២៣ | បុគ្គលិកគ្មានបច្ចេកទេស | ២២ | |
| ២៤ | បុគ្គលិកផ្សេងៗ | | |
| សរុប | | ១២៤ នាក់ | |

## ៥.ការងារបណ្តុះបណ្តាល

➢ ការងារបណ្តុះនៅក្រៅប្រទេស

| ល.រ | ឈ្មោះ | ផ្នែក/តួនាទី | ការប្រជុំឬវគ្គ | កាលបរិច្ឆេទ | ប្រទេស | អ្នកឧបត្ថម្ភ |
|---|---|---|---|---|---|---|
| 1 | -Dr. Char Meng Chour<br>- Dr. Muth Sinuon<br>- Dr. Prak Vonn<br>- Dr. Chhneang Sovutha | - Director<br>- Chief of Admin unit<br>- PHD Kampong Chhnang<br>- PHD Kratie | - Intestinal Parasite Control Project in the Central Area of Cambodia | 05-09/12/2011 | Korean | KAHP |
| | -Dr. Heng Pisal<br>- Dr. Leang Rithea | - Vice Director<br>- Chief of research unit | - The Planning Workshop of Greater Mekong Sub-region Malaria Program | 13-14/12/2011 | Thailand | URC |
| 2 | - Dr.Po Ly | - VWM Team Leader | - American Society of Tropical Medicine and Hygiene | 04-08/12/2011 | USA | London School of Tropical Medicine &Hygien |
| 3 | -Dr. Chea Nguon | - Vice Director | - American Society of Tropical Medicine and Hygiene | 4-13/12/2011 | USA | NIH |
| 4 | -Dr. Kheng Sim<br>- Dr. Meas Tha<br>- Dr. Chea Huch<br>- Dr. Siv Sovannaroth<br>- Dr. Boukheng Thavrin<br>- Phar. Ngau Vanthon<br>- Ms. Sok Vanne | - Vice Director<br>- Vice director<br>- Vice director<br>- Chief of technical bureau<br>- Chief of HE unit<br>- Chief of pharmacy unit<br>- VMW officer | - American Society of Tropical Medicine and Hygiene | - American Society of Tropical Medicine and Hygiene | USA | Global Fund |
| 5 | -Dr. Tho Sochantha<br>- Ms. Mao Srey Touch | - Vice Director<br>- Entomology officer | - Testing and Data Analyzing on Entomology | 10-18/12/2011 | Vietnam | Globla Fund R6 |
| 6 | - Dr. Lek Dysoley<br>- Phar. Mam Boravann | - Vice chief of technical bureau<br>- AMFM coordinator | - ASTM 60th Annual Meeting | 04-08/12/2011 | USA | NAMRU-2 |
| 7 | -Dr. To Setha | - Dengue fever officer | - Combating dengue in ASEAN | 07-09/11/2011 | LAO | WHO |
| 8 | - Dr. Ngan Chantha | - ViceDirector | - American Society of Tropical Medicine and Hygiene 60th Annaul Meeting | 04-08/12/2011 | USA | NAMARU-2 |
| | - Dr. Boukheng | - Chief of HE | - Interpersonal | 07-10/11/2011 | Singapore | Global Fund R9 |

| | | | | | | |
|---|---|---|---|---|---|---|
| | Thavrin | Unit | Communication Skills | | | |
| **9** | - Dr. Chea Nguon<br>- Dr. Po Ly | - Vice director<br>- VMW Team Leader | - The NUS Initiative to Improve Health in Asia (NIHA) | 31/10/2011 to 04/12/2011 | Singapore | NUS Global Asia Institute |
| **10** | - Dr. Lek Dysoley<br>- Dr. Sut Thang Phann<br>- Dr. Sok Sochetra | - vice chief of Technical Bureau<br>- M & E Officer<br>- M & E Officer | - The Regional Training for Strengthening Monitoring and Evaluation (M&E) in the Greater Mekong Sub-region. | 18-29/10/2011 | Lao | MC |
| **11** | - Mr. Sam Bunleng | - Dengue Fever Officer | - Health and Geographic Information System | 24/10/2010 to 04/11/2010 | Thailand | Thai Budget |
| 12 | - Dr. To Setha | - Dengue Fever Officer | - Workshop on Chikunguga Vector Surveillance & Virus Isolation | 19-23/09/2011 | Malaysia | IMR |
| 13 | - Dr. Tho Sochantha | - Vice director | - Training in Management and Analysis of Data | 10-22/10/2011 | Belgium | Institute of Tropical Medicine Antwerp |
| 14 | -Dr. Kheng Sim<br>- Dr. Chea Nguon<br>- Dr. Siv Sovannaroth<br>- Dr. Lek Dysoley<br>- Dr. Boukheng Thavrin<br>- Dr. Srey Sophannaroth | - Vice Director<br>- Vice Director<br>- Chief of Technical Bureau<br>- Vice chief of Technical Bureau<br>- Chief of H.E unit<br>- M&E Officer | - A Strategy for the Containment of Artemisinin-Tolerant Malaria Parasites in South East Asia | 13-15/09/2011 | Bangkok | WHO |
| 15 | - Dr. Chea Ngun<br>- Dr. Tho Sochantha<br>- Dr. Po Ly | - Vice Director<br>- Vice Director<br>- VMW Team Leader | - ACT Malaria Forum in strengthening the capacity of the malaria program to meet the goals and objectives of malaria control and its eventual elimination | 19-24/09/2011 | China | ACT Malaria |
| 16 | - Dr. Tho Sochantha<br>- Dr. Chan Vanna | - Vice Director<br>- IBN Team Leader | - The 9th International Training Course on Management of Malaria | 28/08/2011 to 03/09/2011 | Thailand | |
| 17 | - Dr. Siv Sovannaroth<br>- Dr. Muth Sinuon | - Chief of Technical Bureau<br>- Chief of Admin unit | - Innovative Strategies for Sustainable Control of Asian Schistosomiasis and Other Helminth Zoonoses through Socio-Ecosystem-Bases Interventions | 15-17/08/2011 | China | IDRC Project |
| 18 | - Ms. Mao Sokny | - Entomology Officer | Training and Analysis of Blood Filter Papers for Detecting Malaria Anti bodies | 15/08/2011 to 15/09/2011 | Belgium | DGDC |
| 19 | - Ms. Sem Rithy<br>- Ms. Kim Marath | - Labo Officer<br>- Labo Officer | - One Week Malaria molecular laboratory training program | 23-27/05/2011 | Thailand | WWARN |
| 20 | - Dr. Chea Huch | - Vice Director | - Regional Program Managers Meeting on Lymphatic Filariasis and other Selected Neglected Tropical Diseases | 30/05/2011 to 02/06/2011 | Fiji | WHO |
| 21 | - Dr. Duong Socheat | Director | - Asia Pacific Malaria Elimination Network (APMEN)'s Third Annual Meeting | 08-12/05/2011 | Malaysia | APMEN |
| 22 | - Dr. Sut Thang Phann<br>- Phar. Ouk Rada<br>- MA. Soeru Sothea | - Technical Officer<br>- Pharmacy officer<br>- Pharmacy Officer | - Seminar on Anti-Malaria for Asian and African Country | 17-30/05/2011 | China | China budget |
| 23 | - Dr. Uk Sambunny | Technical Officer | - The Qualitative and Mixed Methods in International Health (QMM) | 27/05/2011 to 11/07/2011 | Belgium | ITM |
| 24 | - Dr. Suon Seila<br>- Dr. Lim Pharath<br>- Ms. Sreng Sokunthea | - Vice chief of Technical Bureau<br>- Labo Officer<br>- Labo Officer | - Tracking Resistance to Artemisinin Collaboration (TRAC) Co-investigator, Laboratory and Data-Manager Training | 20-22/04/2011 | Thailand | MORU |
| 25 | - Dr. Po Ly | - VMW Team | - RBM Malaria in Pregnancy (MPWG) Working Group | 17-21/04/2011 | Switzerlan | WHO |

| | | | | | | |
|---|---|---|---|---|---|---|
| | | Leader | Meeting Addressing Malaria in pregnancy in the Asia Pacific Region | | d | |
| 26 | - Dr. Kheng Sim | - Vice Director | - Infromal Consultation on Myanmar Artemisinin Resistance Containment (MARC) Framework | 04-05/04/2011 | Myanmar | WHO |
| 27 | - Dr. Ngan chantha<br>- MA. Chea Monthavy | - Vice director<br>- Vice chief of Admin | - WHO ASEAN Workshop on Priority Actions for Dengue Prevention and Control | 03-05/05/2011 | Philiphine | WHO |
| 28 | - Dr. Chea Nguon<br>- Dr. Tho Sochantha | - Vice Director<br>- Vice Director | - ACTM Malaria Executive Board and Partner Meeting 2011 | 14-20/03/2011 | Lao | ACTMalaria Foundation |
| 29 | - Dr. Muth Sinuon | - Chief of admin unit | - The 96 years of Opisthorchiasi, Past, Present and Future International Congress of Liver Flukes | 06-10/03/2011 | Thailand | The Liver Flue Network |
| 30 | - Dr. Suon Seila<br><br>- Ms. Sreng Sokunthea | - vice chief of Technical Bureau<br>- Labo Officer | - Discussion on ongoing collaborative research, to plan for new projects between CNM an the NIH, and to conduct experiments and analyze data | 01-31/03/2011 | Maryland | NIH |
| 31 | - Dr. Lek Dysoley<br><br>- Dr. Po Ly<br><br>- Phar. Mam Boravann | - Vice Chief of Technical Bureau<br>- VMW Team Leader<br>- AMFM Coordinator | - Affordable Medicines Facilities for Malaria (AMFM) | 29/01/2011 to 06/02/2011 | Cameroun | Fonds Mondial |

## ខ.របាយការណ៍បូកសរុបការងារគណនេយ្យ-ហិរញ្ញវត្ថុឆ្នាំ២០១១

### ១.គោលបំណងនិងទិសដៅ

ដើម្បីរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ និងពិសេសការបន្តជំរុញការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ដើម្បីកំណើនការងារសមធម៌និងប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលសំដៅសំរេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រនិងលើកកំពស់កំរិតជីវភាពរបស់ប្រជាពលរដ្ឋ។

ក្រសួងសុខាភិបាលបានរៀបចំនូវផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០០៨-២០១៥ ដែលបានកំណត់គោលបំណងគោលនយោបាយក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រថវិកាក៏ដូចជាផែនការប្រតិបត្តិប្រចាំឆ្នាំតាមកម្មវិធីដែលផ្តោតលើគោលបំណងគោលនយោបាយចំបងៗចំនួន៤ក៏ប៉ុន្តែមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រមានបេសកកម្ម ត្រូវនឹងគោលបំណងគោលនយោបាយទី២៖បង្កានិងទប់ស្កាត់ជម្ងឺឆ្លង ព្រមទាំងពង្រឹងប្រព័ន្ធតាមដានជម្ងឺដើម្បីឆ្លើយតបមានប្រសិទ្ធភាពទៅនឹងជម្ងឺរាតត្បាតដែលលេចឡើងនិងលេចឡើងសារជាថ្មីដែលជាជ្រុងទី២នៃយុទ្ធសាស្ត្រចតុកោណទី៤ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស្ថិតនៅក្នុងគោលនយោបាយវិស័យសុខាភិបាល។

### ២.ផែនការសកម្មភាពនិងលទ្ធផលដែលសំរេចបានក្នុងឆ្នាំ២០១១

- ➢ បានធ្វើគំរោងផែនការចំណូល-ចំណាយថវិកាប្រចាំឆ្នាំ២០១១ដែលរដ្ឋសភាបានអនុម័តរួចសរុបមានទឹកប្រាក់ចំនួនៈ១,៩៣៤,១០០,០០០៛០០បើប្រៀបធៀបនិងថវិកាឆ្នាំ២០១០គឺមានការកើនឡើង ០,០៣២%ការកើនឡើងនេះក្រសួងសុខាភិបាលចាំបាច់ត្រូវកំរិតថវិកាអនុវត្តន៍តាមកម្មវិធីនិងមិនមែនកម្មវិធីអោយមានតម្លាភាពបំផុតលើការចំណាយហើយរាល់ការទិញឱសថប្រតិករនិងបរិក្ខារទេព្យរបស់មជ្ឈមណ្ឌលជាតិជាគោលការណ៍ក្រសួងសុខាភិបាលបានឱ្យគ្រប់អង្គភាពក្រោមឱវាទស្នើសុំលើកសំណើមកក្រសួងនូវរាល់ធានាចំណាយណាដែលមានលក្ខណៈជាលទ្ធកម្មដើម្បីក្រសួងមានភាពងាយស្រួលក្នុងការប្រមូលផ្តុំគំរោងរាល់តំរូវការរបស់អង្គភាពនីមួយៗឱ្យអង្គភាពលទ្ធកម្មក្រសួងធ្វើបែបបទលទ្ធកម្មសាធារណៈបានទាន់ពេលវេលានិងចំមុខចំណាយជៀសវាងការបំបែកគំរោងតូចៗដែលខុសនឹងនីតិវិធីលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ➢ ថវិកាដែលស្នើសុំហើយទទួលបានក្នុងឆ្នាំ២០១១នេះរួមមានដូចខាងក្រោម ÷

**ក/ស្ថានភាពចំណូលថវិការដ្ឋក្នុងឆ្នាំ២០១១**

➢ សមតុល្យដើមឆ្នាំ២០១១ជាសម្ភារជំពូក៦០,៦២ចំនួន = *៣៣៤,១៤១,៤០០៛០០*

- សរុបចំណូលជាសាច់ប្រាក់និងសម្ភារជំពូក៦០,៦១,៦២,៦៤ចំនួន = ១,៦៨៨,៤៨០,៦១០៛០០
- សរុបចំណូលថវិកាជាសាច់ប្រាក់ជំពូក៦០,៦១,៦២,៦៤ចំនួន = ៦៤៣,៨៤៩,៤០០៛០០

  ក្នុងនោះរួមមាន ÷

  + ប្រាក់រដ្ឋទេយ្យបុរេប្រទានមិនមែនកម្មវិធី ជំពូក៦០,៦១ = ៧១,០០០,០០០៛០០

  +ប្រាក់រដ្ឋទេយ្យបុរេប្រទានតាមកម្មវិធីជំពូក៦២ = ២៥,០០០,០០០៛០០

  +ប្រាក់បៀវត្សនិងប្រាក់បំណាច់មិនមែនកម្មវិធីជំពូក៦៤ = ៥៤៧,៨៤៩,៤០០៛០០
- ចំណូលបង់ពន្ធផ្លូវរថយន្តផ្ទេរភារៈចំណាយជំពូក៦៣មិនមែនកម្មវិធីចំនួន = ១១,០៥០,០០០៛០០
- ចំណូលបង់ថ្លៃអគ្គិសនីផ្ទេរភារៈចំណាយជំពូក៦០មិនមែនកម្មវិធីចំនួន = ១៧៩,៩២៤,៤០០៛០០
- ចំណូលបង់ថ្លៃទឹកផ្ទេរភារៈចំណាយជំពូក៦០មិនមែនកម្មវិធី ចំនួន = ៥,៤២០,៣០០៛០០
- ចំណូលដួសជុលរថយន្ត( លទ្ធកម្មក្រសួង )ជំពូក៦១មិនមែនកម្មវិធីចំនួន = ១៤៧,០៤០,៤០០៛០០
- ចំណូលដួសជុលអគារ( លទ្ធកម្មក្រសួង )ជំពូក៦១មិនមែនកម្មវិធីចំនួន = ៧៥,៣៦៥,៦០០៛០០

•ចំណូលជាសម្ភារ(លទ្ធកម្មក្រសួង)ជំពូក៦០មិនមែនកម្មវិធី ចំនួន = ៣៤៧,១៣៦,៥១០៖០០

•ចំណូលជាសម្ភារបោះពុម្ព(លទ្ធកម្មក្រសួង)ជំពូក៦២តាមកម្មវិធីចំនួន = ២៧៨,៦៩៤,០០០៖០០

រាល់ចំណូលជាថវិកានិងសម្ភារដែលការិយាល័យគណនេយ្យយើងខ្ញុំទទួលបានពីក្រសួងសុខាភិបាលមានថវិកាតាមកម្មវិធីនិងថវិកាមិនមែនកម្មវិធី។ គណនេយ្យករយើងខ្ញុំបានញែកយ៉ាងច្បាស់លាស់នូវតួលេខថវិកាទាំងពីរខាងលើដោយយោងប័ណ្ណចំណាយឬប័ណ្ណបញ្ចេញសម្ភាររបស់ក្រសួងដើម្បីអនុវត្តកិច្ចបញ្ជិកាចំណូលរបស់គណនេយ្យនៃអង្គភាពតាមនីតិវិធី(ថវិការដ្ឋទេយ្យបុរេប្រទានឬក៏ថវិកាលទ្ធកម្មសាធារណៈ)និងតាមគោលការណ៍ច្បាប់គណនេយ្យហិរញ្ញវត្ថុ។

## ខ/ស្ថានភាពចំណាយថវិការដ្ឋក្នុងឆ្នាំ២០១១៖

•• សរុបចំណាយជាសាច់ប្រាក់និងសម្ភារជំពូក៦០,៦១,៦២,៦៤ ចំនួន = <u>១,៧៥៣,២៩៣,៣៧០៖០០</u>

•ចំណាយថវិកាជាសាច់ប្រាក់ជំពូក៦០,៦១,៦២,៦៤ ចំនួន = ៦៤៣,៨៤៩,៤០០៖០០

ក្នុងនោះរួមមាន ៖

\+ ប្រាក់រដ្ឋទេយ្យបុរេប្រទានមិនមែនកម្មវិធីជំពូក៦០,៦១ = ៧១,០០០,០០០៖០០

\+ប្រាក់រដ្ឋទេយ្យបុរេប្រទានតាមកម្មវិធីជំពូក៦២ = ២៥,០០០,០០០៖០០

\+ប្រាក់បៀវត្សនិងប្រាក់បំណាច់មិនមែនកម្មវិធីជំពូក៦៤ = ៦៤២,៧៨២,១៥០៖០០

- ➢ សំណេះចំណាយបៀវត្ស = ១,០៦៧,២៥០៖០០

•ចំណាយបង់ពន្ធផ្លូវរថយន្តផ្ទេរភារៈចំណាយជំពូក៦៣មិនមែនកម្មវិធីចំនួន = ១១,០៥០,០០០៖០០

•ចំណូលបង់ថ្លៃអគ្គិសនីផ្ទេរភារៈចំណាយជំពូក៦០មិនមែនកម្មវិធីចំនួន = ១៧៩,៩២៤,៤០០៖០០

•ចំណាយបង់ថ្លៃទឹកផ្ទេរភារៈចំណាយជំពូក៦០មិនមែនកម្មវិធីចំនួន = ៥,៤២០,៣០០៖០០

•ចំណាយជួសជុលរថយន្ត(លទ្ធកម្មក្រសួង)ជំពូក៦១មិនមែនកម្មវិធីចំនួន = ១៤៧,០៤០,៤០០៖០០

•ចំណាយជួសជុលអគារ (លទ្ធកម្មក្រសួង)ជំពូក៦១មិនមែនកម្មវិធីចំនួន = ៧៥,៣៦៥,៦០០៖០០

•ចំណាយជាសម្ភារ (លទ្ធកម្មក្រសួង)ជំពូក៦០មិនមែនកម្មវិធីចំនួន = ៣៦២,០៥៨,៧៧០៖០០

•ចំណាយជាសម្ភារបោះពុម្ព(លទ្ធកម្មក្រសួង)ជំពូក៦២តាមកម្មវិធីចំនួន = ៣២៨,៥៨៤,៥០០៖០០

- ➢ សមតុល្យចុងឆ្នាំ២០១១ជាសម្ភារជំពូក៦០,៦២ចំនួន = <u>២៦៩,៣២៨,៦៤០៖០០</u>

*តារាងស្ថានភាពបញ្ចូល-បញ្ចេញសម្ភារប្រចាំឆ្នាំ២០១១គិតជារៀល*

| ល.រ | បរិយាយ | សមតុល្យដើមគ្រា | បញ្ចូលក្នុងគ្រា | បញ្ចេញក្នុងគ្រា | សមតុល្យចុងគ្រា |
|---|---|---|---|---|---|
| ១ | សម្ភារសំអាតនិងអនាម័យ | ១៤,៧៨២,៨០០ | ១០,៥២០,៦០០ | ១២,៦១៨,១៧០ | ១២,៦៨៥,២៣០ |
| ២ | សម្ភារផ្គត់ផ្គង់សំរាប់ថែទាំសម្ភារឧបករណ៍ | 0 | ៤៣,៦០១,២០០ | ២៥,១១១,៤០០ | ១៨,៤៨៩,៨០០ |
| ៣ | ប្រេងឥន្ទនៈនិងប្រេងរំអិល | 0 | ២៥១,៩៤៩,២០០ | ២៥១,៩៤៩,២០០ | 0 |
| ៤ | សម្ភារការិយាល័យនិងការបោះពុម្ព | ៧១,២៨២,៦០០ | ១៤,១៨៦,២១០ | ៤៥,៥០០,៧០០ | ៣៩,៩៦៨,១១០ |
| ៥ | ឯកសណ្ឋានពេទ្យ | 0 | ១៣,៨៨០,០០០ | ១៣,៨៨០,០០០ | 0 |
| ៦ | សម្ភារនិងបរិក្ខារបច្ចេកទេស | 0 | ១២,៩៩៩,៣០០ | ១២,៩៩៩,៣០០ | 0 |
| ៧ | សម្ភារឃោសនាអប់រំផ្សព្វផ្សាយ | ២៤៨,០៧៦,០០០ | ២៧៨,៦៩៤,០០០ | ៣២៨,៥៨៤,៥០០ | ១៩៨,១៨៥,៥០០ |
| | សរុប... | ៣៣៤,១៤១,៤០០ | ៦២៥,៨៣០,៥១០ | ៦៩០,៦៤៣,២៧០ | <u>២៦៩,៣២៨,៦៤០</u> |

ចំពោះរាល់ការចំណាយជាថវិកាក្តីជាសម្ភារក្តីជាលទ្ធកម្មក្រសួងក្តីជាការផ្ទេរភារៈចំណាយដោយក្រសួងក្តីគណនេយ្យ ករបានថតចំលងរៀបចំទុកដាក់ឯកសារបានគ្រប់គ្រាន់និងយ៉ាងត្រឹមត្រូវតាមកិច្ចបញ្ជីការការរបស់គណនេយ្យ។

ទន្ទឹមនឹងនោះ ÷

- បានធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនិងសន្និធិឃ្លាំងប្រចាំឆ្នាំ២០១១ទាន់ពេលវេលាជូនក្រសួង
- បានរៀបចំទុកដាក់ប្រមូលផ្តុំឯកសារក្នុងឆ្នាំ២០១១ដែលពាក់ព័ន្ធនិងការងារគណនេយ្យឱ្យមាន សណ្តាប់ធ្នាប់ល្អទាំងថវិកាជាសាច់ប្រាក់ថវិកាជាសម្ភារក៏ដូចឯកសារនីតិវិធីលទ្ធកម្មឬការផ្ទេរភារៈចំណាយដោយក្រសួងសុខាភិបាល។

- បានរៀបចំបញ្ជីស្នាមគណនេយ្យសំរាប់ឆ្នាំ២០១១ដើម្បីត្រៀមជូនប្រតិភូសវនកម្មជាតិឬប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬប្រតិភូសវនកម្មផ្ទៃក្នុងនិងរួមសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងសុខាភិបាលនៅតែការផ្ទួរផ្ទងតួលេខជាមួយនាយកដ្ឋានថវិកា-ហិរញ្ញវត្ថុប៉ុណ្ណោះ។
- បានរៀបចំរបាយការណ៍លទ្ធផលការងារដែលសំរេចបានតាមកម្មវិធីនៃសកម្មភាពនិងការអនុវត្តថវិកាផែនការឆ្នាំ២០១១ដាក់ជូនការិយាល័យផែនការនៃនាយកដ្ឋានថវិកា-ហិរញ្ញវត្ថុក្រសួងសុខាភិបាលដើម្បីធ្វើការបូកសរុបដាក់ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ជាក់អំពីលទ្ធផលនៃការងារដែលបានអនុវត្តក្នុងឆ្នាំកន្លងមក។

**៣.ទិសដៅគំរោងផែនការសំរាប់ឆ្នាំ២០១២**

- បានលើកគំរោងផែនការឆ្នាំ២០១២ជាមាតិកាថវិកាសំរាប់ខ្ទង់ចំណាយណាតាមកម្មវិធីនិងខ្ទង់ចំណាយណាមិនមែនកម្មវិធីដែលជាផែនការប្រចាំឆ្នាំរបស់អង្គភាពតាមកំណើននៃការអនុញ្ញាតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅលើជំពូកនីមួយៗដូចជាជំពូក៦០, ៦១, ៦២, ៦៣ឱ្យកើនតែ ៥% ប៉ុណ្ណោះចំណែកឯជំពូក៦៤បៀវត្សរ៍វិញ ឱ្យកើនរហូតទៅដល់២០% សំរាប់ប្រតិបត្តិការលើវិស័យ សុខាភិបាលដែលអនុវត្តន៍ទៅលើការងារគ្រប់គ្រងរដ្ឋបាលបច្ចេកទេសការងារដំណើរការរៀបចំជួសជុលនិងថែទាំមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រទាំងមូល។
- បានសិក្សាលើផែនការឆ្នាំ២០១២ដើម្បីអនុវត្តន៍ប្រតិបត្តិការប្រចាំឆ្នាំប្រចាំត្រីមាសប្រចាំឆមាសដែលមានថវិកាតាមកម្មវិធីនិងមិនមែនកម្មវិធី។
- បានរៀបចំនិងបែងចែកថវិកាតាមមខ្ទង់ជំពូកសំរាប់ការងារថែទាំជួសជុល និងដំណើរការងារអង្គភាពដើម្បីឱ្យមាននិរន្តន៍ភាពនិងតម្លាភាពគ្រប់កម្មវិធីជាតិមានៈកម្មវិធីប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់, កម្មវិធីប្រយុទ្ធ នឹងជម្ងឺគ្រុនឈាម, កម្មវិធីប្រយទ្ធនឹងជម្ងឺស៊ីស្តូសូមីញ៉ាដង្កូវព្រូនពោះវៀន និងកម្មវិធីប្រយុទ្ធនឹងជម្ងឺព្រូនអំបោះហ្វីលែ
- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រនឹងខិតខំបន្តលើកកំពស់ការអនុវតន្តន៍ផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨ ២០១៥ដើម្បីកែលំអសុចនករសុខភាពសំខាន់ៗក្នុងការឈានទៅសំរេចឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២នីតិកាលទី៤នៃរដ្ឋសភាឆ្នាំ២០០៨ ២០១៣និងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាពិសេសលើការកាត់បន្ថយការស្លាប់ដោយជម្ងឺគ្រុនចាញ់និងឈានត្រៀមលុបបំបាត់ជម្ងឺគ្រុនចាញ់ជាបណ្តើរៗនិងរហូតឈានទៅលុបបំបាត់ទាំងស្រុងនៅឆ្នាំ២០២៥។

- សមិទ្ធិផលរួម
- បញ្ហាប្រឈម
- អនុសាសន៍
- សេចក្តីសន្និដ្ឋាន
- ផ្លូវឆ្ពោះទៅមុខ

របស់មជ្ឈមណ្ឌលជាតប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រ

## ច/សមិទ្ធិផលការងាររួមរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រឆ្នាំ២០១១

ឆ្នាំ២០១១ជាឆ្នាំគោលមួយដែលបញ្ជាក់ថាកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានរួមចំណែកសំរេចមុនកាលកំណត់នូវសូចនាករគោលដៅសហសវត្សសំរាប់ជំងឺនេះផ្ទាល់ហើយដែលជាសុច្ចនករដែលមានផលវិជ្ជមានដល់សូចនាករស្តីអំពីសុខភាពមាតា-កុមារផងដែរ។អន្តរាគមន៍ជាយុទ្ធសាស្ត្រតាមរយៈកម្មវិធីនេះបានផ្តោតលើៈ

- ទី១ការកាត់បន្ថយអត្រាឈឺ/ស្លាប់ដោយការពារមិនឱ្យមូសដែកគោលញីចំលងគ្រុនចាញ់តាមរយៈការជំរុញឱ្យប្រជាជនដែរស់នៅជាអចិន្ត្រៃយ៍ឬធ្វើចំណាកស្រុកចូលទៅក្នុងតំបន់គ្រុនចាញ់មានសំពន្តក្នុងមុងជ្រលក់ថ្នាំ។
- ទី២ការកាត់បន្ថយអត្រាស្លាប់តាមរយៈការធ្វើរោគវិនិច្ឆ័យព្យាបាលទាន់ពេលវេលាដោយចាប់ផ្តើមពីថ្នាក់ភូមិមក។ក្នុងរយៈកាល៤ឆ្នាំ២០០៦២០១០CNMបានចែកមុងជ្រលក់ថ្នាំប្រសិទ្ធិភាព៣ឆ្នាំចំនួន**២,៣លានមុង**នៅតាមបណ្តាខេត្ត។ ប៉ុន្តែក្នុងរយៈកាល៤ខែចាប់ពីខែវិច្ឆិកា២០១១ដល់ខែកុម្ភៈឆ្នាំ២០១២ក្នុងក្របខណ្ឌនៃការអនុវត្តន៏ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ ២០១១-២០២៥របស់រាជរដ្ឋាភិបាល CNM បានធ្វើយុទ្ធនាការចែកមុងដ៏ធំមួយដែលមិនធ្លាប់មានក្នុងតំបន់អាស៊ី។បានប្រគល់ដោយឥតគិត ថ្លៃនូវមុងចំនួន**២,៧**លាន ដែលជាមុងជ្រលក់ថ្នាំប្រសិទ្ធភាព៣ឆ្នាំជូនប្រជាជន នៅគ្រប់ភូមិក្នុងទូទាំង ប្រទេសដែលមានហានិភ័យគ្រុនចាញ់។
  ក្នុងសហប្រតិបត្តការជាមួយវិស័យឯកជននៅឆ្នាំ២០១១នេះថ្នាំជ្រលក់មុងចំនួន៧សែនកញ្ចប់សំរាប់ជ្រលក់មុង៧សែនត្រូវបានចែកជូនដោយឥតគិតថ្លៃដល់អ្នកលក់មុងចំនួន៥៥០០កន្លែងក្នុងនោះមានអ្នកលក់ដុំ៥០កន្លែង។ចំនួនស្លាប់ដោយគ្រុនចាញ់ឆ្នាំនេះថយចុះ៣៨%គឺពី១៥១នាក់នាឆ្នាំ២០១០មកនៅ៩៣នាក់នា ឆ្នាំ២០១១នេះ។មូលហេតុជាគន្លឹះដលនាំឱ្យកាត់បន្ថយអត្រាស្លាប់បានយ៉ាងច្រើននៅឆ្នាំនេះមាន៣គឺៈ

***<u>មូលហេតុទី១-ប្រជាជនយើងកាន់តែមានការយល់ដឹងច្រើនអំពីជំងឺគ្រុនចាញ់</u>***ដោយឱកាសនៃការទទួលពត៌មានមានកាន់តែច្រើនតាមរយៈវិទ្យុទូរទស្សន៏តាមផ្ទាំងគំនូរនៅទីសាធារណៈ និងតាមមធ្យោបាយឃោសនាទល់មុខគ្នានៅតាមសហគមន៏។ឆ្នាំ២០១១នេះថវិកាចំណាយលើការឃោសនាតាម រយៈវិទ្យុ-ទូរទស្សន៏មានការកើនទ្វេដង។

យើងកំពុងលើកសំណើកែសំរួលកម្មវិធិពីមូលនិធិសកលដើម្បីសុំបង្វែរថវិកាពីមុខសញ្ញានានាមកចំណាយជាង៤សែនដុល្លារសំរាប់វិទ្យុ-ទូរទស្សន៏ឆ្នាំ២០១២នេះពោលគឺកើនជាង៨ដងបើប្រៀបធៀបឆ្នាំ២០១១ ក្នុងនោះសំរាប់ ជាងពាក់កណ្តាលនៃថវិកានេះនឹងត្រូវចំណាយលើស្ថានីយ៏ដែលមានទីតាំងនៅភ្នំពេញដោយវិទ្យុទូរទស្សន៏ដោយ ស្ថានីយ៏១ចំនួនអាចគ្រប់ដណ្តប់ស្ទើរទូទាំងប្រទេសពិសេសជនបទដាច់ស្រយ៉ាល។

***<u>មូលហេតុទី២-ភូមិដែលប្រឈមការចំលងគ្រុនចាញ់</u>***

នីមួយៗសុទ្ធតែមានភ្នាក់ងារសុខភាពស្ម័គ្រចិត្តការពារ-ព្យាបាលជំងឺគ្រុនចាញ់។ភ្នាក់ងារទាំងនេះបានទទួលការបណ្តុះបណ្តាលអំពីវិធីការពារ ព្យាលជំងឺគ្រុនចាញ់ហើយទទួលនូវសំភារៈ ដោះឈាមមើលមេរោគ គ្រុនចាញ់ដឹងលទ្ធផលភ្លាមៗមានឱសថព្យាបាលនៅក្នុងដៃមិនដាច់ស្តុក។ពួកគាត់តែងបញ្ជូនករណីធ្ងន់ធ្ងរឬកុមារអាយុក្រោម៥ឆ្នាំឬស្ត្រីមានផ្ទៃពោះដែលមានមេរោគគ្រុនចាញ់មកមន្ទីរពេទ្យបង្អែកឱ្យបានទាន់ ពេល។***នេះជាការរួម***

*ចំណែក១ក្នុងការកាត់បន្ថយអត្រាស្លាប់របស់កុមារនិងមាតាផងដែរ។*បច្ចុប្បន្នយើងមានភ្នាក់ងារសុខភាពស្ម័គ្រតាមភូមិចំនួន**៨១០៤**នាក់៤០៥៧ភូមិដែលប្រឈមនឹងជំងឺគ្រុនចាញ់ក្នុងនោះមាន២៨៩០នាក់ជាភ្នាក់ងារសុខភាពស្ម័គ្រចិត្តការពារ-ព្យាបាលជំងឺគ្រុនចាញ់សំរាប់១៤៤៥ភូមិដែល ប្រឈមធ្ងន់ធ្ងរនឹងការចំលងជំងឺគ្រុនចាញ់។

ចំណែកភូមិចំនួន២៦១២ទៀតដែលប្រឈមនឹងគ្រុនចាញ់ដែរប៉ុន្តែមិនសូវធ្ងន់ធ្ងរនោះសកម្មភាពតាម ភូមិត្រូវបានអនុវត្តដោយភ្នាក់ងារសុខភាពស្ម័គ្រចិត្តដែលទទួលបន្ទុកការងារសុខភាពជាទូទៅដោយមិនសំដៅតែជំងឺ គ្រុនចាញ់១មុខនោះទេ។

ដើម្បីកាត់បន្ថយអត្រាស្លាប់យើងបានជំរុញការបញ្ជូនករណីគ្រុនចាញ់ធ្ងន់ធ្ងរឬកុមារអាយុក្រោម១ឆ្នាំឬស្ត្រីមានផ្ទៃពោះដែលមានផ្ទុកមេរោគគ្រុនចាញ់ឱ្យមកមណ្ឌលសុខភាពឬមន្ទីរពេទ្យ។ដោយការបញ្ជូននេះហើយទើបចំនួនករណីឈឺកើនឡើងបន្តិចបន្តួច(៧%)គឺពី៥៨,៦២១នាឆ្នាំ២០១០-៦២,៦៨០នាឆ្នាំ២០១១នេះ។

ក្រៅពីកត្តាវិជ្ជមាន (ការយល់-ទុកចិត្តលើសេវាសាធារណៈកាន់តែខ្លាំង)នៃការកើនឡើងនេះក៏មានកត្តាអវិជ្ជមានដែរគឺការធ្វើជនចំណាកស្រុកទៅធ្វើការនៅតំបន់គ្រុនចាញ់ដោយគ្មានការប្រុងប្រយ័ត្នចំពោះមូសដែលគោលញីក្នុងនោះមានការទៅរកការធ្វើនៅការដ្ឋានកសិកម្មចំការកៅស៊ូ-ដំឡូងការដ្ឋានថាមពលអគ្គិសនី-រ៉ែនិងគមនាគមន៏ ដែលមានហានិភ័យគ្រុនចាញ់ជាដើម។អញ្ចឹងហើយបានជានៅខេត្តដែលមិនមែនតំបន់គ្រុនចាញ់ជនចំណាកស្រុក ដែលឆ្លងគ្រុនចាញ់ហើយត្រឡប់មកពីធ្វើការនៅតំបន់គ្រុនចាញ់បានកើនឡើងដូចជាខេត្តកណ្តាលកើន៣១%ខេត្តស្វាយរៀងកើន៣៨%មន្ទីរពេទ្យមជ្ឈឹមនិងភ្នំពេញកើន២៨%។ដោយឡែកនៅខេត្តស្វាយរៀងចំនួនស្លាប់ដោយគ្រុនចាញ់ក្រោយពីត្រឡប់មកពីធ្វើការនៅខេត្តបាត់ដំបង-ប៉ៃលិន បានកើនទ្វេដងគឺពី២នាក់ក្នុងឆ្នាំ២០១០មក៤នាក់ ក្នុងឆ្នាំ២០១១ក្នុងពេលដែលចំនួនស្លាប់ទូទាំងប្រទេសចុះដល់ទៅ៣៨%។ផ្ទុយទៅវិញករណីគ្រុនចាញ់នៅខេត្តដែលធ្លាប់តែប្រឈមគ្រុនចាញ់មួយចំនួនបែរជាថយចុះដូចជាមណ្ឌលគីរីថយ២៩%ក្រចេះ ថយ១៧%បន្ទាយមានជ័យ ថយ១៧%ឧត្តរមានជ័យថយ១០%កំពង់ធំថយ៦%សៀមរាបថយ៥%រតនគីរីថយ១៤%ប៉ៃលិនថយ៤%កំពតថយចុះ១%។

ចំនួនស្លាប់នៅរតនគីរីថយចុះ**៧១%**គឺពី**៣៨នាក់**ឆ្នាំ២០១០មក**១១នាក់ឆ្នាំ២០១១**ហើយនៅកំពង់ចាមថយចុះ៧៧%គឺពី**២២ នាក់ឆ្នាំ**២០១០មកនៅ**៥នាក់ឆ្នាំ**២០១១នេះ។

## ឆ/បញ្ហាប្រឈមរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ

នាឆ្នាំ២០១១កន្លងមកនេះការអនុវត្តន៏ការងាររបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានជួបនឹងកត្តាប្រឈមចំពោះមុខមួយចំនួនដូចជា៖

-ការចំលងជំងឺគ្រុនចាញ់ចំពោះប្រជាជនផ្លាស់ទីលំនៅពីតំបន់ដែលគ្មានជម្ងឺគ្រុនចាញ់ទៅតំបន់ដែលមានជម្ងឺគ្រុនចាញ់ខ្ពស់នៅក្នុងប្រទេសជាពិសេសនៅការដ្ឋានចំការកៅស៊ូចំការដំឡូងការដ្ឋានថាមពលអគ្គីសនីការដ្ឋានសំណង់ស្ពានថ្នល់ជាដើម។

- ភាពស្មុគស្មាញមួយទៀតគឺថាភ្នាក់ងារចំលងជម្ងឺគ្រុនចាញ់គឺកំពុងបង្ហាញនូវនិន្នាការផ្លាស់ប្តូរលក្ខណៈរបស់វាដែលបង្កឱ្យមានភាពស៊ាំនឹងថ្នាំសំលាប់សត្វល្អិត។

-ប៉ារ៉ាស៊ីតជម្ងឺគ្រុនចាញ់នៅកន្លែងខ្លះចាប់ផ្តើមមានភាពស៊ាំនឹងថ្នាំប្រឆាំងជម្ងឺគ្រុនចាញ់ដ៏មានប្រសិទ្ធិភាពដូចជាថ្នាំអារតេមិស៊ីនិនជាដើម។

-ចំណុចចុងក្រោយគឺការយល់ដឹងឬធ្វេសប្រហែសពីការការពារខ្លួនពីជម្ងឺគ្រុនចាញ់របស់ប្រជាជនមួយចំនួនគឺនៅមានកំរិត។ឧទាហរណ៏អត្រាប្រជាជនដែលប្រើប្រាស់មុងជ្រលក់ថ្នាំគឺមានកំរិតទាបនៅឡើយទោះបីស្ទើរតែ១០០ភាគរយនៃគ្រួសារទាំងអស់មានមុងក៏ដោយ។

ចំពោះកត្តាប្រឈមទាំងនេះយើងមាន*ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការលុបបំបាត់ជម្ងឺគ្រុនចាញ់ឆ្នាំ២០២៥ក្នុងព្រះរាជាណាចក្រកម្ពុជាដែលសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*បានផ្តួចផ្តើមឱ្យរៀបចំចប់សព្វគ្រប់និងបានចុះហត្ថលេខាលើសារលិខិតគាំទ្រកាលពីថ្ងៃទី១១ខែមិនា ឆ្នាំ២០១១។

កត្តាប្រឈមរបស់កម្មវិធីភាពជាដៃគូរវាងសេវាសាធារណៈនិងសេវាឯកជន

ក-ការពង្រីកកិច្ចសន្យានៅស្រុកប្រតិបត្តិថ្មីៗទាមទារមន្ត្រីជាវេជ្ជបណ្ឌិត២រូបនិងឱសថការី២រូបដែលអាចជាបុគ្គលិកធ្លាប់បំរើការនៅអង្គភាពណាមួយថ្នាក់កណ្តាលឬខេត្ត។

ខ-Affordable Medicines Facility for malaria អាចនឹងត្រូវលុបចោលដោយវិបត្តិថវិកា របស់អង្គការមូលនិធិសកល។

## ជ/ការផ្តល់ជាអនុសាសន៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

- គួរតែជំរុញអោយមានការប្រើប្រាស់ឱសថព្យាបាលជំងឺគ្រុនចាញ់ដូចគ្នានៅតាមបណ្តោយព្រំដែនជាពិសេសតំបន់១និងការចុះអង្កេតលើការប្រើប្រាស់ថ្នាំPrimaquineនៅក្នុងប្រទេសកម្ពុជានិងដាក់បញ្ចូលទៅក្នុងសៀវភៅមគ្គុទេសក៏ជាតិព្យាបាលគ្រុនចាញ់។
- CNMគួរតែស្វែងរកនិងធ្វើសេចក្តីសន្និដ្ឋានតាមរយៈការសិក្សាស្រាវជ្រាវលើជំងឺគ្រុនចាញ់បង្កឡើងដោយមេរោគវីវ៉ាក់ដើម្បីអះអាងបញ្ជាក់បង្កើតឡើងអោយមានជាគោលការណ៍នៃការប្រើប្រាស់ថ្នាំPrimaquine និងជឿជាក់ថាពេលអនុវត្តន៍ទៅពិតជាមានសុវត្ថិភាពប្រសិទ្ធិភាពគ្មានផ្តល់ផលប៉ះពាល់ជាពិសេសថ្នាំនេះមាន ប្រសិទ្ធិភាពខ្ពស់ផងដែរប្រឆាំងនឹងការលាប់ឡើងវិញ។
- CNM គួរតែពិចារណាផងដែរលើការប្រើប្រាស់ថ្នាំ Primaquine តែមួយដូសស្មើនឹង 45mg ឬក៏ពីរដូសក្នុងមួយអាទិត្យសំរាប់ប្រឆាំងនឹង gametocytes of P.falciparum.
- ត្រូវយកចិត្តទុកដាក់ជាអតិភាពខ្ពស់លើការបញ្ជូននិងគ្រប់គ្រងលើករណីគ្រុនចាញ់ធ្ងន់ធ្ងរ ដែលបានបញ្ជូនមកដើម្បីកាត់បន្ថយអត្រាស្លាប់ជាពិសេសករណីស្លាប់ដោយសារគ្រុនចាញ់ធ្ងន់ធ្ងរ។
- CNMគួរតែពង្រីកបន្ថែមជាបណ្តោះអាសន្នសំរាប់RDTsនិងACTsសំរាប់ផ្តល់អោយខាងប៉ូលីសនិងយោធាចាប់តាំងពីពួកគេនិងក្រុមគ្រួសារបានផ្លាស់ប្តូរទីលំនៅទៅតំបន់ដែលងាយរងគ្រោះ ដោយសារជំងឺគ្រុនចាញ់ តាមបណ្តោយព្រំដែនកម្ពុជាថៃ។ក្នុងពេលជាមួយគ្នានោះដែរCNMក៏បានរៀបចំកិច្ចការជាមួយនឹងក្រសួង មហាផ្ទៃនិងក្រសួងការពារជាតិដើម្បីរៀបចំបណ្តុះបណ្តាលការគ្រប់គ្រងករណីជំងឺគ្រុនចាញ់សំរាប់បុគ្គលិកបំរើការងារនៅទីនោះ។
- ត្រូវទាក់ទងជាមួយអ្នកផ្តល់សេវាសុខភាពឯកជន ក្នុងការជំរុញអោយមានការធ្វើរោគវិនិច្ឆ័យ និងព្យាបាលបានត្រឹមត្រូវតាមរយៈការបើកវគ្គបណ្តុះបណ្តាលការប្រជុំនិងការចុះអភិបាលកិច្ច។
- បង្ករលក្ខណៈងាយស្រួលដល់ក្រសួងសុខាភិបាលក្នុងការហាមប្រើប្រាស់ថ្នាំព្យាបាលជំងឺគ្រុនចាញ់តែមួយមុខការនាំចូលដោយគ្មានច្បាប់អនុញ្ញាតិមិនបានចុះបញ្ជីនិងថ្នាំក្លែងក្លាយចូលមកក្នុងប្រទេសកម្ពុជា។
- គំរោងសាកល្បងដែលបានរៀបចំឡើងសំរាប់ MDA នៅតាមទីកន្លែងផ្សេងៗគ្នានៃប្រទេសចាប់តាំងពី MDA មានសក្តានុពលភាពមកគឺជាគន្លឹះដ៏សំខាន់មួយក្នុងប្រទេសកម្ពុជាដែលជំរុញឆ្ពោះទៅការកាត់បន្ថយជំងឺគ្រុនចាញ់នៅក្នុងប្រទេស។
- ការរៀបចំឡើងវិញនិងផ្សព្វផ្សាយការណែនាំច្បាស់លាស់សំរាប់ព្យាបាលគ្រុនចាញ់ដែលនៅតែវិជ្ជមាននៅថ្ងៃទី៣បន្ទាប់ពីបានព្យាបាលត្រឹមត្រូវនិងរួមបញ្ចូលទាំងការអង្កេតដោយផ្ទាល់ផងក្នុងការព្យាបាល។
- រួមមន្តនិងផ្សព្វផ្សាយការណែនាំជាក់លាក់ស្តីពីការប្រើប្រាស់ indoor residual spraying សំរាប់ជួយធ្វើអន្តរាគមន៍នៅតាមclustersដែលមានមេរោគគ្រុនចាញ់ដែលបានព្យាបាលហើយនៅតែវិជ្ជមានដល់ថ្ងៃទី៣។
- ផ្នែកអប់រំសុខភាពគួរតែរៀបចំការប្រជុំជាក្រុមពិភាក្សាសំរាប់BCCដើម្បីជឿជាក់ថាការខិតខំប្រឹងប្រែងត្រូវចៀសវាងការរៀបចំសម្ភារៈជាន់គ្នាពីរដងនិងសារជូនដំណឹងមានលក្ខណៈត្រឹមត្រូវតាមស្តង់ដារ។
- សារជូនដំណឹងBCCគួរផ្តោតអារម្មណ៍សំខាន់ទៅលើសេចក្តីត្រូវការសំរាប់ការធ្វើរោគវិនិច្ឆ័យ រហ័សដោយគ្មានពន្យាពេលវេលាទេចំពោះស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៥ឆ្នាំនៅពេលមានគ្រុនក្តៅឬសង្ស័យថាមានគ្រុនចាញ់ជាពិសេសភ្ជាប់ជាមួយការព្យាបាលនិងបញ្ហាដែលកើតមានជាឧទាហរណ៍ដូចជាការប្រើ

ប្រាស់មុងជ្រលក់ថ្នាំនៅពេលធ្វើដំណើរទៅឆ្ងាយពីផ្ទះ។សារជូនដំណឹងនឹងតំរូវសំរាប់ប្រជាជនចល័តនិងចំណាកស្រុកផងដែរដោយមានការបញ្ជាក់និងសង្កត់ធ្ងន់ទៅលើការហាមប្រើថ្នាំតែមួយមុខរបស់រាជរដ្ឋាភិបាល និងឃាត់មិនអោយប្រជាជនប្រើប្រាស់ថ្នាំគ្មានគុណភាពរួមទាំងថ្នាំក្លែងក្លាយផងដែរ

- ការសិក្សាស្រាវជ្រាវលើភាពដែលអាចទទួលយកបានក្នុងការប្រើប្រាស់និងតំលៃរបស់ITNsសំរាប់ប្រជាជនចល័តនិងចំណាកស្រុក។
- ការសិក្សាស្រាវជ្រាវលើភ្នាក់ងារចំលងនៃជីវបរិស្ថានវិទ្យាបរិស្ថានវិទ្យានិងភាពស៊ាំនៃថ្នាំបាណកឃាដរួមបញ្ចូលទាំងពេលវេលានិងការខាំដោយភ្នាក់ងារចំលង។
- VMW គួរតែតាមដាននិងដឹងចំពោះប្រជាជនចល័តនៅតាមភូមិនិមួយៗ។
- ការចុះត្រួតពិនិត្យនូវរាល់សកម្មភាពផែនការនិងតាមដានជាបន្តទៅលើគន្លឹះសុចនាករនៅគ្រប់កំរិត។តាមដានការចំណាយទៅលើសកម្មភាពនិងតាមដានលើការអនុវត្តគំរោងតាមផ្នែកខេត្តស្រុកប្រតិបត្តិដែលតាមគេ មិនទាន់និងជួយឧបត្ថម្ភណែនាំឱ្យធ្វើទៅតាមការស្នើសុំ។
- រៀបចំការប្រជុំសំរាប់៣ខែនិង៦ខែជាមួយនឹងដៃគូរអនុវត្តគំរោងនិងផ្តល់ព័ត៌មានត្រឡប់ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង។
- រៀបចំសិក្ខាសាលាដើម្បីធ្វើការបណ្តុះបណ្តាលពាក់កណ្តាលឆ្នាំ(on procurement, finance and M&E) សំរាប់ដៃគូរអនុវត្តគំរោង(SRs and SSRs)។
- បង្កើននូវភាពជឿជាក់និងមានគុណភាពខ្ពស់លើទិន្នន័យជំងឺគ្រុនចាញ់ដែល នឹងត្រូវធ្វើការសំរេចចិត្តទៅលើការប្រតិបត្តិរួមទាំងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាព។មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ត្រូវមានទំនាក់ទំនងគ្នាយ៉ាងសកម្មជាមួយមន្ទីរសុខាភិបាលខេត្តក្នុងការប្រមូលទិន្នន័យវិភាគទិន្នន័យនិងបកស្រាយលទ្ធផល។
- ផ្នែកខាងអេពីដេមីសាស្ត្រនឹងត្រូវទំនាក់ទំនងជាមួយនាយកដ្ឋានផែនការនិងព័ត៌មានផ្នែកសុខភាពនៃក្រសួងសុខាភិបាលនិងជឿជាក់ថាទំរង់ថ្មីសំរាប់ការប្រមូលទិន្នន័យត្រូវបានយកទៅប្រើនៅតាមសេវាសុខភាពសាធារណៈតាមកម្មវិធីដោយមានការយល់ដឹងខ្ពស់។

## ឈ/សេចក្តីសន្និដ្ឋាន

- ប្រការដែលគួរជាទីមោទនៈក្នុងមជ្ឈដ្ឋានជាតិ អាណត្តិរបស់២អន្តរជាតិក្នុងរយៈកាលជាង-សភាជាតិគឺឆ្នាំ១៩៩៨យើងសំរេចសូចនាករគោលដៅ២០១១-សហសវត្សសំរាប់ជំងឺគ្រុនចាញ់មុនកាលកំណត់ដល់ទៅ៤ឆ្នាំគឺៈ សុច្ចនករស្ទូលគោលដៅសហវត្សដែលមានចែងក្នុង"ផែនការអភិវឌ្ឍន៏ជាតិបច្ចុប្បកម្ម២០០៩-២០១៣ មានតែមួយ ទេដែលពាក់ព័ន្ធនឹងជំងឺគ្រុនចាញ់ គឺចំនួនស្លាប់ដោយជំងឺគ្រុនចាញ់ក្នុងប្រជាជន១០០,០០០នាក់ ដោយបាន កំណត់ថានឹងបញ្ចុះអត្រានេះឱ្យនៅត្រឹម០,៨០នាឆ្នាំ២០១៥ក៏ប៉ុន្តែជាក់ស្តែងយើងបានបញ្ចុះពី៥,៤១នាឆ្នាំ១៩៩៨មកដល់០,៧០នាឆ្នាំ២០១១ពោលគឺយើងសំរេចបាន៤ឆ្នាំមុនកាលកំណត់។
- យើងមានមោទនភាពចំពោះការសំរេចគោលដៅសហសវត្សពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺគ្រុនចាញ់ក៏ពិតមែនប៉ុន្តែយើងនៅមានភារកិច្ចជាច្រើនរួមគ្នាបន្តធ្វើទៀតព្រោះថាផែនការយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០១១របស់រាជរដ្ឋាភិបាលមានផែនទីផ្លូវដែលយើងត្រូវធ្វើដំណើរ២០២៥-ទៅហួសឆ្ងាយពីគោលដៅសហសវត្ស នោះទៅទៀតក្នុងនោះចាប់ពីឆ្នាំ២០១៥តទៅការស្លាប់ដោយជំងឺគ្រុនចាញ់លែងជាបញ្ហាចំបងរបស់សុខភាពសាធារណៈកម្ពុជាបន្ទាប់មកចាប់ពីឆ្នាំ២០២០ទៅលែងមានគ្រុនចាញ់ដោយសារមេរោគគ្រុនចាញ់ប្រភេទហ្វាល់ស៊ីហ្វារ៉ូម ដែលជាប្រភេទកាចសាហាវអាចឱ្យស្លាប់បាន និងនៅទីបំផុតចាប់ពីឆ្នាំ២០២៥តទៅលែងមានជម្ងឺគ្រុនចាញ់ឆ្លងក្នុង ប្រទេសយើង។
- ជម្ងឺគ្រុនឈាមជាប្រភេទជម្ងឺដែលកំពុងតែផ្ទុះឡើងជាថ្មីនៅក្នុងចំណោមប្រទេសនៅSouth-AsiaPacific ហើយដែលវាមានភាពខ្លាំងក្លានៅក្នុងប្រទេសទន់ខ្សោយដែលរចនាសម្ព័ន្ធសុខាភិបាលនៅមានកំរិតទាប និងប្រភពធនធាននៅមានកំរិត។ ជាបទពិសោធន៏កាលពីឆ្នាំ២០០៧ខណៈដែលមានការរាតត្បាតខ្លាំងក្លានោះគឺយើងត្រូវតែធ្វើការពង្រឹង រចនាសម្ព័ន្ធសុខាភិបាលគ្រប់កំរិតក្នុងការតាមដាននិងទស្សន៏ទាយករណីគ្រុនឈាម និងការផ្តល់ការងារធ្វើរោគ វិនិច្ឆ័យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលានិងការងារថែរក្សាព្យាបាលអ្នកជម្ងឺឱ្យបានល្អប្រសើរ-កាត់បន្ថយអត្រាមរណៈ។ បង្កើនកិច្ចសហការយ៉ាងជិតស្និត និងការចូលរួមរបស់សហគមអន្តរជាតិអង្គការ-មិនមែនរដ្ឋាភិបាលអន្តរក្រសួងនិងវិស័យឯកជនគឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធិភាពក្នុងការទប់ស្កាត់និងហ៊ុំព័ទ្ធជម្ងឺគ្រុនឈាម។
- កិច្ចសហការយ៉ាងជិតស្និតរវាងក្រសួងសុខាភិបាល-ដៃគូរអភិវឌ្ឍន៏អង្គការមិនមែនរដ្ឋាភិបាលនិងការចូល-រួមរបស់ម្ចាស់ជំនួយអន្តរជាតិគឺជាគន្លឹះដ៏សំខាន់ក្នុងការទប់ស្កាត់និងហ៊ុំព័ទ្ធជម្ងឺគ្រុនឈាម។ ទំហំនៃការរាតត្បាតនិងទំនាក់ទំនងកិច្ចសហការនៃការឆ្លើយតបរវាងដៃគូរផ្សេងៗ គឺជាការដែលមិនអាច គ្រោងទុកបាន។កត្តាដែលបង្កនាំឱ្យកើតមានជាការរាតត្បាតមានលក្ខណៈស្មុគស្មាញ-ស៊ាំញុាំនិងមានទំនាក់ទំនង យ៉ាងជិតស្និតទៅនឹងកត្តាបាណកសាស្រ្តភាពស៊ាំ-វីរុសសាស្រ្ត-បរិស្ថាននិងសង្គមបរិយាកាស។
- កត្តាផ្សេងៗទៀតដូចជាបំរែបំរួលសីតុណ្ហភាពក៏ជាកត្តាថាមពលនាំមកនូវសមត្ថភាព បង្កបង្កើតពូជដល់ភ្នាក់ងារចម្លងតាមមូលដ្ឋាន។ការនាំចូលមកនូវប្រភេទវីរុសថ្មីដែលបណ្តាលមកពីការកើនឡើងនូវការធ្វើដំណើរនៅ ក្នុងនិងក្រៅតំបន់ក៏ជាកត្តាដ៏សំខាន់ក្នុងការនាំឱ្យមានការរាតត្បាតផងដែរ។ការចុះថយនូវ

ប្រព័ន្ធភាពស៊ាំជាមួយនឹងប្រភេទមេរោគវីរុសថ្មីមួយនិងវត្តមាននៃប្រព័ន្ធការពារមួយរយៈពេលនៃបុគ្គលម្នាក់ៗបានបង្ករឱ្យមានភាពស្មុគស្មាញ ដល់កត្តាអេពីដេមីសាស្រ្ត។ជាទូទៅការរាតត្បាតនៃជម្ងឺគ្រុនឈាមមិនអាចកំណត់បានទេ។មុនពេលមានវ៉ាក់សាំង ចាក់ការពារជម្ងឺគ្រុនឈាមការងារកំចាត់ភ្នាក់ងារចម្លងគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់ការ រាតត្បាតជម្ងឺគ្រុនឈាម។សកម្មភាពទាំងនោះគួរអនុវត្តនៅចន្លោះពេលនៃការរាតត្បាតដោយអនុលោមទៅតាម សភាពការណ៏ជាក់ស្តែងនៃយុទ្ធសាស្រ្តកំចាត់ភ្នាក់ងារចម្លង។យន្តការនៃការតាមដានវីរុសសាស្រ្តនៅតាម មន្ទីរពេទ្យ ចំណុចគួរតែពង្រឹងនៅដំណាក់កាលមុនការរាតត្បាតដើម្បីរកឱ្យឃើញនូវការចលតប្រភេទមេរោគវីរុសគ្រុនឈាម។

- ក្រសួងសុខាភិបាលនិងអង្គការដៃគូអភិវឌ្ឍន៏គួរតែបង្កើនការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ និងទាន់ពលវេលានូវរាល់ឪសថបរិក្ខារ- ថ្នាំបាណកឃាដដើម្បីត្រៀមទុកជាមុននិងធ្វើការឆ្លើយតបបន្ទាន់និងបង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធថែម ឡើងទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងម្ចាស់ជំនួយនានា។

## ញ/ផ្លូវឆ្ពោះទៅមុខរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រឆ្នាំ២០១២

ផ្លូវឆ្ពោះទៅមុខរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ក្នុងការអនុវត្តន៏កម្មវិធីប្រតិបត្តិសំរាប់ពេលខាងមុខឆ្នាំ២០១២៖

បន្តលើការអនុវត្តគំរោងដែលកំពុងតែប្រើប្រាស់ថវិកាGFR6,R9SSFមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់នឹងត្រូវដឹកនាំសហការលើការប្រតិបត្តិគំរោងនិងផែនការជាយុទ្ធសាស្ត្រសំរាប់គ្រុនចាញ់ថ្នាក់ជាតិ (២០១២-២០១៥)ដូចគ្នាផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសំរាប់រយៈពេលយូរដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុង ប្រទេសកម្ពុជា (២០១២-២០២៥)។

CNMនឹងត្រូវធ្វើការប៉ាន់ប្រមាណនិងបំពេញនូវសេចក្តីត្រូវការសំរាប់ការរៀបចំកម្មវិធីឡើងវិញនៅគ្រប់ផ្នែកទាំងអស់និងដៃគូរអនុវត្តន៏គំរោងជាមួយនឹងថវិការSSF ។

គ្រប់ផ្នែកទាំងអស់នៃCNMនិងដៃគូរអនុវត្តន៍គំរោងនឹងត្រូវអនុវត្តន៍គំរោងសកម្មភាពពីឆ្នាំ២០១២ដូចគ្នាដែរនិងផែនការសកម្មភាពសំរាប់ឆ្នាំ២០១២តាមការកែសំរួលផែនការសកម្មភាពនិងថវិកា។

សកម្មភាពចំពោះមុខរបស់កម្មវិធីភាពជាដៃគូររវាងសេវាសាធារណៈនិងសេវាឯកជនដែលនឹងត្រូវធ្វើជាន្តទៀត៖

**ក**-តាមដានវាយតម្លៃការអនុវត្តន៏នៅស្រុកទាំង៦ដែលក្នុងនោះមានស្រុកប្រតិបត្តិ*ឈូក,បានលុង*,បាត់ដំបង, សំពៅលូន,អូរជ្រៅនិងសូត្រនិគមនិងបន្ថែមការកិច្ចសន្យា៤ស្រុកប្រតិបត្តិទៀតគឺឆ្លូង, ព្រះវិហារ ១ស្រុកនៅ កំពង់ចាមនិង១ស្រុក និងនៅកំពង់ធំមួយស្រុក។បទពិសោធន៏ក្នុងរយៈកាល៥ឆ្នាំ២០១១-២០១៥ នៃការ អនុវត្តន៏កិច្ចសន្យាជាមួយផ្នែកឯកជនទាំង១០ស្រុកនឹងក្លាយជាគុណប្រយោជន៏រួមសំរាប់មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រកំណត់និយាមការ (ស្តង់ដារ) ពាក់ព័ន្ធនឹង លក្ខណៈសម្បត្តិរបស់សេវាឯកជន ដែលត្រូវអនុញ្ញាតឬមិនអនុញ្ញាតអោយព្យាបាលជំងឺគ្រុនចាញ់ចាប់ពី ឆ្នាំ២០១៦ទៅ។

**ខ**-ដោយយោងតាមស្មារតីពីភាក្យាក្នុងអង្គសន្និបាតសុខាភិបាលលើកទី៣៣(៤-៥មិនា២០១២) មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រកំពុងពិនិត្យលទ្ធភាពហាមលក់ឱសថប្រឆាំងមេរោគគ្រុនចាញ់ដោយចាប់ផ្តើមនៅឆ្នាំ២០១៣ខាងមុខនេះនៅស្រុកប្រតិបត្ត ១ ចំនួន ជាពិសេសតំបន់ដែលមានមេរោគគ្រុនចាញ់ស៊ាំនឹងឱសថព្យាបាលជំងឺនេះខ្លាំងជាងគេ។

**គ**-ពង្រីកសក្មភាពសហការជាមួយនិយោជកចំការកៅស៊ូ-ជំឡូងឬការដ្ឋានផ្សេងៗ ដើម្បីឱ្យនិយោជិកគ្រប់រូបបានទទួលចំណេះដឹងនិងទទួលសេវាពាក់ព័ន្ធនឹងការការពារនិងព្យាបាលជំងឺគ្រុនចាញ់។

**ឃ**-រៀបចំដំណើរការ AMFm (Affordable Medicines Facility for malaria) (ឧបសម្ព័ន្ធទី២) ជាមួយរោងចក្រផលិតឱសថព្យាបាលគ្រុនចាញ់ដែលអង្គការមូលនិធិសកលអនុញ្ញាតឱ្យ ផ្គត់ផ្គង់។ សព្វថ្ងៃមានផលិតផល២ហើយគឺ: EURATESOM (Dihydroartemisinin-piperaquine) manufactured by Sigma-Tau, an Italian pharmaceutical group and PYRAMAX (Artesunate & Pyronaridine tetraphosphate) manufactured by Shin Poong Pharm. Co. Ltd. (Approved by European MedicineAgent)។យើងកំពុងរៀបចំអនុវត្តន៏និតិវិធី សុំថវិកាអង្គការមូលនិធិសកល សំរាប់ផ្គត់ផ្គង់ ឱសថប្រភេទនេះដើម្បីព្យាបាល none complicated malaria case វិស័យ សាធារណៈ និងឯកជន តាមយន្តការAMFm។ក្រុមហ៊ុននាំចូលឱសថត្រូវចង់ថ្លៃជូនរោងចក្រផលិតឱសថក្នុងសមាមាត្រ៥%នៃតម្លៃឱសថ ចំណែកថវិកាការ៩៥%ទៀតជាបន្ទុករបស់អង្គការមូលនិធីសកល។ ដោយយន្តការនេះថ្មីសំរាប់កម្ពុជា

យើងរំពឹងទុកថាឱសថដែលនឹងត្រូវនាំចូលចែកចាយតាមយន្តការនេះអាចមកដល់កម្ពុជានៅក្នុងឆ្នាំ២០១៣ខាងមុខនេះដើម្បីផ្គត់ផ្គង់ទាំងសេវាឯកជនទាំងសេវាសាធារណៈក៏ប៉ុន្តែយើងមិនសង្ឃឹម១០០% នោះទេដោយហេតុថាអង្គការកំពុងជួបវិបត្តិចំណូលថវិកា។

**ង**-បន្តបង្កើយការកសាងផែនការយុទ្ធសាស្ត្រជាតិសំរាប់ភាពជាដៃគូនៃវិស័យសាធារណៈនិងឯកជនដើម្បីលុបបំបាត់ជម្ងឺគ្រុនចាញ់ (National Strategy for Public Private Partnership for Elimination of Malaria in Cambodia)។

›››››››››››››››››››››››››››››››››››››